# ទស្សនៈវិស័យថ្នាក់តំបន់ចំពោះចំការឈើដាំ

## ការពិនិត្យមើលទៅលើតំបន់អាងទន្លេមេគង្គ

អត្ថបទសង្ខេបរបស់អង្គការ WRM —ខែធ្នូ ឆ្នាំ២០០៨

---

### ចំការឈើដាំនៅតំបន់ទន្លេមេគង្គ

ចំការឈើដាំឯកវប្បកម្មនៃដំណាំប្រេងខ្យល់ ដូងប្រេង កៅស៊ូ និងល្ហុងខ្វង បច្ចុប្បន្នកំពុងទទួលបាននូវការនិយមពង្រីកច្រើនឡើងទៅក្នុងតំបន់ដី និងព្រៃរបស់សហគមន៍មូលដ្ឋាន ក្នុងបណ្តាប្រទេសតាមតំបន់ទន្លេមេគង្គ។ ដោយ លើកកម្ពស់ក្នុងន័យការអភិវឌ្ឍន៍ ការកាត់បន្ថយភាពក្រីក្រ និងការបន្ធូរបន្ថយការប្រែប្រួលអាកាសធាតុ ចំការឈើដាំ បែបនេះ កំពុងតែបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គមយ៉ាងធ្ងន់ធ្ងរ។ ទោះបីជាមានសេនារីយូនយោបាយពិបាកៗ មួយចំនួនត្រូវបានបង្កើតឡើងយ៉ាងណាក៏ដោយ ក៏ប្រជាជនមូលដ្ឋាននៅតែកំពុងបន្តការតស៊ូតាមរយៈមធ្យោបាយជាច្រើន ដែលពួកគេអាចធ្វើទៅបាន ដោយចាប់ពីការចងសម្ព័ន្ធភាពដ៏ធំដើម្បីប្រឆាំងនឹងចំការឧស្សាហកម្ម (ដូចជាករណីនៅក្នុងប្រទេសថៃ) រហូតដល់ការតស៊ូជាក្រុមធំទល់នឹងចំការឈើដាំនៅក្នុងប្រទេសកម្ពុជា និងប្រទេសឡាវជាដើម។ គោលបំណងនៃអត្ថបទ សង្ខេបនេះ គឺដើម្បីបង្ហាញពីលក្ខណៈទូទៅនៃការពិតនៅមូលដ្ឋានរបស់ចំការឈើដាំ នៅក្នុងប្រទេសចំនួនប្រាំមួយ ដូចជាប្រទេសភូមា កម្ពុជា ចិន ឡាវ ថៃ និងវៀតណាម ដើម្បីជាមធ្យោបាយបណ្តុះចំណេះដឹងអំពីបញ្ហានេះ ហើយរិតតែសំខាន់ជាងនេះទៀតនោះ ដើម្បីជួយធ្វើឱ្យគេស្តាប់ឮសំលេងរបស់ប្រជាជនមូលដ្ឋាន។ ដូចគ្នានេះដែរ យើងក៏សង្ឃឹមថាពិតមាននេះ នឹងក្លាយជាឧបករណ៍ដ៏មានសារៈសំខាន់សំរាប់ធ្វើអោយរឹងមាំនូវការតស៊ូប្រឆាំងនឹងប្រភេទនៃចំការឈើដាំទាំងនេះទាំងក្នុង និងក្រៅតំបន់ ទន្លេមេគង្គ។

### លក្ខណៈទូទៅរបស់ចំការឈើដាំនៅតំបន់ទន្លេមេគង

### លែងមានព្រំសីមាអាចឆ្លងកាត់បានទៀតហើយៈ ជីវិតរបស់ប្រជាជនតំបន់ទន្លេមេគង្គក្នុងយុគសម័យចំការឈើដាំ

សូមស្វាគមន៍មកកាន់តំបន់មេគង្គ! ដោយប្រើរួមគ្នានូវតំបន់កើតដំណែលតាមការសិក្សាភាសាវិទ្យា ពាក្យដ៏ចំណាស់ដដែល នៅតែត្រូវគេប្រើប្រាស់ទូទាំងតំបន់ ពិសេសនៅក្នុងប្រទេសឡាវ ថៃ និងកម្ពុជា ដើម្បីពិពណ៌នាកន្លែងនេះថាជា "សុវណ្ណភូមិ" ដែលមានន័យថាដីមាស។ ដោយសំបូរធនធានធម្មជាតិដ៏មហិមាពីទន្លេ ព្រៃឈើ និងដីធ្លី ប្រជាជនក្នុងតំបន់ទន្លេមេគង្គ ត្រូវបានចាត់ទុកថាជាមនុស្ស ដែលមានលើសពីទ្រព្យសម្បត្តិទៅទៀត ដោយសារថាពួកគេភាគច្រើនរស់នៅដោយប្រើប្រាស់សមត្ថភាពរបស់ពួកគេធ្វើការរួមគ្នាជាមួយធម្មជាតិ។ ទន្លេ និងព្រៃឈើ

ជាកន្លែងប្រមាញ់ នេសាទ និងប្រមូលចំណែកដីធ្លីជាមាសដែលមាននៅខាងក្នុង ដែលអាចផលិតស្រូវ ភោគដំណាំជាច្រើនប្រភេទ និងផ្តល់ជាជំរកផងដែរ។ នៅក្នុងជ្រុងផ្សេងទៀតនៃពិភពលោក ប្រជាជនយល់ឃើញថាជាតម្រូវការក្នុងការបន្តការឆ្លងកាត់ព្រំសីមា ដោយព្យាយាមឈ្នះឈ្មុលឱ្យហួសពីព្រំសីមាពិតប្រាកដរបស់ខ្លួន ដើម្បីស្វែងរកជីវិតមួយរិតតែប្រសើរ និងដើម្បីមានភោគផលបរិភោគរិតតែច្រើន។ លើកលែងតែមានការបណ្តេញចេញដោយបង្ខំ ប្រជាជនតំបន់ទន្លេមេគង្គមិនងាយចាកចេញទេ ពីព្រោះពួកគេសុទ្ធតែមានដីមាសផ្ទាល់ខ្លួនរបស់ពួកគេ។ នោះប្រហែលជាមូលហេតុដែលអាចពន្យល់បានថា ហេតុអ្វីបានជាប្រជាជនមូលដ្ឋាន មិនយល់ពីការមកដល់របស់វិនិយោគិនដ៏ស្រេកឃ្លាន ដែលប្រញាយគ្នាចូលទៅក្នុងតំបន់នោះ ដើម្បីប្រើប្រាស់ដីរបស់ពួកគេ រួចទាញយកផលប្រយោជន៍ផ្ទាល់ខ្លួនត្រឡប់ទៅផ្ទះវិញ។

ក្រុមហ៊ុនឯកជនជាច្រើន កំពុងប៉ុនប៉ងកាន់កាប់ដីធ្លីជាង ១៨០,០០០ ហិកតា ក្នុងប្រទេសឡាវ និងជាង ៨០០,០០០ ហិកតា ក្នុងប្រទេសកម្ពុជា។ មួយចំនួនជាក្រុមហ៊ុនក្នុងស្រុក ប៉ុន្តែមួយភាគធំជាក្រុមហ៊ុនអន្តរជាតិ។ រដ្ឋាភិបាលប្រទេសតំបន់ទន្លេមេគង្គភាគខាងក្រោម បានផ្តល់សម្បទានជាច្រើនដល់ក្រុមហ៊ុន ដែលគោលបំណងរបស់ពួកគេ គឺត្រូវទន្ទ្រានកាន់កាប់ដីឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន រួចក្រោយមកចាប់ផ្តើមដំណើរការចំការឈើដាំកម្រិតធំ។ ដើមដំបូង ចំការឈើដាំនោះអាចបរាជ័យ ប៉ុន្តែចំនុចនេះមិនមានបញ្ហាទេដរាបណាពួកគេកាន់កាប់ដីតាមបណ្តោយមហាវិថី ចំណាយពន្ធក្នុងកម្រិតមួយដ៏ទាប និងមានពេលវេលាច្រើនក្នុងការដាំដើមឈើសាជាថ្មី។

កត្តាគំរាមកំហែងធំៗចំនួនពីរចំពោះប្រជាជន និងធនធានក្នុងតំបន់ទន្លេមេគង្គ ដូចជាចំការឈើដាំខ្នាតធំ និងទំនប់វារីអគ្គិសនី មានលក្ខណៈសំគាល់រួមជាច្រើន រួមមានបញ្ហាទាក់ទងនឹងតួនាទីរបស់វិស័យឯកជន កង្វះខាតគោលនយោបាយជាក់លាក់ដើម្បីធ្វើឱ្យដំណើរការមានតម្លាភាព និងការទទួលខុសត្រូវ និងកង្វះការចូលរួមពីសំណាក់ប្រជាជនមូលដ្ឋាន។ ទោះបីជាយ៉ាងណាក៏ដោយ ចំការឈើដាំកម្រិតធំ បានដំណើរការទៅមុខកាលពី ១០-១៥ ឆ្នាំមុន ហើយជាលទ្ធផល ប្រជាជនជាច្រើនបានបាត់បង់ដីធ្លីរបស់ពួកគេ នៅមុនពេលដែលពួកគេដឹងថាតើពួកគេមានសិទ្ធិស្របច្បាប់កាន់កាប់ដីនោះ។ ការជម្រុញផែនការទាំងនោះ បានធ្វើឱ្យមានគម្លាតរិតតែឆ្ងាយរវាងប្រជាជន និងអ្នកធ្វើគោលនយោបាយ ហើយប្រជាជននៅតែមិនមានឱកាសធ្វើឱ្យគេស្តាប់ឮនូវសំលេងរបស់ខ្លួន ក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីអនាគតរបស់ពួកគេនៅលើដីធ្លីរបស់ពួកគេ។ ការយកដីពីប្រជាជន មានន័យថាយកបាយ យកដំណាំពីពួកគេ និងយកសន្តិសុខស្បៀងពីគ្រួសាររបស់ពួកគេផងដែរ។ បញ្ហានេះ អាចនាំទៅរកគ្រោះទុរភិក្សដល់ប្រទេស ប្រសិនបើការពិចារណាឡើងវិញបន្ទាន់មួយ ពាក់ព័ន្ធនឹងគោលនយោបាយទាំងនេះ មិនអាចសម្រេចបានទាន់ពេលវេលានោះទេ។

ដោយសារប្រទេសទន្លេមេគង្គទាំងអស់ ដូចជាភូមា កម្ពុជា ចិន ឡាវ ថៃ និងវៀតណាម បច្ចុប្បន្នកំពុងផ្តល់ដីសម្រាប់ចំការឈើដាំខ្នាតធំ រួមមានចំការកៅស៊ូ ចំការប្រេងខ្យល់ ចំការល្ហុងខ្វង និងចំការដូងប្រេង ទន្ទឹមពេលដែលវិនិយោគិនមកពីក្នុងតំបន់ កំពុងលេងល្បែងអំណាចចំពោះប្រទេសទន់ខ្សោយមួយចំនួន។ ក្រុមហ៊ុនប្រទេសចិន ថៃ និងវៀតណាម និងសហគ្រាសជាច្រើនផ្សេងទៀតនៅក្នុងប្រទេសរបស់ពួកគេ កំពុងប្រញាប់ប្រញាល់ឈ្មុះឈ្មុលឱ្យហួសពីព្រំសីមារបស់ខ្លួន ដើម្បីបំពេញតាមតម្រូវការរបស់ឧស្សាហកម្មរបស់ពួកគេ នៅតាមបណ្តាប្រទេសជិតខាងដូចជាប្រទេសកម្ពុជា និងឡាវជាដើម។

នៅក្នុងទសវត្សចុងក្រោយនេះ ការតស៊ូត្រួតពិនិត្យ និងធ្វើយុទ្ធនាការអំពីបញ្ហាចំការឈើដាំនៅក្នុងតំបន់ បានទទួលជោគជ័យតិចតួចបំផុត។ ទោះបីជាយ៉ាងនេះក៏ដោយ ការលេចឡើងនូវបណ្តាញដីធ្លី និងយុទ្ធនាការរបស់ពួកគេ ឧទាហរណ៍យុទ្ធនាការដីសម្បទាននៅក្នុងប្រទេសកម្ពុជា បានធ្វើឱ្យមានយល់ដឹងកាន់តែច្រើនឡើងនៅក្នុងសង្គមទាំងមូល។ ទោះបីជាយ៉ាងនេះក៏ដោយ ក្រុមអ្នកគាំទ្រចំការឈើដាំ នៅតែបន្តផ្សព្វផ្សាយពីចំការឈើដាំ ដោយប្រើប្រាស់ហេតុផលយ៉ាងច្រើន និងសែនស្មុគស្មាញ ដោយមានចាប់ពី "ការធ្វើឱ្យមានស្ថេរភាពដល់ចំការពនេចរ" និង "ការកាត់បន្ថយភាពក្រីក្រ" កាលពី២០ឆ្នាំមុន រហូតដល់មានចំការឈើដាំ ដែលសំដៅបង្កើត ជីវឧស្ម័ន និងឥណទានកាបូន។ ជាច្រើនឆ្នាំមកនេះ ហេតុផលជាច្រើនដែលផ្តល់ដល់ប្រជាជនមូលដ្ឋាន បានផ្លាស់ប្តូរ ប៉ុន្តែអ្វីដែលមិនផ្លាស់ប្តូរ គឺប្រជាជនក្នុងប្រទេសតាមដងទន្លេមេគង្គ បានបន្តបណ្តោយឱ្យគេឈ្មុះឈ្មុលឆ្លងកាត់ព្រំសីមានៃដីរបស់ពួកគេ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៦ សេចក្តីថ្លែងការណ៍ពីការសាមគ្គីគ្នាមួយ ត្រូវបានបង្កើតឡើងចេញពីសន្និសិទតំបន់ទន្លេមេគង្គស្តីពីចំការឈើដាំ ដែលប្រារព្ធធ្វើនៅក្នុងខេត្តក្រចេះ ប្រទេសកម្ពុជា ដែលនៅទីនោះ ប្រជាជនមកពីប្រទេសតាមដងទន្លេមេគង្គចំនួនប្រាំ បានធ្វើការផ្លាស់ប្តូរមេរៀន និងបទពិសោធន៍ដែលពួកគេបានឆ្លងកាត់ ពាក់ព័ន្ធនឹងបញ្ហាចំការឈើដាំលក្ខណៈឧស្សាហកម្ម និងផលប៉ះពាល់របស់វាទៅលើជីវភាពរស់នៅរបស់ប្រជាជន។ ប្រជាជន បានបញ្ជាក់ថា "ផ្ទុយពីការអះអាងរបស់រដ្ឋាភិបាលដែលថា ចំការឈើដាំនឹងចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ ផ្ទុយទៅវិញចំការឈើដាំបានបង្កើនភាពក្រីក្រ ដោយធ្វើឱ្យសហគមន៍ទាំងមូលបាត់បង់ទីលំនៅ ខូចខាតប្រភព ធនធានជីវភាពរស់នៅ និងរារាំងដល់លទ្ធភាពរបស់ពួកគេក្នុងការទទួលបាននូវធនធានធម្មជាតិ"។ ជារួម ពួកគេបាន បញ្ជាក់ថា "*គ្រប់ករណីទាំងអស់ មធ្យោបាយតែមួយគត់ដើម្បីបង្កើតការផ្លាស់ប្តូរ គឺតាមរយៈការតស៊ូរបស់ប្រជាជន*"។ ការតស៊ូមិនមានន័យថាជាអំពើហិង្សានោះទេ ប៉ុន្តែមានន័យផ្សេងថា ប្រជាជនមូលដ្ឋានឯកភាពគ្នាដើម្បីធានាសន្តិសុខ និងការពារសិទ្ធិរបស់ពួកគេ។

ដើម្បីចៀសវាងពីការជម្លាសចេញ និងដើម្បីផ្លាស់ប្តូរជីវិតរស់នៅរបស់ពួកគេ ប្រជាជនក្នុងតំបន់ទន្លេមេគង្គចាំបាច់ត្រូវងាកត្រឡប់ក្រោយវិញ និងត្រូវបញ្ជាក់ឱ្យបានច្បាស់ដល់អ្នកគាំទ្រចំការឈើដាំថា លែងមានព្រំសីមាសម្រាប់ឱ្យក្រុមហ៊ុនឆ្លងកាត់បានទៀតហើយ។ ផ្ទុយមកវិញ ប្រជាជនចង់រក្សា និងទទួលបានមកវិញនូវជីវិតមួយនៅលើដីផ្ទាល់ខ្លួនរបស់ពួកគេ ដែលពួកគេបាន និងកំពុងប្រើប្រាស់ជាច្រើនជំនាន់មកហើយ។ ចំនុចនេះអាចនិយាយបានថាពួកគេចង់រស់នៅលើដែនដី "សុវណ្ណភូមិ" របស់ពួកគេ គឺតំបន់សម្បូរទៅដោយភោគទ្រព្យរបស់ពួកគេ។

## ចំការចំណាំឯកវប្បកម្មរកឃើញថាមានទីកន្លែងជាច្រើនទៀតនៅតាមព្រំដែនក្នុងតំបន់ទន្លេមេគង្គ

ការប្រទាក់ក្នាទៅវិញទៅមកនៃសេដ្ឋកិច្ចទាំងប្រាំមួយក្នុងអាងទន្លេមេគង្គចាប់តាំងពីទសវត្សឆ្នាំ៩០ ត្រូវបានលើកកម្ពស់ក្រោមកម្មវិធីកិច្ចសហការសេដ្ឋកិច្ចអនុតំបន់អាងទន្លេមេគង្គ។ កម្មវិធីនេះ សំដៅបង្កើនឱ្យមានលំហូរវិនិយោគឆ្លងព្រំដែនពីប្រទេសដែលមានសេដ្ឋកិច្ចខ្ពស់ ដូចជាប្រទេសចិន ថៃ និងវៀតណាម ទៅក្នុងប្រទេសក្បែរខាង ដូចជាប្រទេសឡាវ និងកម្ពុជា ដែលបើក "ទ្វារចំហរ" រង់ចាំទទួលក្រុមហ៊ុនបរទេសមកធ្វើការវិនិយោគ។ ដីដ៏ធំទូលាយ និងកំរៃពលកម្មដ៏ថោក ត្រូវបានប្រើប្រាស់ជាវត្ថុលើកទឹកចិត្ត ដើម្បីទាក់ទាញវិនិយោគិនមកអភិវឌ្ឍន៍ចំការឈើដាំជាលក្ខណៈពាណិជ្ជកម្ម ក្នុងទម្រង់ជាសម្បទានដីខ្នាតធំរាប់សិបកន្លែងកាលពី ៤-៥ឆ្នាំកន្លងទៅ។

យើងអាចបែងចែកជាបួនទម្រង់ នៃការវិនិយោគចំការឈើដាំឯកវប្បកម្មនៅក្នុងតំបន់ទន្លេមេគង្គ គឺការវិនិយោគមូលធនបរទេសពីតំបន់ខាងក្រៅតំបន់ទន្លេមេគង្គ ការវិនិយោគឆ្លងព្រំដែននៃមូលធនពីក្នុងតំបន់ទន្លេមេគង្គ ការវិនិយោគក្នុងស្រុកដោយក្រុមមូលធនសំខាន់ៗ និងការវិនិយោគជាលក្ខណៈគ្រួសារដោយក្រុមកសិករដែលមានកម្មសិទ្ធិតិចតួចនៅលើដីធ្លីរបស់ពួកគេ។ ក្នុងអត្ថបទនេះ យើងនឹងសង្កត់ធ្ងន់ប្រភេទពីរដំបូង ពីព្រោះពួកវាទំនងជាមានជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លីដ៏ច្រើនមហិមា និងអាចនាំមកនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សហគមន៍មូលដ្ឋាន។ យើងអាចកំណត់កត្តាសំខាន់ៗនៅក្នុងប្រទេសផ្សេងៗដូចខាងក្រោម

### ប្រទេសឡាវ

ការវិនិយោគចំការឈើដាំនៅក្នុងប្រទេសឡាវ ភាគច្រើននៅក្នុងទម្រង់ជាសម្បទានដីរដ្ឋខ្នាតធំ ជាពិសេសដើម្បីដាំដំណាំប្រេងខ្យល់ និងកៅស៊ូ។ ទាំងនេះ បានទាក់ទាញការវិនិយោគពីប្រទេសជាច្រើនដែលមកពីខាងក្រៅព្រមទាំងខាងក្នុងតំបន់ទន្លេមេគង្គ។ ក្រុមហ៊ុនវិនិយោគដ៏ធំជាច្រើន រួមមានក្រុមហ៊ុនអូជីមកពីប្រទេសជប៉ុន ដែលមានចំការឈើដាំធំៗជាច្រើនកំពុងដំណើរការ និងដែលកំពុងស្វែងរកដីចំនួន ៥០,០០០ ហិកតា ដើម្បីដាំដំណាំប្រេងខ្យល់នៅក្នុងខេត្តបូលីខាំសៃ និងខាំមូអាន់។ ក្រុមហ៊ុនមួយទៀត ឈ្មោះ ប៊ីឡាឡាវ (ប៊ីឡាក្រាស៊ីម) មកពីប្រទេសឥណ្ឌា ដែលមានដីសម្បទានចំនួន ៣០,០០០ ហិកតា ដើម្បីដាំដំណាំប្រេងខ្យល់នៅក្នុងខេត្តសាវណ្ណាខេត។ តួអង្គក្នុងតំបន់រួមមានក្រុមហ៊ុនចំការកៅស៊ូវៀតណាម ដែលមានឈ្មោះថា វៀត-ឡាវ ដាឡាក់ និងដោវទ្យេង ដែលមានកិច្ចសន្យាវិនិយោគកៅស៊ូលើផ្ទៃដីជាង ៣០,០០០ ហិកតា នៅភាគខាងត្បូងប្រទេសឡាវ ឬក្នុងខេត្តចំប៉ាសាក់ និងសាឡាវ៉ាន។ របាយការណ៍ជាច្រើនបានបង្ហាញថា ក្រុមហ៊ុនវៀតណាម កំពុងស្វែងរកការពង្រីកការវិនិយោគដំណាំកៅស៊ូនៅក្នុងប្រទេសឡាវរហូតដល់ ១០០,០០០ ហិកតា ក្នុងរង្វង់១២ឆ្នាំទៀត។ ក្រុមហ៊ុនក្រដាសដ៏ធំបំផុតពីរនៅក្នុងប្រទេសថៃ

ដែលមានឈ្មោះ Advance Agro and Phoenix Pulp and Paper កំពុងស្វែងរកដីនៅក្នុងប្រទេសឡាវដើម្បីដាំដំណាំប្រេងខ្យល់ ដែលជាវត្ថុធាតុដើមសម្រាប់ផ្គត់ផ្គង់រោងចក្ររបស់ពួកគេនៅក្នុងប្រទេសថៃ។

មកដល់បច្ចុប្បន្ននេះ រដ្ឋាភិបាលឡាវបានអនុញ្ញាតផ្តល់ដីចំនួន ១៦៧,០០០ ហិកតា ដល់ក្រុមហ៊ុនបរទេសដើម្បីវិនិយោគទៅលើដំណាំសេដ្ឋកិច្ចឯកវប្បកម្មទូទាំងប្រទេស។ ក្នុងរង្វង់តំបន់នេះ ផ្ទៃដីចំនួន ៨០,០០០ ហិកតា ត្រូវបានផ្តល់សម្រាប់ដាំដំណាំប្រេងខ្យល់ និងប្រហែលជា ៤៦,៦០០ ហិតា សម្រាប់ដាំដំណាំកៅស៊ូ។ ដីសម្បទានភាគច្រើនមានទីតាំងនៅក្នុងចំតំបន់ស្នូល ចុះឆ្ពោះទៅភាគខាងត្បូងរបស់ប្រទេស។

កាលពីខែឧសភា ឆ្នាំ២០០៨ រដ្ឋាភិបាលឡាវ បានដោះស្រាយដោយព្យួរការចេញដីសម្បទាននៅទូទាំងប្រទេស។ ទោះបីជាយ៉ាងនេះក៏ដោយ ការដាក់សំពាធជាបន្តបន្ទាប់ពីសំណាក់អ្នកវិនិយោគិនបរទេស និងការចង់លើកទឹកចិត្តការវិនិយោគនៅក្នុងវិស័យពិតប្រាកដណាមួយរបស់រដ្ឋាភិបាល ថ្មីៗនេះបាននាំគណៈកម្មាធិការផែនការ និងវិនិយោគ (CPI) របស់ប្រទេសឡាវឱ្យបន្តចេញប័ណ្ណវិនិយោគ ទោះបីជាក្នុងលក្ខណៈចំការឈើដាំបែបពាណិជ្ជកម្មដែលត្រូវការដីក្នុងទំហំធំយ៉ាងណាក៏ដោយ។ ខណៈដែលមានសេចក្តីសម្រេចឱ្យផ្អាកសម្បទាន ក្រុមហ៊ុនជាច្រើនមិនអាចទទួលបានសិទ្ធិប្រើប្រាស់ដីជាង ១០០ ហិកតា ដោយស្របច្បាប់នោះទេ។ ទោះជាយ៉ាងនេះក៏ដោយ វាគឺច្បាស់ណាស់ថា ក្រុមហ៊ុនខ្លះទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋានក្នុងការប្រើប្រាស់ដីធ្លី ដោយផ្អែកតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការផែនការ និងវិនិយោគ។ បទដ្ឋានច្បាប់ដ៏ស្មុកស្មាញបច្ចុប្បន្ន ដែលមានបទញ្ញត្តិជាច្រើនមិនស៊ីគ្នាបានបង្កើតឱ្យមានការភ័ណ្ឌច្រឡំក្នុងចំណោមវិនិយោគិន មន្ត្រីរដ្ឋាភិបាល និងប្រជាជនមូលដ្ឋានផងដែរ។ ក្នុងបរិបទនេះ អ្នកភូមិជាច្រើន មិនទទួលបានការការពារសមស្រប ទល់នឹងការបាត់បង់ដីធ្លីរបស់ពួកគេដោយសារតែសម្បទានដ៏មានឥទ្ធពល និងអំណាចនោះទេ។

**ប្រទេសកម្ពុជា**

ទំហំគោលនយោបាយដីធ្លីក្នុងប្រទេសកម្ពុជា មានភាពធំធេងយ៉ាងខ្លាំង។ ព័ត៌មានពីទីស្តីការគណៈរដ្ឋមន្ត្រីនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៣ បានបញ្ជាក់ថា រដ្ឋាភិបាលកម្ពុជាអនុញ្ញាតឱ្យមានសម្បទានសេដ្ឋកិច្ចចំនួន៤០កន្លែង លើផ្ទៃដីសរុបចំនួន ៨០៩,២៩៦ ហិកតា។ ចាប់តាំងពីពេលនោះមក ទូរលេខជាផ្លូវការ មានការពិបាកក្នុងស្វែងរក ប៉ុន្តែរបាយការណ៍បច្ចុប្បន្នគួសបញ្ជាក់ថា ក្នុងអំឡុងវិបត្តិសេដ្ឋកិច្ចពិភពលោក គឺចាប់តាំងពីពេលចាប់ផ្តើមរហូតដល់ពាក់កណ្តាលវិបត្តិ តំបន់ដីធ្លីរបស់ប្រទេសនេះ ត្រូវបានកំណត់ឱ្យដល់វិនិយោគិនបរទេសតាមរយៈដីសម្បទាន ឬតាមរយៈកិច្ចព្រមព្រៀងជួលយូរអង្វែង។

វិនិយោគិនធំៗនៅក្នុងប្រទេសកម្ពុជា ទំនងជាមានទំនាក់ទំនងជិតស្និតជាមួយអ្នកនយោបាយជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាល។ ច្បាប់របស់ប្រទេសនេះបានបញ្ជាក់ថា ដីសម្បទានសេដ្ឋកិច្ច មិនអាចលើសពី ១០,០០០ ហិកតាបានទេ ហើយសម្បទានធំជាងនេះដែលមានមានពីមុន ត្រូវតែកាត់បន្ថយឱ្យស្របតាមច្បាប់។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាល មិនបានចាត់វិធានការណ៍ដើម្បីយកដីទាំងនោះត្រឡប់មកវិញ ពីក្រុមហ៊ុនដ៏មានអំណាច ដែលកាន់កាប់ដីធ្លីដ៏សែនធំល្វឹងល្វើយក្រោមពាក្យសម្បទាន (**<u>ពាក់ព័ន្ធនឹង: សម្បទានសេដ្ឋកិច្ចចំការឈើដាំឆាប់បានផល និងការចិញ្ចឹមជីវិតតាម មូលដ្ឋានក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៦, ផែនទីដីសម្បទាន និងព្រៃសម្បទានក្នុងខេត្តស្ទឹងត្រែង ឆ្នាំ២០០៦</u>**)។ ក្រុមហ៊ុន វ៉ូជីស្សាន គ្រុប (Wuzhishan L.S. Group) មកពីប្រទេសចិន ទទួលបានដីសម្បទានចំនួន ១៩៩,៩៩៩ ហិកតា ដើម្បីដាំដើមស្រល់នៅក្នុង ខេត្តមណ្ឌលគិរី។ ការប្រើប្រាស់ដើមដំបូងចំនួន ១០,០០០ ហិកតា ត្រូវបានអនុញ្ញាត ប៉ុន្តែស្ថានភាពដីដែលនៅសល់ មិនអាចកំណត់បានច្បាស់លាស់។ ក្រុមហ៊ុនចំការឈើដាំដែលគ្រប់គ្រងដោយ បរទេសផ្សេងទៀត ដែលទទួលបាន សម្បទានយ៉ាងធំនោះ រួមមានក្រុមហ៊ុន គ្រីនរីច (Green Rich Company) ដែលដាំដំណាំអាកាស្យា និងដំណាំដូងប្រេងលើផ្ទៃដី ១៨,៣០០ ហិកតា នៅក្នុងខេត្តកោះកុង ក្រុមហ៊ុន ខេមបូឌា ហៃនីង គ្រុប (Cambodian Haining Group) ដែលទទួលបានដីចំនួន ២១,២៥០ ហិកតា ក្នុងខេត្តកំពង់ស្ពឺ ដើម្បីដាំដំណាំដំឡូងមី ដំណាំដូងប្រេង និងចិញ្ចឹមសត្វ និងក្រុមហ៊ុនបីទៀត ដូចជាក្រុមហ៊ុនអភិវឌ្ឍន៏កសិកម្ម ពិភពលោក និងអាស៊ី (Asia World Agricultural Development Co.,) ក្រុមហ៊ុនអភិវឌ្ឍន៏កសិកម្ម សកលលោក (Global Agricultural Development Co.,) និងក្រុមហ៊ុន គ្រេដវន់ឌឺរ អា ដេវ (Great Wonder Ag Dev Col.,) ដែលទទួលបានផ្ទៃដី ម្នាក់ៗសរុបចំនួន ១០,០០០ ហិកតា ដើម្បីដាំប្រភេទឈើមៃស័ក នៅក្នុងស្រុកដូចគ្នាក្នុងខេត្តក្រចេះ ដោយឯកសារព្រមព្រៀងផ្សេងៗទៀតភាគច្រើនរបស់ពួកគេ ត្រូវបានផ្តល់ក្នុងថ្ងៃតែមួយ។

កាលពីខែមីនា ឆ្នាំ២០០៦ អ្នកតំណាងក្រុមហ៊ុនឧស្សាហកម្មកៅស៊ូ (Hainan Natural Rubber Industry Group Corp) ដែលជាក្រុមហ៊ុនផលិតកៅស៊ូធំបំផុត នៅក្នុងប្រទេសចិន និងក្រុមហ៊ុនអភិវឌ្ឍន៏វិនិយោគ (Suigang Investment Development Co., Ltd in Cambodia) បានចុះកិច្ចព្រមព្រៀងគំរោងវិនិយោគដំណាំកៅស៊ូ លើផ្ទៃដីសរុបជាង ៦០,០០០ ហិកតា ដោយរួមបញ្ចូលទាំងការបង្កើតរោងចក្រកែច្នៃនៅប្រទេសកម្ពុជាផងដែរ។ មានរបាយការណ៍បន្ថែមថា ក្រុមហ៊ុនចំនួនពីរផ្សេងទៀតមកពីប្រទេសវៀតណាម បានទទួលការអនុញ្ញាតឱ្យដំណើរការចំការកៅស៊ូលើផ្ទៃដីសរុបចំនួន ១៦,០០០ ហិកតា នៅក្នុងខេត្តមណ្ឌលគិរី។ ដូចគ្នានឹងប្រទេសឡាវ ឧស្សាហកម្មដំណាំកៅស៊ូរបស់ប្រទេសវៀតណាម មានទិសដៅស្វែងរកដីចំនួន ១០០,០០០ ហិកតា

សម្រាប់ដំណើរការចំការឈើដាំដ៏ធំនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍ព័ត៌មានពីខែវិច្ឆិកា ឆ្នាំ២០០៧ (Manager Online ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧) បានបញ្ជាក់ថា ចំការដំណាំកៅស៊ូរបស់រដ្ឋាភិបាលចំនួនបីលើផ្ទៃដីចំនួន ២២,០០០ ហិកតា ត្រូវបានលក់ទៅឱ្យក្រុមហ៊ុនឯកជនចំនួនបីមកពីប្រទេសចិន ក្នុងកិច្ចសន្យារយៈពេល៩៩ឆ្នាំ។ មិនមែនគ្រប់ក្រុមហ៊ុនបរទេសទាំងអស់ សុទ្ធតែអាចទទួលបានសិទ្ធិប្រើប្រាស់ដីធ្លីដោយផ្ទាល់តាមរយៈការអនុញ្ញាតរបស់រដ្ឋនោះទេ។ ផ្ទៃដីចំនួន ២០០,០០០ ហិកតា នៅក្នុងខេត្តស្ទឹងត្រែង ត្រូវបានទទួលដោយក្រុមហ៊ុនក្នុងស្រុកចំនួន១១ ហើយដែលបានស្នើក្រុមហ៊ុនបរទេសមកវិនិយោគ ក្នុងនាមជាវិនិយោគិនទីពីរ។

**ប្រទេសភូមា**

មានការលំបាកជាខ្លាំង នៅក្នុងការទទួលបានរបាយការណ៍ព័ត៌មាន ស្តីពីការអភិវឌ្ឍន៍ចំការឈើដាំនៅក្នុងប្រទេសភូមា។ របាយការណ៍ព័ត៌មានយូរម្តង១ ជាញឹកញាប់បានគូសបញ្ជាក់អំពីទិសដៅដែលបានគ្រោង ហើយមានទិន្នន័យតិចតួចបំផុត ដែលត្រូវបានបោះពុម្ពផ្សាយពីស្ថាប័នពាក់ព័ន្ធ។ ភ្នាក់ងារព័ត៌មានស៊ីនហ័រ បានរាយការណ៍កាលពីខែឧសភា ឆ្នាំ២០០៧ថា យោងតាមក្រសួងកសិកម្ម និងធារាសាស្ត្ររបស់ប្រទេសភូមា ផ្ទៃដីដាំដំណាំកសិថាមពលចំនួន៣.២៤ លានហិកតា នឹងត្រូវអនុញ្ញាឱ្យដំណើរការ ដើម្បីសម្រេចឱ្យបានតាមការគ្រោងទុកនូវដំណាំកសិថាមពលចំនួន២០លានតោនក្នុងមួយឆ្នាំ។ ស្ថិតិផ្លូវការមួយចំនួន ទំនងជាបង្ហាញថា មានផ្ទៃដីសរុបចំនួន ៣០២,០០០ ហិកតា បានដំណើរការចំការកៅស៊ូក្នុងឆ្នាំ២០០៧ (កាសែត Myanmar Times ឆ្នាំ២០០៧)។

**ប្រទេសចិន វៀតណាម និងថៃ : តួរអង្គថ្មី**

ប្រទេសទាំងបីនេះ កំពុងប្រកាន់តួនាទីជាវិនិយោគិននៅក្នុងប្រទេសជិតខាងរបស់ខ្លួន។ ក្រុមហ៊ុនឯកជនជាច្រើននៅក្នុងប្រទេសទាំងនេះ កំពុងបង្កើនសមត្ថភាពផ្នែកវិនិយោគ។ នៅពេលអនាគត ពួកគេនឹងមិនចាំបាច់ពឹងផ្អែកជំនួយ ឬកំចីពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជាធនាគារអភិវឌ្ឍអាស៊ីជាទៀតឡើយ។ ដោយកាន់កាប់ក្នុងទំហំមួយមានកំណត់ ពាក់ព័ន្ធនឹងការងារអភិវឌ្ឍន៍ចំការឈើដាំដ៏មហិមានៅក្នុងប្រទេសរបស់ពួកគេ ក្រុមវិនិយោគិនមកពីប្រទេសចិន ថៃ និងវៀតណាម កំពុងប្រវេសប្រវាសដើម្បីវិនិយោគចំការឈើដាំនៅក្នុងប្រទេសឡាវ និងកម្ពុជា។

ប៉ុន្តែនៅពីក្រោយឆាកនៃដីសម្បទានដ៏មហិមានេះ គឺជាការបាត់បង់កសិដ្ឋាន ចំការ និងតំបន់សហគមន៍ ដែលជាកន្លែងស្វែងរកអាហារ និងចិញ្ចឹមសត្វ។ នៅក្នុងប្រទេសឡាវ និងកម្ពុជា ប្រជាជនជាង ៨០% រស់នៅ និងពឹងផ្អែកលើធនធានពីតំបន់នោះដើម្បីចិញ្ចឹមជីវិត។ ខណៈដែលតម្លៃម្ហូបអាហារកើនឡើង អ្នកភូមិជាច្រើនដែលបាត់បង់ដីស្រែចំការរបស់ពួកគេ បានទទួរងនូវការឈឺចាប់ និងភាពក្រីក្រ។ អ្នកដែលបាត់បង់ដីធ្លី ជារឿយ១បានក្លាយទៅជាអ្នកដែលពឹងអាស្រ័យទៅនឹងការធ្វើការងារឱ្យក្រុមហ៊ុនចំការឈើដាំ ប៉ុន្តែការងារពេញម៉ោង ទំនងជាបានតែចំពោះ

ក្រុមមនុស្សមួយចំនួនតូចតែប៉ុណ្ណោះ ជាពិសេសក្រុមក្មេងដែលមានកាយសម្បទាមាំមួន ដែលចំនុចនេះបានបន្សល់ឱ្យសមាជិកគ្រួសារផ្សេងទៀតអត់មានការងារធ្វើ។ ប្រាក់ចំណូលបានមកពីការប្រើប្រាស់កំលាំងពលកម្មជាមួយក្រុមហ៊ុនមិនគ្រប់គ្រាន់ដើម្បីចិញ្ចឹមគ្រួសារដែលបាត់បង់ដីធ្លីទាំងអស់នោះបានទេ។

ក្នុងបរិបទនៃភាពផ្សេងគ្នាផ្នែកនយោបាយ និងសេដ្ឋកិច្ចដ៏ស្មុគស្មាញ ក្នុងចំណោមប្រទេសនៅតំបន់ទីជំរាលទន្លេមេគង្គ តួរអង្គសង្គមស៊ីវិល ស្ទើរតែមិនមានចន្លោះប្រហោងណាមួយ ដើម្បីដើរតួរនាទីជាសាធារណៈរបស់ពួកគេបាន។ ដែនកំណត់ផ្នែកនយោបាយ និងទំនាក់ទំនងក្នុងប្រទេសឡាវ និងកម្ពុជា បានធ្វើឱ្យមានការលំបាកដល់ការពិភាក្សាជាសាធារណៈ ចំណែកឯការគាបសង្កត់ដ៏ឃោរឃៅនៅក្នុងប្រទេសភូមា បានរារាំងដល់ការបញ្ចេញមតិ ឬយោបល់ជាសាធារណៈ។ ក្នុងចំណោមប្រទេសដែលមានសេដ្ឋកិច្ចខ្ពស់ និងអំណាចផ្នែកនយោបាយ ដូចជាប្រទេសចិន វៀតណាម និងថៃ មើលទៅស្រដៀងគ្នា បើទោះបីជាមានប្រទេសខ្លះ ដូចជាប្រទេសថៃ បានបើចំហរសម្រាប់អង្គការសង្គមស៊ីវិលយ៉ាងណាក៏ដោយ។ មេដឹកនាំសង្គមស៊ីវិលជាច្រើន ព្រមទាំងប្រជាជនដែលរស់នៅក្នុងសង្គមទូលាយជាងនេះ នៅតែមិនមានចំណាប់អារម្មណ៏សមល្មម ឬការយល់ដឹងអំពីផលប៉ះពាល់នៃការឆ្លងកាត់ព្រំដែន ដើម្បីស្វែងប្រាក់ចំណូលរបស់វិនិយោគិនជាតិនៅតាមប្រទេសជិតខាង។

**ដោយ :** Pornpana Kuaycharoen, TERRA

**អ៊ីមែល :** pornpana@terraper.org

**សម្រាប់ព័ត៏មានបន្ថែមអំពីចំការឈើផាំនៅក្នុងតំបន់ សូមមើលទំព័រ "ចំការឈើផាំទន្លេមេគង្គ" តាមរយៈគេហទំព័រ** www.terraper.org

**ធនាគារអភិវឌ្ឍន៍អាស៊ី កំពុងបំផ្លាញព្រៃតំបន់ទន្លេមេគង្គ និងអាកាសធាតុរបស់ផែនដី**

នៅវេលាព្រឹក នៅខាងក្រៅសន្និសិទស្តីពីការប្រែប្រួលអាកាសធាតុក្នុងទីក្រុង Poznan មិត្តភក្រ្តជាច្រើនរបស់ភពផែនដី បាននាំគ្នាធ្វើបាតុកម្មមួយប្រឆាំងទល់នឹងធនាគារពិភពលោក ដែលបានគាំទ្រផ្តល់មូលនិធិដើម្បីដំណើរការរោងចក្រថាមពលដើរដោយធ្យូងថ្ម។ ឥស្សរជនធនាគារពិភពលោក ដែលដើរដោយប្រើទំរជើងឈើ និងស្លៀកពាក់ឯកសណ្ឋានខ្មៅ បានវាយប្រហារទៅលើខ្លាឃ្មុំទឹកកក ដោយយកធ្យូងថ្មចោលទៅលើពួកវា។ នរណាម្នាក់នៅខាងក្រោយ បានប្រាប់ខ្ញុំថា "នេះគឺគ្រាន់តែជាឧទាហរណ៍ធម្មតាមួយ ទាក់ទងថាតើអង្គការមិនមែនរដ្ឋាភិបាលរបស់អ៊ឺរ៉ុប មិនព្រមទទួលយកគំនិតនេះយ៉ាងដូចម្តេច"។ វាសរបញ្ជាក់ឱ្យឃើញថា គាត់ជាអ្នកធ្វើការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី នៅនាយកដ្ឋានប្រែប្រួលអាកាសធាតុ។ គាត់បានប្រាប់ខ្ញុំថា ការប្រែប្រួលអាកាសធាតុ នឹងត្រូវសម្រេចនៅក្នុងប្រទេសឥណ្ឌា និងចិន ដែលនៅទីនោះ យើងចាំបាច់ត្រូវបង្កើត "មធ្យោបាយស្អាតក្នុងចំហេះសំណល់ផូស៊ីល"។ ត្រង់ចំនុចនេះ គាត់ចង់មានន័យថាជាការស្តុកទុក និងគ្រប់គ្រងកាបូន ហើយគាត់បានសារភាពថា មកដល់សព្វថ្ងៃនេះ លែងមានបច្ចេកវិទ្យា បែបនេះទៀតហើយ។

ខ្ញុំបានគូសបញ្ជាក់ថា ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី បន្តផ្តល់មូលនិធិដល់រោងចក្រថាមពលដើរដោយធ្យូងថ្ម ដោយស្នើឡើងថា ខ្លួនជាធនាគារ មិនមែនជាអង្គការមិនមែនរដ្ឋាភិបាលទេ ដែលមិនត្រូវទទួលយកគំនិតបែបនេះ។ គាត់បាននិយាយថា ឆ្នាំមុនធនាគារអភិវឌ្ឍន៍អាស៊ី បានព្រមព្រៀងផ្តល់ប្រាក់កំចីចំនួន ៩00 លានដុល្លាអាមេរិក សម្រាប់ដំណើរការរោងចក្រថាមពលដើរដោយធ្យូងថ្មនៅប្រទេសវៀតណាម។ គាត់និយាយទៀតថា "ខ្ញុំប្រហែលជាមានលក្ខណៈរិះគន់ចំពោះធនាគារអភិវឌ្ឍន៍អាស៊ីច្រើនជាងអ្នក"។

ចំនុចផ្តោតសំខាន់នៃការពិភាក្សានៅទីក្រុង Poznan ពាក់ព័ន្ធនឹងព្រៃឈើ និងតួនាទីរបស់វានៅក្នុងការដោះស្រាយវិបត្តិប្រែប្រួលអាកាសធាតុ។ ធនាគារ សាជីវកម្ម អ្នកផ្តល់ហិរញ្ញបទាន រដ្ឋាភិបាល និងភ្នាក់ងារអង្គការសហប្រជាជាតិ ដែលចាប់អារម្មណ៍អំពីលក្ខណៈរបស់ព្រៃឈើ ដែលអាចជួយសង្គ្រោះភពផែនដីបាននោះ ធ្លាប់បានដើរតួនាទីយ៉ាងធំធេងក្នុងការបំផ្លាញព្រៃឈើ ប៉ុន្តែឥឡូវនេះ ពួកគេទាមទាចង់ថែរក្សាព្រៃទាំងនោះឡើងវិញ។

នៅមុនឆ្នាំនេះ ក្រុមការងារអនុតំបន់ទន្លេមេគង្គស្តីពីបរិស្ថាន បានផលិតខ្សែវីដេអូមួយ ដោយមានការគាំទ្រមូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី។ ខ្សែវីដេអូដែលមានចំណងជើង "ព្រៃឈើដើម្បីអនាគត" នេះ ពន្យល់ថាចំហេះសំណល់ផូស៊ីល គឺមិនមែនជាមូលហេតុតែមួយគត់ ដែលធ្វើឱ្យកាបូនត្រូវរំភាយទៅកាន់បរិយាកាស : "ព្រៃឈើដ៏មានតំលៃ ត្រូវបានផ្តួលរំលំដើម្បីយកសាច់ឈើ និងធ្វើក្រដាស់ ដើម្បីចិញ្ចឹមសត្វ និងធ្វើកសិដ្ឋាន និងដើម្បីចំការឈើដាំដើម្បីផ្គត់ផ្គង់តម្រូវការថាមពលដែលកំពុងកើនឡើង"។ ប្រសិនបើយើងមិនច្បាស់អំពីសមត្ថភាព និងបទពិសោធន៍

ផ្នែកគំរោងបែតងរបស់ធនាគាអភិវឌ្ឍន៍អាស៊ីនោះទេ សន្និសិទសារព័ត៌មានរបស់ធនាគារនេះ បានប្រាប់យើងថា "ព្រៃឈើដើរតួនាទីប្រៀបបានជាសួតរបស់ភពផែនដីរបស់យើង ហើយអាចស្តុកទុកនូវសារធាតុកាបូន ដែលត្រូវរំភាយចេញទៅបរិយាកាសនៅថ្ងៃនេះ"។

ទោះបីយ៉ាងណាក៏ដោយ ប្រាក់កំចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើព្រៃឈើក្នុងតំបន់ទន្លេមេគង្គ ដែលបានរួញខ្មែញមកត្រឹម ៦៨,០០០ គីឡូម៉ែត្រក្រឡា នៅចន្លោះឆ្នាំ១៩៩៩ដល់ឆ្នាំ២០០០។ ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់មូលនិធិសាងសង់ផ្លូវ ដែលបើកច្រកទៅកាន់តំបន់ព្រៃ និងជួយសម្របសម្រួលការនាំឈើចេញ។ ឧទាហរណ៍ ផ្លូវលេខ៩ដែលតភ្ជាប់ពីកំពង់ផែ **ឌុង ហា** ប្រទេសវៀតណាមទៅកាន់ខេត្តសុវណ្ណាខេតប្រទេសឡាវ គឺជាផ្លូវតែមួយគត់ដែលប្រើប្រាស់ដោយក្រុមហ៊ុនកាប់ឈើរបស់ប្រទេសវៀតណាម ដើម្បីនាំឈើចេញពីប្រទេសឡាវ ដែលភាគច្រើនក្នុងលក្ខណៈខុសច្បាប់។ ផ្លូវនេះ ឆ្លងកាត់ជិតតំបន់អភិរក្សជីវៈចំរុះជាតិចំនួនពីរ។ មុនព្រមព្រៀងផ្តល់មូលនិធិដល់គំរោងនេះ ធនាគារអភិវឌ្ឍន៍អាស៊ី ក៏ទទួលស្គាល់ថា ផ្លូវនេះនឹង "**ជុំរុញឱ្យមានការរត់ពន្ធសត្វព្រៃ និងកានាំឈើចេញខុសច្បាប់រឹតតែធ្ងន់ធ្ងរ**"។

ចំការឈើដាំ ជាប្រភេទមួយផ្សេងទៀតនៃការបំផ្លាញព្រៃឈើ ដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ី។ នៅក្នុងប្រទេសឡាវ ធនាគារនេះទទួលស្គាល់ថា គំរោងចំការឈើដាំលក្ខណៈឧស្សាហកម្មរបស់ខ្លួន បានបង្កើតនិងបង្កើនភាពក្រីក្រ។ នៅក្រោមគំរោងនេះ ចំការដំណាំប្រេងខ្យល់ត្រូវដាក់ជំនួសព្រៃឈើ ដែលមានសារៈប្រយោជន៍ដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។ របាយការណ៍ដែលផលិតឡើងសម្រាប់ធនាគារនេះ ទទួលស្គាល់ផងដែរថា "ការបង្កើតចំការឈើដាំ មិនអាចដូចគ្នានឹងការថែរក្សាបរិស្ថានទេ" ហើយដោយសារគំរោងនេះ "ព្រៃឈើដ៏ល្អ" ត្រូវបានប្រែក្លាយទៅជាចំការឈើដាំ។

ដោយមិនចាប់អារម្មណ៏ ធនាគារអភិវឌ្ឍន៍អាស៊ី មានគំរោងអនុវត្តគំរោងចំការឈើដាំមួយផ្សេងទៀតនៅក្នុងប្រទេសឡាវ ដែលចុងក្រោយត្រូវបានលុបចោល ដោយសារតែបញ្ហាចំការឈើដាំលក្ខណៈឧស្សាហកម្មនៅប្រទេសនេះបានក្លាយទៅជាបញ្ហាដ៏ចំរូងចំរាស់ ហើយធនាគារនេះក៏ដឹងផងដែរថា ខ្លួនកំពុងត្រូវបានគេឃ្លាំមើលយ៉ាងជិតដល់ពីសំណាក់អង្គការក្នុងប្រទេសឡាវ និងអន្តរជាតិ។

នៅក្នុងប្រទេសវៀតណាម ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្តល់ប្រាក់កំចីចំនួន ៣៣ លានដុល្លាអាមេរិក ដើម្បីអនុវត្តគំរោងមួយដែលសំដៅស្តារឡើងវិញនូវព្រៃឈើដែលទទួលរងខូចខាត។ ជាញឹកញយ ការពិតនៅក្នុងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាល និងធនាគារអភិវឌ្ឍន៍អាស៊ី កសិករត្រូវបានស្តីបន្ទោសថាបានបំផ្លាញព្រៃឈើ ចំណែកឯប្រវត្តិសាស្ត្រនៃការកាប់ឈើហ៊ុបធំៗ និងគំរោងអភិវឌ្ឍន៍បំផ្លាញផ្សេងៗទៀត ត្រូវបានក្លែងថាជាបញ្ហាមិនសំខាន់

និងមិនអើពើទាំងស្រុង។ ជាការពិត យោងតាមឯកសារគំរោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី គំរោងនេះសំដៅកាត់បន្ថយការអនុវត្តការដាំដុះបែបពនេចរ ដែលប៉ះពាល់ដល់ព្រៃឈើ។

ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាអ្នកផ្តល់មូលនិធិដ៏ធំចំពោះកម្មវិធី **"ដាំដើមឈើឡើងវិញ"** លើផ្ទៃដីសរុបចំនួន ៥លានហិកតានៅប្រទេសវៀតណាម ដោយរាប់បញ្ចូលទាំងចំការឈើដាំលក្ខណៈឧស្សាហកម្ម លើផ្ទៃដី១លានហិកតា ដើម្បីផ្គត់ផ្គង់ដល់រោងចក្រផលិតក្រដាស់។ គំរោងដែលផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ីមួយទៀត ដែលមានឈ្មោះថា "ព្រៃឈើដើម្បីធ្វើឱ្យជីវភាពរស់នៅមានភាពប្រសើ នៅតំបន់ខ្ពង់រាបភាគកណ្តាល" រួមមានផ្ទៃដីសរុបចំនួន ៣០,០០០ ហិកតា សម្រាប់ដំណើរការ **"ចំការឈើដាំដែលផ្តល់ទិន្នផលខ្ពស់"** ដែលអាចហៅម្យ៉ាងទៀតថា ឯកវប្បកម្មលក្ខណៈឧស្សាហកម្ម។

ជាផ្នែកមួយនៃតំបន់នាំចេញពិសេស នៅតាមបណ្តោយព្រំដែនវៀតណាម-ឡាវ ធនាគារអភិវឌ្ឍន៍អាស៊ីកំពុងគិតពិចារណាផ្តល់មូលនិធិដល់រោងចក្រកែច្នៃឈើនៅ **ឡាវ បាវ**។ រោងចក្រនេះ នឹងទិញឈើរបស់ចំការដំណាំអាកាស្យា និងប្រេងខ្យល់ពីប្រទេសឡាវ និងវៀតណាមដើម្បីផលិត "គ្រឿងសង្ហារឹមដ៏មានតំលៃថោក កំទេចកំទីឈើ និងសម្ភារៈសាងសង់ផ្សេងៗ"។ ឯកសារគំរោងរបស់ធនាគារនេះ បានកត់ចំណាំថា **"បច្ចុប្បន្ននេះ មានការព្រួយបារម្ភខ្លះៗអំពីកំនើនចំការដំណាំឯកវប្បកម្មនៅក្នុងប្រទេសវៀតណាម"**។ ជាការពិត ឯកសារនេះមិនមានការនិយាយអំពីតួនាទីរបស់ធនាគារនៅក្នុងការជុំរុញចំការដំណាំឯកវប្បកម្មទាំងនេះទេ។

វាហាក់ដូចជាមិនសូវទំនងសោះដែលថា ផលចំណេញតិចតួច នឹងកើតចេញពីកិច្ចចចារពីអាកាសធាតុនៅទីក្រុង Poznan គឺថាតើវាសម្រាប់ប្រជាជន ព្រៃឈើ ឬក៏អាកាសធាតុ។ អង្គការសហប្រជាជាតិ ភាន់ច្រឡំក្នុងការញែក រវាងពាក្យចំការឈើដាំ និងព្រៃឈើ។ នេះមានន័យថា មូលនិធិដែលផ្តល់ដោយធនាគារអភិវឌ្ឍន៍អាស៊ីសំរាប់កាប់ព្រៃឈើដើម្បីត្រួសត្រាយផ្លូវសម្រាប់ចំការឈើដាំ អាចត្រូវបានដាក់បញ្ចូលក្រោមកម្មវិធី កាត់បន្ថយការរំភាយចេញពីការខូចខាត និងកាប់បំផ្លាញព្រៃឈើ។ ជាការពិត ធនាគារអភិវឌ្ឍន៍អាស៊ី នឹងមិនធ្វើការតវ៉ាអ្វីឡើយ។

**ដោយ :** Chris Lang,

**អ៊ីមែល :** http://chrislang.org

## ចំការឈើដាំនៅក្នុងតំបន់ទន្លេមេគង្គ : តាមប្រទេសមួយៗ

### ប្រទេសភូមា : យុទ្ធនាការដាំដំណាំល្ហុងខ្វងដោយកំលាំងពលកម្មដោយបង្ខំពិយោធា

នៅក្នុងខែធ្នូ ឆ្នាំ២០០៥ ឧត្តមសេនីយជាន់ខ្ពស់របស់ប្រទេសភូមា លោក ថាន់ ស្វេ បានបញ្ជាឱ្យចាប់ផ្តើមយុទ្ធនាការដាំដំណាំល្ហុងខ្វងទូទាំងប្រទេស ដើម្បីផលិតជីវម៉ាស៊ូត។ ប្រទេសនេះ ត្រូវដាំលើផ្ទៃដី ៨លាន អេឃើ (៣.២ លាន ហិកតា) ឬតំបន់មួយដែលមានទំហំប៉ុនប្រទេសប៊ែលសិច ក្នុងរយះពេលបីឆ្នាំ។ រដ្ឋ ឬតំបន់នីមួយៗរបស់ប្រទេសនេះ ដោយមិនគិតពីទំហំ ត្រូវរំពឹងថាដាំដំណាំនេះយ៉ាងហោចណាស់លើផ្ទៃដី ៥០០,០០០ អេឃើ។ នៅក្នុងតំបន់ក្រុងរ៉ង់គុន ២០%នៃដីដែលអាចដាំបាន សុទ្ធតែគ្របដណ្តប់ដោយដំណាំល្ហុងខ្វង។

ការផ្ទុះឡើងនាពេលថ្មីៗនេះ ទាក់ទងនឹងការកើនឡើងនៃតំលៃប្រេង ការរក្សាទុកដ៏ស្តួចស្តើងនៃសំណល់ផូស៊ីល និងការព្រួយបារម្ភផ្សេងៗជុំវិញការរំភាយឧស្ម័នផ្ទះកញ្ចក់ ដែលអាចប៉ះពាល់ដល់ការប្រែប្រួលអាកាសធាតុនោះ បានជំរុញដល់ឧស្សាហកម្មជីវថាមពលដែលកំពុងតែដុះពន្លក។ ការផលិតជីវថាមពលទូទាំងពិភពលោក — ថាមពលបានពីជីវម៉ាស់ ឬរុក្ខជាតិ -បានកើនឡើងទ្វេរកាលពីប្រាំឆ្នាំមុន ហើយគេរំពឹងថានឹងអាចកើងឡើងទ្វេរម្តងទៀត ក្នុងរយះពេលបួនឆ្នាំទៀត។

កម្មវិធីថ្មី និងទំនងមានប្រសិទ្ធិភាពមួយ ត្រូវបានចាប់ដំណើរការនៅក្នុងប្រទេសភូមាដើម្បីដាំដំណាំល្ហុងខ្វង បើទោះបីជាមានកង្វល់ពីអន្តរជាតិអំពីផលប៉ះពាល់អវិជ្ជមានពីការផលិតជីវថាមពលយ៉ាងណាក៏ដោយ ជាពិសេសនៅពេលដែលត្រូវបានអនុវត្តន៏យ៉ាងគង្គុក និងក្នុងក៏រិតមួយយ៉ាងធំ។

ដំណាំល្ហុងខ្វង ជាប្រភេទដំណាំដែលមានទំហំតូច ឬចុល្លព្រឹក នៅក្នុងគ្រួសារ Euphorbiaceae។ ដំណាំល្ហុងខ្វង មានប្រភពមកពីប្រទេស ម៉ិចស៊ីកូ និងអាមេរិកភាគកណ្តាល ប៉ុន្តែបានរីករាលដាលទូទាំងពិភពលោក ហើយត្រូវបានប្រើប្រាស់ភាគច្រើនជារបងដើម្បីការពារដំណាំពីការបំផ្លាញរបស់សត្វពាហនៈ។ ដំណាំនេះ អាចដុះលូលាស់រហូតដល់ប្រាំមួយម៉ែត្រក្នុងលក្ខ័ខណ្ឌប្រកប គឺវាមានដើមត្រង់ មានមែកយ៉ាងក្រាស់ និងមានស្លឹកពណ៌បៃតង។ វាត្រូវបានគេហៅថាជា "ប្រភេទរុក្ខជាតិជីវម៉ាស៊ូត" ដោយសារតែវាអាចផលិតជីវម៉ាស៊ូតចេញពីប្រេងនៅក្នុងគ្រាប់របស់ផ្លែរបស់វា។ គ្រាប់ដំណាំល្ហុងខ្វង អាចផ្តល់ជីវម៉ាស៊ូតបានច្រើនជាងប្រភេទជីវថាមពលផ្សេងទៀត នៅក្នុងមួយហិកតា ខណៈដែលប្រេងរបស់វា អាចជួយកាត់បន្ថយរំភាយកាបូនទៅបរិយាកាសរហូតដល់ទៅ ១/៥ នៃរំភាយកាបូនចេញពីសំណល់ផូស៊ីល។

ចាប់តាំងពីឆ្នាំ២០០៦មក គ្រប់វិស័យទាំងអស់របស់ប្រទេសភូមា ត្រូវបានបង្ខំឱ្យបង្វែថវិកា ដីកសិដ្ឋាន និងកំលាំពលកម្មរបស់ខ្លួនដើម្បីដាំដំណាំល្ហុងខ្វង។ លោកគ្រូ/អ្នកគ្រូ សិស្សសាលា កសិករ គិលានុបដ្ឋាយិកា និងបុគ្គលិកមន្ត្រីរាជការ ត្រូវបានដាក់កំហិតឱ្យចំណាយពេលធ្វើការងាររបសពួកគេទៅដាំដំណាំល្ហុងខ្វងនៅតាមដងផ្លូវ នៅតាមសាលារៀន មន្ទីរពេទ្យ ការិយាល័យ តំបន់សាសនា និងនៅលើដីកសិដ្ឋានដែលធ្លាប់ធ្វើស្រែចំការ។

គិលានុបដ្ឋាយិកាម្នាក់មកពីរដ្ឋកាជីន (Kachin) បាននិយាយថា *"គ្រប់និយោជិកមន្ទីរពេទ្យតម្រូវឱ្យដាំដំណាំល្ហុងខ្វង។ យើងបានចេញទៅក្រៅដើម្បីដកស្មៅពេញមួយថ្ងៃ។ ពួកយើងម្នាក់ៗត្រូវគេរំពឹងថា នឹងដាំដំណាំល្ហុងខ្វងក្នុងចំនួន ៥០០ គ្រាប់ ប៉ុន្តែគ្មាននរណាម្នាក់អាចធ្វើបាននៅក្នុងចំនួនដ៏ច្រើនបែបនោះឡើយ"*។

និស្សិតម្នាក់មកពីរដ្ឋកាជីន (Kachin) បាននិយាយថា *"ពួកយើងទាំងអស់គ្នា ដែលរៀនពីថ្នាក់ទី៥ដល់ថ្នាក់ទី៩ ត្រូវបណ្តុះគ្រាប់នៅក្នុងបរិវេណសាលារៀន និងកីឡាដ្ឋានបាល់ទាត់។ គ្រូបង្រៀនយើងបានប្រាប់ថា ទាំងនេះគឺជាបញ្ជាមកពីចាងហ្វាងសាលា"*។

កសិករម្នាក់មកពីរដ្ឋការិនធី (Karenni) បាននិយាយថា *"ប្អូនស្រីរបស់ខ្ញុំ គឺជាគ្រូបង្រៀន។ នាងត្រូវតែដាំដំណាំនេះ ហើយបន្ទាប់មកត្រូវសរសេររបាយការណ៍ពីភាពរីកចំរើនរៀងរាល់ខែ។ ស្ថិតិជាបញ្ហាឈឺក្បាលសម្រាប់នាង និងគ្រូបង្រៀនរបស់នាង។ អាជ្ញាធរដែនដីបានប្រាប់ពួកគេថា ពួកគេនឹងមិនទទួលបានប្រាក់ខែ ប្រសិនបើចំការឈើដាំមិនទទួលបានជោគជ័យ"*។

ការសិក្សាស្រាវជ្រាវមួយចេញពីខ័ណ្ឌ/ស្រុកចំនួន៣២កន្លែង នៅក្នុងរដ្ឋនីមួយៗរបស់ប្រទេសភូមា ដែលរួមមាន១៣១សម្ភាសន៍ជាមួយកសិករ មន្ត្រីរាជការ និងវិនិយោគិន បានលាតត្រដាងអំពីលក្ខណៈដែលប្រជាជនត្រូវទទួលរងការផាកពិន័យ ចាប់ខ្លួន និងគំរាមកំហែងដល់អាយុជីវិត ពីបទមិនបំពេញតាមកូតា ការធ្វើឱ្យខូចខាតដល់ដំណាំល្ហុងខ្វង ឬការរិះគន់ទៅលើកម្មវិធីនេះ។ លទ្ធផលមួយ ទាក់ទងនឹងការទាមទារដីកសិដ្ឋាន និងកំលាំងពលកម្មដ៏ហួសហេតុ គឺជាបាតុភូតថ្មីដែលនាំឱ្យមាន **"ជនភៀសខ្លួន"** ដែលក្នុងនោះមនុស្សជិត៨០០នាក់ បានរត់ភៀសខ្លួនចេញពីរដ្ឋស្យានភាគ ខាងត្បូងទៅកាន់ប្រទេសថៃដែលនៅក្បែរខាង។

មេភូមិម្នាក់មកពីរដ្ឋស្យាន (Shan) បាននិយាយថា *"នៅឆ្នាំ២០០៤ ភូមិរបស់ខ្ញុំមានមនុស្ស*

*ជាង៨០០នាក់ ស្មើនឹង២៤០គ្រួសារ។ ឥឡូវនេះ នៅក្នុងភូមិរបស់ខ្ញុំ មានអ្នកភូមិត្រឹមតែ១៣០ នាក់ប៉ុណ្ណោះ ដែលស្មើនឹង៤០គ្រួសារ។ ចាប់តាំងពីឆ្នាំ២០០៤មក ៨០%នៃប្រជាជនរបស់ភូមិរបស់ខ្ញុំ បានរត់ចូលទៅក្នុងប្រទេសថៃដោយសារតែក្រុមប្រឹក្សាអភិវឌ្ឍន៍ និងសន្តិភាពរដ្ឋ (SPDC)"។*

ដំណាំនេះ អាចដុះលូតលាស់នៅលើដីដែលមិនសូវមានជីជាតិ ដូចនេះការដាំដំណាំនេះ មិនប៉ះពាល់ដល់ការដុះលូតលាស់របស់ដំណាំអាហារផ្សេងទៀតឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តយុទ្ធនាការណ៏ក្នុងប្រទេសភូមា កំពុងគំរាមកំហែងដល់សន្តិសុខស្បៀងរបស់កសិករ។ ទីមួយ ដំណាំល្ហុងខ្វង ត្រូវដាំនៅលើដីកសិដ្ឋានដែលមានស្រាប់ និងនៅក្នុងសួនដំណាំក្នុងផ្ទះ ដែលត្រូវប្រកួតប្រជែងដោយផ្ទាល់ជាមួយពពួកដំណាំអាហារ ពិសេសទាក់ទងនឹងជីវជាតិរបស់ដី និងប្រភពទឹកស្រោចស្រព។ ទីពីរ ការរឹបអូស និងការប្រើប្រាស់ដីធ្លីនៅជិតមណ្ឌលប្រជាជន បានបង្ខំឱ្យកសិករស្វែងរកតំបន់ដាំដុះបន្ថែមទៀត ដែលធ្វើឱ្យធ្លាក់ចុះដល់ផលិតភាព និងជាការដាក់សំពាធថ្មីមួយទៅលើបរិស្ថាន។ ទីបី ដោយសារតែតម្រូវការឱ្យកសិករចេញពីដីស្រែចំការរបស់ពួកគេ ដើម្បីបង្កើត និងថែរក្សាដំណាំល្ហុងខ្វង កសិករទាំងនោះ មានពេលវេលាតិចតួចបំផុតដើម្បីមើលថែរក្សាដំណាំអាហារផ្ទាល់របស់ពួកគេ។ កសិករខ្លះ បានរាយការណ៏ថា ដំណាំផ្សេងទៀតដែលដុះជិតដំណាំល្ហុងខ្វង មិនអាចដុះលូតលាស់បានល្អទេ។

មន្ត្រីរាជកាម្នាក់មកពីរដ្ឋការីននី (Karenni) បាននិយាយថា *"យើងមាន៤៧ភូមិនៅក្នុងស្រុករបស់យើង។ គ្រប់ភូមិនីមួយៗ គ្រួសារត្រូវតែដាំដំណាំល្ហុងខ្វងយ៉ាងហោចណាស់ឱ្យបាន ៥អេឃើ (១អេឃើ= ៤,០៥០ ម៉ែត្រការេ) ដូចនេះពួកគេត្រូវបាត់បង់មួយផ្នែកនៃដីស្រែចំការរបស់ពួកគេ។*

អ្នកភូមិនៅទូទាំងប្រទេសភូមា ត្រូវបានបង្ខំឱ្យ "ចូលរួមចំណែកកំលាំងពលកម្មស្មគ្រចិត្ត" ដើម្បីចំការល្ហុងខ្វងផ្អែកតាមមូលដ្ឋាន មនុស្សម្នាក់-មួយគ្រួសារ។ ពួកគេត្រូវតែយកអាហារ និងឧបករណ៏របស់ពួកគេមកជាមួយនៅពេលថ្ងៃ និងត្រូវប្រឈមមុខទល់នឹងសកម្មភាពបង្ក្រាបបំពាន ប្រសិនបើបដិសេធមិនព្រមទៅ។ ភាគច្រើនប្រសិនបើពួកគេមិនបានទៅ ពួកគេត្រូវស្វែងរកនរណាម្នាក់ផ្សេងទៀតឱ្យទៅជំនួស។

កសិករម្នាក់មកពីរដ្ឋមន (Mon) បាននិយាយថា *"ក្នុងភូមិរបស់យើង សមាជិកម្នាក់មកពីគ្រួសារនីមួយៗត្រូវតែទៅ និងដាំដំណាំល្ហុងខ្វង។ មេដឹកនាំសហគមន៍ និយាយថា អ្នកដែលមិនបានទៅ*

*នឹងត្រូវផាកពិន័យ ។ ខ្ញុំត្រូវតែចាកចេញពីកសិដ្ឋានផ្ទាល់របស់ខ្ញុំ ដើម្បីទៅកាន់ទីនោះ ។ ប្រជាជនវ័យចំណាស់មួយចំនួន ដែលមិនអាចទៅបាន ត្រូវតែបញ្ជូនចៅ របស់ពួកគេទៅជំនួស ។ យើងត្រូវតែដាំដំណាំនេះឱ្យត្រង់ជួរ តាមបង្គោលដែលបានដោត ។ មុនដាំ យើងត្រូវតែសំអាតគុម្ពោតព្រៃ និងវល្លិ៍ ដើម្បីឱ្យដីអាចដាំបានល្អ"* ។

កសិករម្នាក់មកពីតំបន់ខ្ពង់រាប រដ្ឋកាជីន (Kachin) បាននិយាយថា *"មេដឹកនាំសហគមន៍បានហៅខ្ញុំ ហើយបាននិយាយថា ពួកគេនឹងផាកពិន័យខ្ញុំចំនួន ៣,០០០ ខ្យាត (២.៥ ដុល្លាអាមេរិក) ក្នុងករណីដែលខ្ញុំត្រូវបានរកឃើញថាមានទោស ។ យើងត្រូវបានគេបង្ខំឱ្យដាំពេញមួយថ្ងៃ ហើយយើងត្រូវតែនាំយកអាហារថ្ងៃត្រង់ពីផ្ទះទៅជាមួយ"* ។ **(សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងការផាកពិន័យ —កំរៃប្រចាំថ្ងៃ ជាមធ្យម១,៥០០ ខ្យាត)**

កំលាំងពលកម្មដែលកើតចេញពីការបង្ខំ ត្រូវបានប្រើប្រាស់មិនសម្រាប់តែដើម្បីដាំដំណាំល្ហុងខ្វងប៉ុណ្ណោះទេ ថែមទាំងដើម្បីសាងសង់រោងចក្រកែច្នៃប្រេងផងដែរ ។ នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៧ កងពលទ័ពជើងគោក ៥២៤ បានកោះហៅប្រជាជនមូលដ្ឋាន ហើយបានបង្ខំពួកគេឱ្យត្រួសត្រាយផ្លូវតាមបណ្តោយមហាវិថី ចន្លោះពីភូមិកាលីទៅកាន់ភូមិតាការ នៅក្នុងរដ្ឋស្សានភាគកណ្តាល សម្រាប់ធ្វើជាកន្លែងសាងសង់រោងចក្រកែច្នៃប្រេង ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកភូមិត្រូវតែផ្តល់ប្រេងសម្រាប់ម៉ាស៊ីនកាត់ស្មៅ ដើម្បីសំអាតទីកន្លែង ។ ទាហ៊ាន មានតួនាទីប្រមូលលុយបន្ថែមសម្រាប់ប្រេង ។

យ៉ាងណាក៏ដោយ អ្នកភូមិកំពុងស្វែងរកមធ្យោបាយធ្វើយ៉ាងណាអាចបញ្ចៀស ឬមិនគោរពតាមបញ្ជា ។ មន្ត្រីរាជការជាន់ខ្ពស់ម្នាក់នៅក្នុងរដ្ឋការីននី បានសារភាពថា ប្រជាជនជាច្រើនបានជំទាស់មិនដាំដំណាំនេះ ។ ប្រជាជនខ្លះបានទិញគ្រាប់ពូជតាមបញ្ជា ប៉ុន្តែក្រោយមកមិនបានដាំទេ ហើយចំណែកអ្នកផ្សេងទៀត បានដាំក្នុងកំរិតមួយតិចជាងតាមការបញ្ជា ។ ក្តារព័ត៌មាន/សញ្ញាដែលជំរុញឱ្យមានការដាំដំណាំល្ហុងខ្វង ត្រូវបានធ្វើឱ្យខូចរូបរាង ។

អ្នកភូមិមួយចំនួន បានយកចំណេញពីការអសមត្ថភាពរបស់អាជ្ញាធរដែនដី ដើម្បីត្រួតពិនិត្យតំបន់ ។ កសិករម្នាក់បានពន្យល់ថា *"ដោយសារតំបន់គោលដៅដាំដុះរបស់យើង មិននៅជិតផ្លូវធំ ប្រជាជនជាច្រើន មិនបានដាំដំណាំល្ហុងខ្វងនេះទេ"* ។ (កសិករមកពីរដ្ឋមន)

កសិកម្មគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមភូមា ។ គោលនយោបាយទាំងឡាយណា ដែលមានឥទ្ធពលដល់វិស័យនេះ គួរតែត្រូវពិចារណាដោយប្រុងប្រយ័ត្ន និងអនុវត្តន៍ឱ្យបានខ្ជាប់ខ្ជួន ។ មេដឹកនាំពិភពលោក និង

អ្នកវិទ្យាសាស្ត្រជាច្រើន កំពុងនិយាយដូចគ្នាពីគំនិតផ្ដួចផ្ដើមនៃជីវថាមពល។ ទោះជាយ៉ាងនេះក្ដី របបផ្ដាច់ការរបស់ប្រទេសភូមា កំពុងតែខិតខំទៅមុខដោយភ្លេចគិតពីគ្រោះថ្នាក់ជាមួយនឹងយុទ្ធនាការដាំដំណាំល្ហុងខ្វង ដែលមិនធ្លាប់មានពីមុនមកសោះ។ មិនគ្រាន់តែយុទ្ធនាការទេដែលបង្ហាញពីភាពបរាជ័យ វាក៏បានបង្ហាញពីការគំរាមកំហែងដល់ជីវភាពរស់នៅរបស់ប្រជាជនផងដែរ។

ដើម្បីឱ្យដឹងច្បាស់អំពីដំណើរការអភិវឌ្ឍន៍ដ៏ប្រសើរជាងនេះ សិទ្ធិគ្រប់គ្រងធនធានធម្មជាតិ និងចូលរួមក្នុងការធ្វើសេចក្ដីសម្រេចចិត្តអំពីគំរោងអភិវឌ្ឍន៍ប្រកបដោយចីរភាព ត្រូវតែធានាឱ្យមានយ៉ាងពិតប្រាកដនៅប្រទេសភូមា។ គោលនយោបាយកសិកម្មប្រកបដោយចីរភាព ចាំបាច់ត្រូវតែបង្កើត ដែលអាចធានាដល់សិទ្ធិកាន់កាប់ដីធ្លី និងសន្តិសុខមនុស្ស ហើយត្រូវអនុញ្ញាតឱ្យសហគមន៍អាចគ្រប់គ្រងធនធានធម្មជាតិផ្ទាល់ខ្លួនរបស់ពួកគេ។ សិទ្ធិស្ត្រី និងជនអន្តោរគ្រាម ក៏ត្រូវតែធានាផងដែរ។

ដោយដកស្រង់ និងកែប្រែពីរបាយការណ៍ "ជីវថាមពលតាមក្រិត។ ការលាតត្រដាងពីភាពបរាជ័យនៃគំរោងជីវថាមពលរបស់ប្រទេសភូមា" ដោយវេទិកាអភិវឌ្ឍន៍សហគមន៍ជនជាតិភាគតិច (ECDF) ដែលចេញផ្សាយនៅក្នុង ខែមិថុនា ឆ្នាំ២០០៨។ អ៊ីមែល : unitededcd@gmail.com ។ របាយការណ៍ពេញលេញ អាចទទួលបានតាមរយៈ គេហទំព័រ : http://www.terraper.org/file_upload/BiofuelbyDecree.pdf ។

## ប្រទេសកម្ពុជា ៖ ចំការឈើដាំឯកវប្បកម្មនាំមកនូវជំលោះដីធ្លី

ដោយសួរប្រជាជនកម្ពុជាថាតើពួកគេចាត់ទុកមូលដ្ឋានគ្រឹះនៃសង្គម និងជីវិតនៅក្នុងប្រទេសកម្ពុជាជាអ្វី ចំលើយគឺជា "ដីធ្លី" ដីធ្លីគឺជីវិត។ ប៉ុន្តែវាមានតំលៃស្មើគ្នាជាវត្ថុមិនចេះសាបសូន្យ កម្មសិទ្ធិ និងស្ថេរភាព និងត្រូវចាត់ទុកយ៉ាងសំបើមថាជា មូលដ្ឋាននៃការរៀបចំសង្គមក្នុងប្រទេស។ អារម្មណ៍ជិតជាប់ទៅនឹងដីរបស់គ្រួសារកម្ពុជាមានសារៈសំខាន់យ៉ាងពិតប្រាកដនៅក្នុងសង្គម ដែលកាលពីរាប់រយឆ្នាំមុន បានបោះពួយចូលទៅក្នុងប្រវត្តិកាល ដែលបន្តគ្នានៃជម្លោះស៊ីវិល សង្គ្រាម ការផ្លាស់លំនៅ ការធ្វើសមូហភាវកម្មដោយបង្ខំនិងប្រល័យពូជសាសន៍ ការធ្លាក់ចូលទៅក្នុងសេដ្ឋកិច្ចមិនទៀងទាត់ សេដ្ឋកិច្ចបែប សង្គមនិយម និងចុងក្រោយសេដ្ឋកិច្ចបែបទីផ្សារ។

ជាង៨០%នៃប្រជាជនក្នុងប្រទេសនេះ រស់នៅតាមទីជនបទ។ ដែនដីកម្ពុជា អំណោយផលដល់ការដាំដុះបែបពនេចរ និងនៅមួយកន្លែង ហើយទោះការដាំដុះនោះស្ថិតក្នុងលក្ខណៈណាក៏ដោយ សហគមន៍ជនបទ ពឹងផ្អែកយ៉ាងខ្លាំងទៅលើព្រៃឈើដែលនៅជុំវិញ ព្រៃឈើនិងប្រព័ន្ធផ្តល់ទឹកមួយចំនួន ដែលជាប្រភពផ្តល់អាហារ និងអនុផលព្រៃឈើសម្រាប់ធ្វើជាប្រាក់ចំណូល និងប្រើប្រាស់ក្នុងគ្រួសារ។ អ្នកក្រីក្របំផុតនៅក្នុងភូមិ ជាទូទៅគឺជាអ្នកដែលគ្មានដីធ្លី ហើយជាការពិត ការគ្មានដីធ្វើកសិកម្ម ឬមធ្យោបាយទិញដី អាចត្រូវបានចាត់ទុកថាជាសូចនាករភាពក្រីក្រដ៏សុក្រិតមួយនៅក្នុងប្រទេសកម្ពុជា។

នៅក្នុងទសវត្សទី៦០ គេប៉ាន់ប្រមាណថា ៧៣%នៃដែនដីរបស់ប្រទេសកម្ពុជា គ្របដណ្តប់ដោយព្រៃឈើ ចំនែកសហគមន៍ជនបទ អាចកាប់ព្រៃឈើបានតាមបំណងដើម្បីពង្រីកដីស្រែចំការ ដោយមិនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ប្រព័ន្ធអេកូឡូស៊ីឡើយ។ ដីធ្លីមិនត្រូវបានធ្វើអាជីវកម្មឡើយ គឺមិនមានទីផ្សារដីធ្លីផ្លូវការណាមួយ ហើយអ្នកដែលប្រើប្រាស់ដីធ្លី យល់យ៉ាងច្បាស់ពីកម្មសិទ្ធិ និងការគ្រប់គ្រងដីធ្លី។ នៅក្នុងទសវត្សទី៩០ ប្រទេសកម្ពុជា ត្រូវបានទម្លាក់ចូលទៅក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរី របបអចលទ្រព្យឯកជន ចាប់ផ្តើមយល់បានច្បាស់អំពីកម្មសិទ្ធិ និងការប្រើប្រាស់ដីធ្លី និងទីផ្សារដីធ្លីដែលមិនមានច្បាប់ទម្លាប់ត្រឹមត្រូវ ចាប់ផ្តើមរីកដុះដាល។

ភាពគ្មានដីធ្លី និងវិសមភាពនៅក្នុងការកាន់កាប់ដីធ្លី កំពុងរីកលូតលាស់យ៉ាងគង្ហុកនៅក្នុងប្រទេសកម្ពុជា ក្នុងចំណោមសហគមន៍តាមទីជនបទ និងប្រជុំជន។ ភាពគ្មានដីធ្លីនេះ មានក្នុងចំណោមគ្រួសារដែលដឹកនាំដោយស្ត្រីច្រើនជាងគ្រួសារដែលដឹកនាំដោយបុរស។ ស្រដៀងគ្នានេះដែរ គឺមានចំនួនកើនឡើងនៃ "អ្នកដែលស្ទើរតែគ្មានដីកាន់កាប់" ដែលជាគ្រួសារមានដីធ្លីតិចតួចបំផុតដើម្បីត្រដរស់។ ជាងមួយទសវត្សមកនេះ តំបន់ដីមួយចំនួធំនៅកម្ពុជា ត្រូវបានប្រគល់ឱ្យក្រុមហ៊ុនឯកជនក្នុងលក្ខណៈជាដីសម្បទានសេដ្ឋកិច្ច គឺមានកិច្ចព្រមព្រៀងច្បាស់លាស់រវាងក្រុមហ៊ុន និងរដ្ឋាភិបាលក្នុងការប្រើប្រាស់ដីធ្លីជាលក្ខណៈពាណិជ្ជកម្ម ដោយផ្តោតសំខាន់ទៅលើលក្ខណៈឧស្សាហកម្មនៃព្រៃឈើ

កសិកម្ម រ៉ែ ការរុករកប្រេង ការនេសាទ និងទេសចរណ៍។ ទោះបីជាសម្បទានសេដ្ឋកិច្ច មានប្រភពកំណើតនៅចុងសតវត្សទី១៩ ក្រោមនឹមអាណានិគមនិយមបារាំង (ភាគច្រើនជាប្រភេទចំការកៅស៊ូ) ការលេចរូបរាងសារជាថ្មីឡើងវិញរបស់វា កើតមាននៅដើមទសវត្សទី៩០ដែលនៅពេលនោះ រាជរដ្ឋាភិបាលកម្ពុជា ចាប់ផ្តើមផ្តល់ដី និងព្រៃសម្បទាន ដល់ក្រុមហ៊ុនឯកជន ដើម្បីលើកទឹកចិត្តដល់សហគ្រាសឯកជនទាំងអស់នោះ ឱ្យចូលរួមចំណែកដល់ប្រាក់ ចំណូលរបស់រដ្ឋ និងដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមទីជនបទ។ តាមការប៉ាន់ប្រមាណ នៅចុងទសវត្សទី៩០ ជាង១/៣នៃសហគមន៍ជនបទរបស់ប្រទេសកម្ពុជា នឹងត្រូវបាត់បង់ភាពជាម្ចាស់កម្មសិទ្ធិលើដីធ្លីរបស់ពួកគេ ដោយសារតែ ដីសម្បទាន និងព្រៃសម្បទាន។

សម្បទានសេដ្ឋកិច្ចរួមមាន ចំការឈើដាំលក្ខណៈឧស្សាហកម្មនៃដំណាំកៅស៊ូ ស្រល់ អាកាស្យា ដូងប្រេង មៃស័ក និងប្រេងខ្យល់ និងផលិតកម្មកសិឧស្សាហកម្មនៃដំណាំសេដ្ឋកិច្ចផ្សេងទៀត។ ពួកគេបានផ្តល់សិទ្ធិគ្រប់គ្រងដីសម្បទានផ្តាច់មុខដល់វិនិយោគិនរហូតដល់៩៩ឆ្នាំ។ នៅតំបន់ខ្លះ សហគមន៍ត្រូវបានជន្លៀសចេញដើម្បីត្រួសត្រាយផ្លូវសម្រាប់ចំការឈើដាំ ហើយក្រុមហ៊ុនបានប្រើគ្រឿងចាក់ឈូសឆាយព្រៃឈើ ដែលសហគមន៍ធ្លាប់ពឹងអាស្រ័យដើម្បីជីវភាពរស់នៅ។ អ្នកភូមិដែលរស់នៅចំតំបន់សម្បទាននៅក្នុងខេត្តក្រចេះ ស្ទឹងត្រែង និងមណ្ឌលគីរី (ក្នុងចំណោមអ្នកផ្សេងទៀត) បានរាយការណ៍ថា ពួកគេមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ព្រៃឈើឡើយ ហើយតំបន់ដីហាមឃាត់ទៀតសោត ឥឡូវនេះត្រូវស្ថិតនៅក្នុងដីសម្បទាន ទោះបីជាការពិតដែលថា ដីទាំងនេះបានស្ថិតនៅក្រោមការមើលថែរក្សារបស់ពួកគេជាច្រើនជំនាន់ហើយក៏ដោយ ដែលធ្លាប់ជាតំបន់អារក្សអ្នកតា និងជាតំបន់នៃប្រភពអាហារ និងប្រាក់ចំណូលដ៏សំខាន់សម្រាប់ពួកគេ។ សហគមន៍ដែលស្ថិតនៅចំតំបន់សម្បទាន ក៏បានរាយការណ៍ផងដែរថា ក្រុមហ៊ុនបានល្មើសពង្រីកតំបន់ដីធ្លីដែលមានចែងនៅក្នុងកិច្ចសន្យា ព្រមទាំងទន្ទ្រានកាន់កាប់ដីធ្លី និងទ្រព្យសម្បត្តិនៅក្នុងភូមិថែមទៀត។

ចំការឈើដាំ គឺជាឯកវប្បកម្មនៃប្រភេទដំណាំ ឬដើមឈើណាមួយ ហើយការដាំម្តងហើយម្តងទៀតនៃប្រភេទដំណាំដដែលៗក្នុងវដ្តជីវិតបិតជិតមួយ ត្រូវការការប្រើប្រាស់ចំរុះនូវជីគីមី ថ្នាំសំលាប់សត្វល្អិត និងស្មៅចង្រៃដែលត្រូវច្រោះចូលទៅក្នុងដី និងទឹកក្រោមដី ដែលកាត់បន្ថយដល់ជីវជាតិដីនៅជុំវិញ ធ្វើឱ្យដីពុល និងនាំទៅរកការកើត ជម្ងឺក្នុងចំណោមអ្នកភូមិ។ ចំការឈើដាំប្រភេទដើមប្រេងខ្យល់ អាចធ្វើឱ្យដីស្ងួត បំផ្លាញសំណើម និងជីវជាតិដី និងចូលរួមចំណែកធ្វើឱ្យធ្លាក់ចុះដល់ប្រភពទឹកក្រោមដី និងធ្វើឱ្យបឹងត្រពាំងរីងហួត។ បឹងទន្លេសាបនៅកម្ពុជាភាគពាយព្យ គឺជាប្រព័ន្ធអេកូឡូស៊ីទឹកធម្មជាតិដ៏មានសារៈសំខាន់បំផុត ហើយដែលទ្រទ្រង់ប្រជាជនកម្ពុជារាប់លាននាក់ តាមរយៈមច្ឆជីវចំរុះរបស់វា។ បឹងនេះត្រូវទទួលរងការគំរាមកំហែងពីរោងចក្រក្រដាស់ ដែល

បញ្ចេញសារធាតុពុល "តុកស៊ីន" និងសារធាតុគីមីផ្សេងៗទៀតចូលទៅក្នុងប្រព័ន្ធទឹកផ្សេងៗ ដែលត្រូវហូរចូលទៅក្នុងបឹងទន្លេសាប។ នៅក្នុងខេត្តកោះកុង និងតំបន់ផ្សេងទៀតដែលគ្របដណ្តប់ដោយព្រៃពាក់កណ្តាលស្រោង ការដាំដំណាំឯកវប្បកម្ម ដូចជាអាកាស្យា និងស្រល់ បានបំផ្លាញដល់តំបន់ពងកូនរបស់ត្រី ដែលភាសាតំបន់ហៅថា "ព្រៃលិចទឹក" នៅក្នុងអំឡុងខ្យល់មូសុង។

ក្រៅពីមានការខូចខាតដល់អេកូឡូស៊ី និងសេដ្ឋកិច្ច ការរំលោភសិទ្ធិមនុស្សក៏កើតមានផងដែរ។ អ្នកភូមិជាច្រើន ត្រូវទទួលរងការគំរាមកំហែងជាប្រចាំពីឆ្មាំល្បាតដែលប្រដាប់ទៅដោយអាវុធ ដែលជួលដោយសម្បទានិក ប្រសិនបើពួកគេព្យាយាមចូលទៅក្នុងតំបន់ភោគទ្រព្យ ឬធ្វើការតវ៉ាប្រឆាំងទល់នឹងការទន្ទ្រានដីធ្លី។ តំបន់មួយចំនួនធំ សកម្មភាពល្បាតដោយប្រើអាវុធ បានបណ្តាលឱ្យកើតមានអំពើហិង្សា ការរងរបួស និងស្លាប់ដល់អ្នកភូមិ។ នៅក្នុងតំបន់ជាច្រើន ឧទាហរណ៍នៅក្នុងខេត្តពោធិសាត់ ស្ទឹងត្រែង កំពង់ស្ពឺ មណ្ឌលគិរី និងកោះកុង សហគមន៍បានរៀបចំដោយខ្លួនរបស់ពួកគេដើម្បីធ្វើការតវ៉ាទាមទារចំពោះការបាត់បង់ដីធ្លី និងធនធានធម្មជាតិរបស់ពួកគេ និងសកម្មភាពរបស់ក្រុមហ៊ុនសម្បទានផ្សេងៗ។ ពួកគេបានធ្វើពាក្យបណ្តឹងទៅដល់មន្ត្រីថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិ ដើម្បីជួយធ្វើអន្តរាគមន៍ ប៉ុន្តែជាសំណាងអាក្រក់ ពួកគេមិនទទួលបានលទ្ធផលអ្វីទាំងអស់។ ផ្ទុយមកវិញ មន្ត្រីរដ្ឋបាលជាទូទៅបានលំអៀងទៅខាងក្រុមហ៊ុន ហើយបានប៉ុនប៉ងគំរាមកំហែងអ្នកភូមិឱ្យបញ្ឈប់ការប្តឹងតវ៉ារបស់ពួកគេ។

ប្រជាជនក្រីក្រតាមទីជនបទរបស់ប្រទេសកម្ពុជា បានទទួលផលប្រយោជន៍តិចតួចបំផុត ពីការរីកចំរើនសេដ្ឋកិច្ចរបស់ប្រទេស។ មិនត្រឹមតែភាពក្រីក្រ មិនត្រូវបានលុបបំបាត់ប៉ុណ្ណោះទេ ផ្ទុយមកវិញ មានប្រជាជនរិតតែច្រើន ធ្លាក់ខ្លួនក្រីក្រ និងងាយទទួលរងគ្រោះផ្នែកសេដ្ឋកិច្ច។ ការបំផ្លាញជីវចំរុះ និងការបាត់បង់លទ្ធភាពប្រើប្រាស់ធនធានព្រៃឈើ នេសាទត្រី និងប្រភពធម្មជាតិផ្សេងទៀត បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិសុខស្បៀងនៅថ្នាក់មូលដ្ឋាន។ ការភាសខ្លួនទាំងឈឺចាប់ពីជនបទមកកាន់ទីប្រជុំជន ជាពិសេសមកកាន់រាជធានីភ្នំពេញ កំពុងកើនឡើង។ ប៉ុន្តែអ្នកដែលស្វែងរកផ្លូវមកកាន់រាជធានីភ្នំពេញ ពុំអាចរកបានការងារ និងទីជំរកដ៏មានសុវត្ថិភាពសម្រាប់ពួកគេបានឡើយ ភាគច្រើនគឺត្រូវរស់នៅតាមដងផ្លូវ ឬកន្លែងតាំងទីលំនៅមិនជាប់លាប់ ហើយដែលត្រូវបន្តទទួលរងគ្រោះថ្នាក់ចំពោះការជម្លៀស ឬផ្លាស់ប្តូរទីលំនៅនៅពេលខាងមុខ។

នៅក្នុងពិភពអភិវឌ្ឍន៍អន្តរជាតិ ប្រទេសកម្ពុជាត្រូវបានចាត់ទុកថាជាប្រទេសក្រោយជម្លោះ ដែលបច្ចុប្បន្ននេះ ស្ថិតនៅក្នុងសម័យកាលសន្តិភាព ស្ថេរភាព និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ហើយត្រូវបានបកប្រែថាជាប្រទេសដែលមានការអភិវឌ្ឍន៍ច្រើន ដោយសារថាមិនមានសង្គ្រាម និងជាប្រទេសដែលព្រមឱ្យមានកញ្ចប់គោលនយោបាយសេដ្ឋកិច្ច ដែលសំដៅសម្របសម្រួលទីផ្សារមូលធននិយម។ ប៉ុន្តែការកើនឡើងនូវជម្លោះដីធ្លី និង

ភាពមិនសប្បាយចិត្ត របស់សហគមន៍ដោយសារតែបញ្ហាធនធាន និងដីធ្លីរបស់ពួកគេ ស្ទើរតែមិនអាចចាត់ទុកថាជាសូចនាករស្តីពីសន្តិភាព ស្ថេរភាព ឬសុខុមាលភាពបានទេ។

ដកស្រង់ចេញពី "ការមិនសប្បាយចិត្តដោយសារគោលនយោបាយថ្មីស្តីពីដីធ្លី និងធនធានធម្មជាតិ" ដោយ Shalmali Guttal, s.guttal@focusweb.org ផ្តោតលើពិភពលោកខាងត្បូង ខែធ្នូ ឆ្នាំ២០០៦។ របាយការណ៍ពេញលេញ អាចទទួលបាន តាមរយៈ គេហទំព័រ : http://focusweb.org/land-and-natural-resource-alienation-in-cambodia.html

### ការប៉ុនប៉ងគ្រប់គ្រងចំការឈើដាំដោយប្រើប្រព័ន្ធច្បាប់នៅកម្ពុជា

ចាប់តាំងពីឆ្នាំ២០០២ នៅពេលដែលព្រៃសម្បទានទាំងអស់ ត្រូវបានព្យួរ រដ្ឋាភិបាលកម្ពុជាបានបន្តគាំទ្រដីសម្បទានសេដ្ឋកិច្ចដល់ក្រុមហ៊ុនឯកជន ដែលជាបឋមធ្វើការអភិវឌ្ឍការដាំដំណាំលក្ខណៈកសិឧស្សាហកម្ម នូវប្រភេទដំណាំមួយចំនួន ដូចជាស្រូវ ដំឡូងមី កៅស៊ូ អាកាស្យា និងដំណាំកសិថាមពលផ្សេងៗទៀត។ ចំការឈើដាំទាំងអស់នេះ ត្រូវបានបង្កើតឡើងមិនត្រឹមតែដើម្បីរកប្រាក់ចំណូលជូនរដ្ឋ និងបង្កើតសកម្មភាពកសិកម្មធំរុះប៉ុណ្ណោះទេ ថែមទាំងដើម្បីកាត់បន្ថយភាពក្រីក្រផងដែរ ដោយលើកកម្ពស់ឱកាសការងារនៅតាមមូលដ្ឋាន។ ទោះជាយ៉ាងណាក៏ដោយ នៅចំនុចចាប់ផ្តើមបំផុត ចំការឈើដាំខ្នាតធំទាំងនេះ មិនអាចឆ្លើយតបតាមគោលបំណងទាំងនេះបានត្រឹមត្រូវ ហើយជាលទ្ធផល រដ្ឋាភិបាលត្រូវទទួលរងសំពាធឱ្យគ្រប់គ្រង និងត្រួតពិនិត្យការប្រតិបត្តិរបស់ពួកគេឱ្យបានល្អប្រសើរជាងនេះ។

បទដ្ឋានគតិយុត្តដែលគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច (ELCs) មានចែងនៅក្នុងច្បាប់ភូមិបាលឆ្នាំ២០០១ និងអនុក្រិតដីសម្បទានសេដ្ឋកិច្ចឆ្នាំ២០០៥។ ពួកវាមានចែងអំពីការតម្រូវឱ្យធ្វើកិច្ចព្រមព្រៀង និងការត្រួតពិនិត្យពីដំណើរការ ការផ្តល់ការការពារសិទ្ធិរបស់សហគមន៍មូលដ្ឋាន ដែលរស់នៅជុំវិញចំការទាំងនេះ និងការរារាំងផលប៉ះពាល់បរិស្ថាន។ ពួកវាក៏មានចែងពីការដាក់ទោសដល់ក្រុមហ៊ុនទាំងឡាយណា ដែលត្រូវបានរកឃើញថាមិនស្របតាមអ្វីដែលបានចែង។ ទោះបីជាយ៉ាងនេះក៏ដោយ ក្រុមហ៊ុនសម្បទានជាច្រើន ត្រូវបានផ្តល់ដោយមិនស្របតាមបទដ្ឋានគតិយុត្ត បានបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះសហគមន៍មូលដ្ឋាន និងមិនបានបំពេញតាមការសន្យាពីផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច។

មូលហេតុមួយចំពោះបញ្ហាទាំងអស់នេះ គឺកង្វះខាតតម្លាភាពអំឡុងដំណើរការរៀបចំកិច្ចព្រមព្រៀង និងកង្វះការទទួលខុសត្រូវនៅពេលដែលក្រុមហ៊ុនចាប់ផ្តើមប្រតិបត្តិការ។ ក្រោមសំពាធពីម្ចាស់ជំនួយ និងសង្គមស៊ីវិល រដ្ឋាភិបាលយល់ស្របកាលពីខែមិថុនា ឆ្នាំ២០០៧ ក្នុងការបង្កើត និងធ្វើបច្ចុប្បន្នកម្មឱ្យបានទៀងទាត់ចំពោះកំណត់ត្រា

ជាសាធារណៈនៃដីសម្បទានសេដ្ឋកិច្ច ដែលមានផ្តល់ជូនទូទាំងប្រទេស។ កំណត់ត្រានេះ មានបំណងធ្វើឱ្យសាធារណជនជ្រួតជ្រាបពីព័ត៌មានពាក់ព័ន្ធនឹងកម្មសិទ្ធិ ទីតាំង ស្ថានភាព និងការប្រតិបត្តិរបស់ក្រុមហ៊ុនសម្បទាននីមួយៗ ហើយក៏ត្រូវបង្ហោះតាមគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទផងដែរ។ លើសពីនេះនោះ រដ្ឋាភិបាលបានសន្យាថានឹងពិនិត្យមើលឡើងវិញ ចំពោះក្រុមហ៊ុនសម្បទានមួយចំនួនតូច ដែលបានទទួលដីកាន់កាប់លើសពីចំនួនកំណត់អតិបរមាចំនួន ១០,០០០ ហិកតា និងកំណត់អាទិភាពខ្លាំងក្លាជាងមុន ដើម្បីធានាឱ្យក្រុមហ៊ុនប្រតិបត្តិការស្រប តាមច្បាប់កម្ពុជា។

ទោះជាយ៉ាងណាក៏ដោយ ការត្រួតពិនិត្យដោយអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការទាក់ទងនឹងដីធ្លី និងបញ្ហាការគ្រប់គ្រងធនធានធម្មជាតិ បានរកឃើញថា មកត្រឹមខែវិច្ឆិកា ឆ្នាំ២០០៨ ដំណើរវិវឌ្ឍន៍ធ្វើឱ្យប្រសើរឡើងដល់តម្លាភាព និងការទទួលខុសត្រូវតាមរយៈវិធានការណ៍ទាំងអស់នេះ មានលក្ខណៈគួរឱ្យខកចិត្ត។ កំណត់ត្រាជាសាធារណៈនេះ មិនត្រូវបានធ្វើបច្ចុប្បន្នកម្មទៀងទាត់ ជាពិសេសទាក់ទងនឹងព័ត៌មានទាក់ទងនឹងសម្បទាន ដែលផ្តល់ការអនុញ្ញាតនៅត្រឹមកម្រិតថ្នាក់ខេត្ត។ មានភាពផ្ទុយគ្នាពាក់ព័ន្ធនឹងទិន្នន័យដែលចេញផ្សាយថ្មីៗ គឺរវាងព័ត៌មានដែលមាននៅក្នុងផ្នែកផ្សេងៗនៃគេហទំព័រ និងព័ត៌មានដែលចែកផ្សាយដោយភ្នាក់ងាររដ្ឋាភិបាលផ្សេងទៀត។ ជាងនេះទៀតសោត គោលគំនិតនៃ "កំណត់ត្រាជាសាធារណៈនេះ" ត្រូវបានបកប្រែដោយរដ្ឋាភិបាលទៅជាភាសាអង់គ្លេសប្រព័ន្ធផ្សព្វផ្សាយតាមអ៊ីនធឺណេត ដែលបង្កការលំបាកក្នុងការស្វែងយល់ ដល់សហគមន៍ដែលទទួលរងផលប៉ះពាល់ពីចំការឈើដាំ និងដែលជាអ្នកត្រូវបំផុតនូវព័ត៌មានទាំងអស់នេះ។ កំណត់ត្រាមួយ ដែលបង្កើតសម្រាប់សាធារណជនពិតប្រាកដ នឹងអាចប្រព្រឹត្តទៅបានប្រសិនបើជាភាសាខ្មែរនៅតាមមូលដ្ឋាន និងមិនស្ថិតក្នុងទម្រង់បច្ចេកវិទ្យាទំនើប។

ដំណើរវិវឌ្ឍន៍ធ្វើឱ្យប្រសើរឡើងដល់ការប្រតិបត្តិនៅមូលដ្ឋាន រិតតែមិនបានបំពេញចិត្ត ដោយយោងតាមអង្គការមិនមែនរដ្ឋាភិបាល។ នៅក្នុងចំណោមដីសម្បទានសេដ្ឋកិច្ចចំនួន៩ ដែលចុះបញ្ជីនៅក្នុងកំណត់ត្រាសាធារណៈថាមានទំហំដីធំជាងអ្វីដែលបានកំណត់ក្នុងច្បាប់ មានតែពីរប៉ុណ្ណោះត្រូវបានកាត់បន្ថយមកដល់ពេលនេះ។ ក្រុមហ៊ុនបីផ្សេងទៀត បានបដិសេធន៍មិនព្រមធ្វើការចចារអំពីកិច្ចព្រមព្រៀងរបស់ពួកគេឡើងវិញ។ ទន្ទឹមពេលជាមួយគ្នានេះដែរ រដ្ឋា ភិបាលបានបន្តផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលមានទំហំធំជាងចំនួនដែលកំណត់ក្នុងច្បាប់។ នៅក្នុងខែមេសា ឆ្នាំ២០០៨ ក្រុមហ៊ុនកូរ៉េខាងត្បូងមួយដែលមានឈ្មោះថា Kenertec Co., Ltd ត្រូវបានគេផ្តល់សម្បទានធំជាង៦ដងនៃទំហំ ដែល កំណត់នៅក្នុងច្បាប់ ដើម្បីដំណើរការគំរោងកែច្នៃ និងផលិតកសិថាមពល។ នៅក្នុងខែកញ្ញា ឆ្នាំ២០០៨ អភិបាលខេត្តស្ទឹងត្រែង បានយល់ព្រមជាសាធារណៈចំពោះសំណើររបស់ក្រុមហ៊ុន Greensea

Industry Company Ltd ដើម្បីពង្រីកផលិតកម្មកសិថាមពលរបស់ខ្លួន ដែលមានទំហំ ១០ដងធំជាងទំហំដែលកំណត់ក្នុងច្បាប់។

អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការទាក់ទងនឹងដីធ្លី និងធនធានធម្មជាតិ បានទទួលបណ្ដឹងតតយប់ឈរពីសហគមន៍តាមមូលដ្ឋានអំពីក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ច ដែលរំលោភច្បាប់ ហើយភ្នាក់ងាររបស់រដ្ឋាភិបាលកម្ពុជា មិនបានដាក់ទ័ណ្ឌកម្មដល់ក្រុមហ៊ុនដែលរំលោភច្បាប់ទាំងអស់នោះឡើយ។ កិច្ចព្រមព្រៀង ត្រូវបានចេញមុនពេលដែលដីត្រូវបានចុះបញ្ជីដោយស្របច្បាប់ ហើយជាលទ្ធផល តំបន់សម្បទានជាច្រើន មានរួមបញ្ចូលដីធ្លីដែលកាន់កាប់ដោយស្របច្បាប់របស់សហគមន៍។ អង្គការមិនមែនរដ្ឋាភិបាល មិនបានដឹងថាតើក្រុមហ៊ុនបានពិភាក្សាត្រឹមត្រូវជាមួយសហគមន៍មូលដ្ឋាន ឬបានធ្វើការវាយតំលៃផលប៉ះពាល់សង្គម និងបរិស្ថាន មុនពេលដែលសម្បទាននោះត្រូវបានផ្ដល់។

ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចជាច្រើន បានរំលោភលើលក្ខ័ខណ្ឌដែលមានចែងនៅក្នុងបទដ្ឋានគិតិយុត្តកម្ពុជា ដែលធានាសិទ្ធិប្រើប្រាស់ព្រៃឈើជាប្រពៃណី និងការពារដីធ្លីរបស់ប្រជាជនជនជាតិដើមភាគតិច។ ក្រុមហ៊ុនមួយដែលកំពុងរង់ចាំការផ្ដល់ដី សម្បទានចំនួន ១០,០០០ ហិកតា ដើម្បីដាំកៅស៊ូ ត្រូវបានចោទប្រកាន់ថាបានបង្ខំប្រជាជនជនជាតិដើមភាគតិចនៅក្នុងឃុំក្បែរខាង ឱ្យជួលដីរបស់ពួកគេក្នុងតម្លៃចន្លោះពី២៥-២៥០ដុល្លា ក្នុងរយៈពេលរហូតដល់៩៩ឆ្នាំ។ សមាជិកសហគមន៍មួយចំនួន ដែលតាមការរាយការណ៍ថា ត្រូវបានបង្ខំឱ្យលក់ដីរបស់ពួកគេទៅឱ្យក្រុមហ៊ុនក្នុងតម្លៃនេះ។ ការលក់ដូរនេះ ត្រូវបានចោទប្រកាន់ថាបានរៀបចំដោយមន្ត្រីប៉ូលីសមូលដ្ឋាន ដែលជូនដំណឹងដល់អ្នកភូមិថា ប្រសិនបើពួកគេមិនព្រមទទួលយកក្នុងតម្លៃផ្ដល់ឱ្យ ក្រុមហ៊ុននឹងនៅតែយកដីនេះដដែរ។ ករណីនេះ មិនត្រូវបានចាត់ទុកថាជាឧទាហរណ៍ តែឯងនោះទេ ការគំរាមកំហែងដល់ប្រជាជនមូលដ្ឋាន ត្រូវបានមើលឃើញនៅទូទាំងប្រទេស។

ក្នុងការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំរវាងរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល បានចងក្រងនូវអនុសាសន៍ជាច្រើនដូចមានបង្ហាញខាងក្រោម ដើម្បីផ្លាស់ប្ដូរដែលជាការទាមទារសម្រាប់១២ខែបន្ទាប់ ដែលអាចធ្វើឱ្យមានភាពប្រសើរឡើងដល់តម្លាភាព និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល ទៅលើចំការឈើដាំជាលក្ខណៈកសិឧស្សាហកម្ម។

- ⇨ ធ្វើបច្ចុប្បន្នកម្មកំណត់ត្រាសាធារណៈរៀងរាល់បីខែម្ដង និងធ្វើឱ្យព័ត៌មានលក្ខណៈងាយស្រួល ដោយមានជាភាខ្មែរនៅថ្នាក់មូលដ្ឋានសម្រាប់សហគមន៍ដែលទទួលរងគ្រោះដោយផ្ទាល់ពីដីសម្បទានសេដ្ឋកិច្ច។

- លុបចោលរាល់សម្បទានទាំងឡាយណាដែលមិនគោរពតាមលក្ខខណ្ឌ ដែលមានចែងនៅក្នុងអនុក្រឹត (ដែលបញ្ជាក់ថា មុនពេលដែលសម្បទានផ្តល់ឱ្យ ដីធ្លីត្រូវតែចុះបញ្ជី សិក្សាពីផលប៉ះពាល់បរិស្ថាន និងសង្គម ហើយការពិគ្រោះយោបល់ជាសាធារណៈ ត្រូវតែមាន ចំណែកបញ្ហាតាំងទីលំនៅថ្មី ត្រូវតែដោះស្រាយ)
- បញ្ជាក់ឱ្យបានច្បាស់អំពីមូលដ្ឋានច្បាប់ ថាតើដីសម្បទានសេដ្ឋកិច្ចដែលមានទំហំលើសពីចំនួនដែលបានកំណត់ក្នុងច្បាប់ចំនួនបីកន្លែង អាចបន្តការប្រតិបត្តិរបស់ពួកគេបានដែរឬយ៉ាងណា ហើយត្រូវចេញផ្សាយព័ត៌មានទាំងអស់ទាក់ទងនឹងយន្តការត្រួតពិនិត្យឡើងវិញ ជាពិសេសលទ្ធផលនៃការពិគ្រោះយោបល់ជាសាធារណៈជាមួយសហគមន៍រងគ្រោះ។ ធានាថា ដីសម្បទានទាំងនេះ មិនមានដំណើរទៅមុខ រហូតដល់បញ្ហាទាំងនេះ ត្រូវបានដោះស្រាយចប់ជាស្ថាពរសិន។

អង្គការសង្គមស៊ីវិលនៅកម្ពុជា បានប្រើប្រាស់កិច្ចប្រជុំរវាងម្ចាស់ជំនួយ និងរដ្ឋាភិបាល ជាឱកាសដើម្បីផ្លាស់ប្តូរគោលនយោបាយដោយជោគជ័យកាលពីអតីតកាល។ ទោះបីជាយ៉ាងនេះក្តី ទំនាក់ទំនងរវាងរដ្ឋាភិបាល និងម្ចាស់ជំនួយកំពុងផ្លាស់ប្តូរ ដោយសារតែកិច្ចព្រមព្រៀងជំនួយទ្វេរភាគីរវាងប្រទេសកម្ពុជា និងអ្នកជិតខាងថ្នាក់តំបន់របស់ខ្លួន ដែលអាចជាបញ្ហាប្រឈមចំពោះស្ថានភាពបច្ចុប្បន្ន។ សំណួរសម្រាប់អង្គការមិនមែនរដ្ឋាភិបាល ទាក់ទងនឹងអភិបាលកិច្ចចំពោះដីធ្លី និងធនធានធម្មជាតិនាពេលអនាគត គឺថាតើត្រូវភ្ជាប់ទំនាក់ទំនងជាមួយ "ម្ចាស់ជំនួយដែលទើបតែលេចមុខ" នេះដោយរបៀបណា ខណៈដែលត្រូវរក្សាទំនាក់ទំនងជាមួយម្ចាស់ជំនួយចាស់ និងទន្ទឹមពេលជាមួយគ្នាដែរ ត្រូវបង្កើតឱកាសសម្រាប់ការពិភាក្សាជាមួយ ក្រុមហ៊ុនសម្បទានដោយខ្លួនឯងផ្ទាល់។

ដោយ Megan MacInnes ទីប្រឹក្សាកម្មវិធីដីធ្លី និងការចិញ្ចឹមជីវិត នៃអង្គការវេទិកាមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។ អ៊ីមែល: megan@ngoforum.org.kh

---

[1] NGO Forum (2005) Fastwood Concessions: Economic Concessions and Local Livelihoods in Cambodia: field investigations in Koh Kong, Kampong Speu, Pursat, Mondulkiri, Prey Veng and Svay Rieng provinces. Environmental Forum Core Team, Phnom Penh, August 2005; UN-OHCHR (2007) Economic Land Concessions in Cambodia: a human rights perspective. UN Cambodia Office of the High Commissioner for Human Rights; NGO Forum (2007) NGO Position Papers on Cambodia's Development in 2006: monitoring of Joint Monitoring Indicators and Implementation of National Strategic Development Plan 2006-2010. Phnom Penh, June 2007.

[2] NGO Forum (2008) NGO Position Papers on Cambodia's Development in 2007-08: monitoring of 2007 CDCF Joint Monitoring Indicators and the National Strategic Development Plan 2006-2010. Phnom Penh, November 2008.
[3] Diokno, M (2008) The Importance of Community: issues and Perceptions of Land ownership and Future Options in 5 Communes in Mondulkiri Province, Cambodia. NTFP-Exchange Programme and NGO Forum on Cambodia, Phnom Penh, October 2008.

## ប្រទេសចិន : ស្ថានភាពបង្កភាពធ្ងន់ធ្ងរពីចំការឈើដាំ ដើមឈើជីអឹម (GM) រោងចក្រក្រដាស និង ការប្រើប្រាស់កាកសំណល់ក្រដាស

ទីផ្សារក្រដាស់ដែលកំពុងលូតលាស់របស់ប្រទេសចិន មានសន្ទុះលឿនជាងគេបំផុតនៅក្នុងពិភពលោក។ ទោះបីជាក្នុងមួយនាក់ ការប្រើប្រាស់ក្រដាសនៅមានចំនួនតិចជាងសហរដ្ឋអាមេរិក១០%ក៏ដោយ ប្រទេសចិនតំណាងឱ្យ ១៤%នៃការប្រើប្រាស់ក្រដាសទូទាំងពិភពលោក។ Jaakko Pöyry បានប៉ាន់ប្រមាណថា នៅចន្លោះឆ្នាំ២000-២០១៥ ការប្រើប្រាស់ក្រដាសនៅក្នុងប្រទេសចិន នឹងកើនឡើងចំនួន ៨.៤%ក្នុងមួយឆ្នាំ។ ភាគច្រើននៃការប្រើប្រាស់ក្រដាសនោះ គឺត្រូវបានប្រើប្រាស់ដើម្បីវេចខ្ចប់ទំនិញនាំចេញ ដែលមានន័យថា ការប្រើប្រាស់ក្រដាសក្នុងមនុស្សមួយនាក់ មានកម្រិតទាបបំផុត។

ការលូតលាស់បែបនេះ មានកម្រៃរបស់វានៅត្រង់ថា ក្រោមការផ្តល់ប្រឹក្សាយោបល់ និងថវិកាពីធនាគារពិភពលោក ឧស្សាហកម្មផលិតក្រដាសខ្នាតធំ ដែលប្រើប្រាស់កម្រិតទឹកដ៏ច្រើន ជួលបុគ្គលិកតិចតួច នឹងពឹងផ្អែកចំការឈើដាំលក្ខណៈឯកវប្បកម្ម ដែលមានទំហំដ៏ធំសំបើមដើម្បីផ្តល់ជាវត្ថុធាតុដើមឱ្យខ្លួន ត្រូវបានបង្កើតឡើង។ ឧស្សាហកម្មទំនើបនេះ កំពុងជំនួសឧស្សាហកម្មក្រដាស់ហួសសម័យ ដែលទោះជាបំពុលបរិស្ថានក៏ដោយ ក៏មានគុណសម្បត្តិមួយចំនួនផងដែរ ដូចជាវាដំណើរការនៅលើដីដែលមានទំហំមិនសូវធំ ប្រើប្រាស់វត្ថុធាតុដើមដែលមិនមែនជាឈើ ដូចជាសំណល់សល់ពីដំណាំស្រូវ និងស្រូវសាលី វាត្រូវការបុគ្គលិកច្រើន និងជួយគាំទ្រដល់កសិកររាប់លាននាក់ តាមរយៈការលក់ចំបើងស្រូវសាលីទៅឱ្យរោងចក្រផលិតក្រដាស់ក្នុងស្រុក ដែលជាប្រភពចំណូលដ៏សំខាន់។ (សូមមើលព្រឹត្តបត្រលេខ៨៣ នៃអង្គការ WRM)

ព័ត៌មានអាក្រក់ចំពោះភាពខ្សោយ ក្រុមហ៊ុនផ្តល់ប្រឹក្សាមានប្រាក់ចំណូលខ្ពស់ ក្រុមហ៊ុនផ្គត់ផ្គង់គ្រឿងម៉ាស៊ីន និងក្រុមហ៊ុនក្រដាសជាច្រើន ដែលមានឧស្សាហកម្មក្រដាសនៅទូទាំងពិភពលោក រួមមានក្រុមហ៊ុនផលិតក្រដាសដ៏ធំមហិមា Finnish-Swedish paper giant Stora Enso បានប្រកាស់ថា ខ្លួននឹងបង្កើនសមត្ថភាពរោងចក្រ Suzhou របស់ខ្លួនពី ១៦០,000-២៤០,000 តោនក្នុងមួយឆ្នាំ ដោយក្រុមហ៊ុន Stora Enso នេះមានចំការឈើដាំប្រភេទដំណាំប្រេងខ្យល់ជាច្រើននៅក្នុងខេត្តគ័ងស៊ី (Guangxi) ក្នុងប្រទេសចិន។ រោងចក្ររបស់ប្រទេស

ហ្វាំងឡង់ ដែលមានឈ្មោះថា Finland’s UPM Kymmene’s Changshu ចាប់ដំណើការនៅក្នុងឆ្នាំ១៩៩៩ ហើយបច្ចុប្បន្ននេះអាចផលិតបាន ៨00,000 តោនក្នុងមួយឆ្នាំ ដោយនាំចូលវត្ថុធាតុដើមក្រដាសពីប្រទេសឥណ្ឌូនេស៊ី។ ក្រុមហ៊ុនផលិតក្រដាសអាស៊ីរបស់ប្រទេសឥណ្ឌូនេស៊ី មានគំរោងសាងសង់រោចក្រដែលមានសមត្ថភាពផលិតក្រដាស បាន ៦00,000 តោន នៅក្នុងខេត្តខ្ញិនស៊ូ (Qinzhou) និងខេត្តក័ងស៊ី (Guangxi) ដែលពឹងផ្អែកចំការឈើដាំ ប្រភេទដំណាំប្រែងខ្យល់របស់ក្រុមហ៊ុននៅក្នុងប្រទេសចិនភាគខាងត្បូង។ APP មានបំណងបង្កើតចំការឈើដាំលើ ផ្ទៃដីចំនួន ៦00,000 ហិកតា នៅក្នុងប្រទេសចិន។ ក្រុមហ៊ុនក្រដាស់ធំបំផុតរបស់ប្រទេសជប៉ុនឈ្មោះ Oji Paper មានគំរោងបង្កើតចំការឈើដាំប្រភេទដំណាំឱ្យផលលឿនលើផ្ទៃដីសរុប ២00,000 ហិកតានៅក្នុងប្រទេសចិន។

កំនើនខាងការផលិតក្រដាស នាំទៅរកការបង្កើតចំការឈើដាំលក្ខណៈឧស្សាហកម្មច្រើនជាងមុន ដែលបណ្តាលឱ្យមានផលប៉ះពាល់បរិស្ថាន និងសង្គមយ៉ាងធ្ងន់ធ្ងរ។ គោលបំណងរបស់ពួកគេ គឺការប្រើប្រាស់ ហើយដើម្បីឱ្យឧស្សាហកម្មមានប្រាក់ចំណូល តម្រូវការការប្រើប្រាស់បែបសប្បនិម្មិត ត្រូវបង្កើត ដែលអាចជាវត្ថុធ្វើពីក្រដាសដ៏ចាំបាច់ ដូចជាថង់ខ្ចប់ សៀវភៅតូច នាមប័ណ្ណ សៀវភៅវាយឈ្មោះ អេប៉ុងធ្វើពីជាតិសៃលុយឡូស ក្រដាស់រុំ បារីកញ្ចប់បារី ស្លាកសំគាល់ ប្រអប់គ្រឿងលំអរមុខមាត់ និងរបស់មានតម្លៃ ក្រដាស់ជូតមុខ កញ្ចប់ញាំអាហារភ្លាមៗ កញ្ចប់កាដូ/អំណោយ កន្សែងជូតដៃ កន្សែងជូតផ្ទះបាយ សំបុត្រឆ្នោត បញ្ជីមុខម្ហូប កញ្ចប់អាហារសម្រាប់សត្វ ... (អាចមើលបន្ថែមនៅក្នុងបញ្ជីដ៏វែងមួយនៃផលិតផលសម្រេចរបស់ក្រុមហ៊ុនក្រដាស់ Sappi តាមគេហទំព័រ http://www.sappi.com/SappiWeb/Home+Page)។

ចន្លោះឆ្នាំ២00១-២0១៥ រដ្ឋាភិបាលរបស់ប្រទេសចិន មានគោលបំណងប្រើប្រាស់ដីចំនួន៦លានហិកតាដើម្បីវិនិយោគចំការឈើដាំលក្ខណៈឧស្សាហកម្ម ដើម្បីត្រឡប់ទសវត្សនៃការខូចខាតព្រៃឈើរបស់ខ្លួន ដែលបន្សល់ទុកឱ្យប្រទេសចិនទទួលរងបញ្ហាបរិស្ថានយ៉ាងធ្ងន់ធ្ងរ រួមមានគ្រោះរាំងស្ងួត និងទឹកជំនន់។ ទោះបីជាយ៉ាងនេះក៏ដោយ "ផែនការដាំដើមឈើឡើងវិញ" ស្ទើតែនោះ បង្កប់ខ្លឹមសារអំពីការដាំដើមឈើលក្ខណៈឯកវប្បកម្ម ដែលរួមមានចំការឈើដាំប្រភេទដំណាំជីអឹម។ លោក គ្រីស ស្លាង បានដកស្រង់ពីអ្នកឯកទេសព្រៃឈើរបស់ប្រទេសចិន ដែលមាន Wang Lida Han Yifan និង Hu Jianjun (សូមមើលព្រឹត្តបត្រលេខ៣៩របស់អង្គការ WRM) ដោយសរសេរថា "ជំហ៊ានទីមួយគឺត្រូវបង្កើតចំការឈើដាំ ដោយដាំនូវប្រភេទដើមឈើលូតលាស់លឿន ដូចជាពពួកដើមស្វាវ "Poplar and Larch"។ ទោះបីជាដើមឈើពពួក ដើមស្វាវ ត្រូវបានដាំដើម្បីការពារការហូរច្រោះដីក៏ដោយ ពួកវាចុងក្រោយ អាចប្រើប្រាស់ជាវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មក្រដាស់។

ប្រទេសចិនបានទទួលជំនួយជាថវិកាពីប្រទេសភាគខាងលិច ដើម្បីដាំដើមឈើ ឬធ្វើការស្រាវជ្រាវពីដើមឈើជីអឹម។ ចាប់តាំងពីឆ្នាំ១៩៨០ ធនាគារពិភពលោក បានឱ្យប្រទេសចិនខ្ចីជាង ៦០០ លានដុល្លាអាមេរិក ដើម្បីបង្កើតចំការឈើដាំ។ យោងតាមសេចក្ដីសង្ខេបប្រតិបត្តិរបស់អង្គការកសិកម្ម និងស្បៀង (FAO) ដោយ Nicholas Wheeler បានឱ្យដឹងថា "ទូទាំងពិភពលោក ការសាកល្បងជាង២១០ករណី ក្នុងការពិសោធន៍ដើមឈើជីអឹមត្រូវបានធ្វើឡើងនៅក្នុងប្រទេសជាង១៦" ប៉ុន្តែ "មានតែប្រទេសចិនប៉ុណ្ណោះ បានរាយការណ៍ថាបាននាំឈើជីអឹមចេញជាលក្ខណៈពាណិជ្ជកម្ម។ (ca ដើមឈើជាង ១.៤ លានដើមលើផ្ទៃដីពី ៣០០-៥០០ ហិកតា ក្នុងឆ្នាំ២០០២)។ (១)

នៅចុងទសវត្សទី៩០ ការសាកល្បងលើកដំបូងចំពោះដើមឈើជីអឹម ត្រូវបានធ្វើឡើងនៅតំបន់ក្បាលទន្លេលឿង និងយ៉ង់សេ និងនៅក្នុងខេត្តស៊ីនជាំងក្នុងតំបន់ស្ងួតភាគពាយ័ព្យ។ នៅឆ្នាំ២០០២ រដ្ឋបាលព្រៃឈើរបស់ប្រទេសចិន បានផ្ដល់ការអនុញ្ញាតឱ្យមានការដាំជាលក្ខណៈពាណិជ្ជកម្មនូវប្រភេទដើមឈើស្វាវជាលើកដំបូង។

ប្រភេទដើមឈើស្វាវជីអឹមដែលមានពីរប្រភេទ គឺប្រភេទ Populus nigra និង Populus hybrid ត្រូវបានបង្កើតឡើង និងដាក់ឈ្មោះស្វាវ-12 និងស្វាវ-741។ យោងតាមមន្ត្រីមកពីផ្នែកឯកទេស ព្រៃឈើរបស់ប្រទេសចិនឱ្យដឹងថា "អំបូរជាលក្ខណៈពាណិជ្ជកម្មទាំងពីរនេះ ជាប្រភេទស្វាវភេទញីដែលត្រូវ ការជីជាតិរបស់ដីផ្សេងៗគ្នា"។ ការផ្លាស់ប្ដូរសេនេទិច ត្រូវបានធ្វើឡើងសំដៅផ្ដល់ភាពធន់ទ្រាំទល់នឹងពពួកសត្វល្អិត បំផ្លាញស្លឹក (Bt) និងគុណភាពសាច់ឈើដែលបានកែប្រែ។

យោងតាមអត្ថបទរបស់ Katie Shafley បានឱ្យដឹងថា "ដើមឈើដែលមានករិតថ្នាំ (BT) កើនឡើងអាចបណ្ដាលឱ្យមានការសម្រាំងតាមលក្ខណៈធម្មជាតិនូវសត្វល្អិតមួយចំនួន ដែលមានភាពធន់ទ្រាំទល់នឹងថ្នាំសំលាប់សត្វល្អិត (BT)"។ លទ្ធផលដែលទទួលបានមកវិញ បញ្ហានេះត្រូវការចាំបាច់នូវករិតថ្នាំខ្ពស់ជាងមុន ដែលអាចសំលាប់ប្រភេទដែលមិនមែនជាគោលដៅផ្សេងទៀតបាន។" (២) ជាមួយដើមឈើជីអឹម គ្រោះថ្នាក់នៃការចម្លងរោគ គឺជាកត្តាគំរាមកំហែងដ៏ធ្ងន់ធ្ងរ ដែលគំរាមដល់ប្រធានអ្នកវិទ្យាសាស្ត្រមកពីផ្នែកឯកទេសព្រៃឈើរបស់ប្រទេសចិន គឺលោក Huoran Wang បានបញ្ជាក់យ៉ាងច្បាស់នៅក្នុងរបាយការណ៍ឆ្នាំ២០០៤ សម្រាប់អង្គការស្បៀងអាហារ និងកសិកម្ម សហប្រជាជាតិថា "ដើមឈើ ស្វាវត្រូវបានដាំយ៉ាងទូលំទូលាយនៅភាគខាងជើងប្រទេសចិន ដែលការចែកចាយលំអងផ្កា និងគ្រាប់ពូជនៃដើមឈើនេះ មិនអាចរារាំងបាន" ហើយថាការរក្សាទុក "នៅឆ្ងាយដាច់ដោយឡែកតែឯង" រវាងដើមឈើជីអឹម និងមិនមែនជីអឹម គឺ "ស្ទើរតែមិនធ្វើអាចទៅរួច"។ (៣)វិទ្យាស្ថានវិទ្យាសាស្ត្រ

បរិស្ថានក្រុងណានជីង បានរកឃើញស៊ែនពីដើមឈើស្វាវជីអឹម នៅក្នុងខេត្តស៊ីនជៀង ដែលលេចចេញជាប្រភេទធម្មជាតិផ្សេងៗគ្នាជាច្រើន។ (៤)

មានការចាប់អារម្មណ៍ច្រើនគួរសមពីសំណាក់ប្រទេសភាគខាងលិច ដើម្បីជួយប្រទេសចិនបង្កើតដើមឈើជីអឹម : គំរោងអភិវឌ្ឍន៍សហប្រជាជាតិ បានផ្តល់ទឹកប្រាក់ចំនួន ១.៨ លានដុល្លាអាមេរិក ដល់គំរោងដែលគ្រប់គ្រងដោយ អង្គការស្បៀងអាហារ និងកសិកម្ម ទាក់ទងនឹងដើមឈើ ស្វាវជីអឹម ដែលគាំទ្រផ្នែកកសាង សមត្ថភាពការផ្ទេរផ្នែកបច្ចេកវិទ្យា និងការគាំទ្រផ្នែកពិសោធន៍។ មជ្ឈមណ្ឌលស្រាវជ្រាវសហព័ន្ធអាឡឺម៉ង់ ដើម្បីព្រៃឈើ និងផលិតផលព្រៃឈើនៅឯ Waldsieversdorf បានរក្សាទំនាក់ទំនងយ៉ាងជិតស្និតជាមួយអ្នកវិទ្យាសាស្ត្រព្រៃឈើប្រទេសចិន ដែលធ្វើការពាក់ព័ន្ធនឹងដើមឈើស្វាវជីអឹម ពិសេស លោក Hu Jianjun អ្នកវិទ្យាសាស្ត្រចិន និងជាអ្នកផ្តួចផ្តើម។ ផ្នែកឯកទេសព្រៃឈើរបស់ចិន និងសាកលវិទ្យាល័យ Hebei នៅបៅឌីង (Baoding) កំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍដើមឈើស្វាវ និងបានធ្វើការសិក្សាស្រាវជ្រាវ។ (៥)

បទបញ្ញត្តិនៃការគ្រប់គ្រងសរីរាង្គ ដែលកែប្រែតាមលក្ខណៈសេនេទិចក្នុងប្រទេសចិន គ្របដណ្តប់ដោយសកម្មភាពជីវសុវត្ថិភាពសម្រាប់ GMOs ផ្នែកកសិកម្ម ដែលអនុម័តដោយក្រុមប្រឹក្សារដ្ឋ កាលពីខែមិថុនា ឆ្នាំ២០០១។ ទោះបីជាយ៉ាងណាក៏ដោយ មិនមានបញ្ញត្តិជាក់លាក់ណាមួយ ចែងពីដើមឈើស្វាវជីអឹមទេ ចំណែកការសម្រេចចិត្តថាតើត្រូវយល់ព្រមចំពោះដំណាំជីអឹមឬអត់នោះ ពឹងផ្អែកលើក្រុមអ្នកជំនាញការ ដែលចាត់ចែងដោយរដ្ឋបាលព្រៃឈើរបស់រដ្ឋ។ យោងតាមសេចក្តីប្រកាសរបស់ Xue Dayuan នៃវិទ្យាស្ថានវិទ្យាសាស្ត្របរិស្ថានណាជីង ការិយាល័យរដ្ឋបាលសុវត្ថិភាព GMO របស់ក្រសួងកសិកម្មប្រទេសចិន មិនមានការគ្រប់គ្រងដើមឈើជីអឹមទេ ពីព្រោះពួកវាមិនត្រូវបានចាត់ថ្នាក់ថាជាដំណាំ។ ប៉ុន្តែការិយាល័យព្រៃឈើរដ្ឋ ដែលជាស្ថាប័នត្រួតពិនិត្យចំការឈើដាំ មិនមានប្រព័ន្ធអនុញ្ញាតដូចស្ថាប័នដែលគ្រប់គ្រងដោយក្រសួងឡើយ។ (៦)

នៅក្នុងរបាយការណ៍អង្គការស្បៀងអាហារ និងកសិកម្មកម្ម លោក Huoran Wang បានសរសេរថា "តំបន់ដ៏ពិតប្រាកដសម្រាប់ចំការឈើដាំជីអឹម មិនអាចប៉ាន់ប្រមាណបានឡើយ ដោយសារភាពងាយស្រួលនៃការបង្កាត់ និងទីផ្សារដើមឈើជីអឹម និងដោយសារការលំបាកបែងចែកលក្ខណៈរូបសាស្ត្ររវាងដើមឈើជីអឹម និងដើមឈើមិនមែនជីអឹម"។ មានសម្ភារៈជាច្រើន ត្រូវបានរើពីថ្នាលបណ្តុះមួយទៅកាន់ថ្នាលបណ្តុះមួយផ្សេងទៀត ហើយវាមានការលំបាកណាស់ក្នុងការស្វែងរកសម្ភារៈទាំងនោះ។

ការកើនឡើងនៃការប្រើប្រាស់ក្រដាសខ្វះខ្នាយ បណ្តាលឱ្យមានការពង្រីកវិតតែធំឡើង នៃចំការឈើសម្រាប់ធ្វើក្រដាស់ជាលក្ខណៈឧស្សាហកម្ម។ ការរីកលូតលាស់ដ៏គង្ហុកនៃចំការឈើដាំ សម្រេចជោគជ័យដោយបន្សល់ទុកការ

ខូចខាតដល់គុណភាពដី ទឹក ជីវចំរុះ និងធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។ តម្រូវការបង្កើនប្រាក់ចំណូល តម្រូវឱ្យមានការផលិតច្រើនជាងមុនជាចាំបាច់ ដែលនាំទៅរកការបង្កើតចេញជាដើមឈើជីអឹម ដ៏មានគ្រោះថ្នាក់ ដើម្បីផ្គត់ផ្គង់រោងចក្រក្រដាស់ដែលកាន់តែច្រើនជាងមុន។ ស្ថានភាពបង្កឱ្យមានផលប៉ះពាល់ បែបនេះមិនអាចលុបបំបាត់បានទេ លុះណាតែកំទេចចោល។

(1) Executive summary, Nicholas Wheeler, FAO document, http://www.fao.org/docrep/008/ae574e/AE574E03.htm
(2) “The New Chainsaw. Genetically engineered trees are the new threat to Canada's forests”, by Katie Shafley, http://www.dominionpaper.ca/author/katie_shafley
(3) “The state of genetically modified forest trees in China”, Huoran Wang - Chinese Academy of Forestry, Beijing, FAO report, http://www.fao.org/docrep/008/ae574e/AE574E08.htm
(4) “China's GM trees get lost in bureaucracy”, Fred Pearce, New Scientist, http://www.newscientist.com/article/dn6402-chinas-gm-trees-get-lost-in-bureaucracy.html
(5) “Cultivation of Bt poplars in China”, GMO Safety, http://www.gmo-safety.eu/en/wood/poplar/325.docu.html
(6) Op cit 4

---

## ជីវភាពរស់នៅជនបទងាយទទួលរងគ្រោះថ្នាក់ ខណៈដែលការវិនិយោគកៅស៊ូកាន់កាប់ដីក្នុងប្រទេសឡាវ

ការវិនិយោគដោយក្រុមហ៊ុនបរទេសក្នុងលក្ខណៈជាចំការឈើដាំបែបពាណិជ្ជកម្មក្នុងប្រទេសឡាវ បានកើនឡើងយ៉ាងខ្លាំងនៅក្នុងអំឡុងឆ្នាំ២០០៤-២០០៦។ ចំការឈើដាំខ្នាតធំ ត្រូវបានលើកកម្ពស់តាមរយៈដីសម្បទានរបស់រដ្ឋ។ បច្ចុប្បន្ននេះ ផ្ទៃដីចំនួន ១៦៧,០០០ ហិកតា ត្រូវបានផ្ទេរទៅឱ្យក្រុមហ៊ុនបរទេសក្នុងលក្ខណៈជាដីសម្បទានខ្នាតធំ នៅភាគកណ្តាល និងភាគខាងត្បូងប្រទេស។ ក្នុងចំនួនផ្ទៃដីនេះ ៤៨%ដែលស្មើ ៨០,០០០ ហិកតា ត្រូវបានផ្តោតលើដំណាំកៅស៊ូ និង២៨%ទៀតដែលស្មើ ៤៦,០០០ ហិកតា ត្រូវបានផ្តល់សម្រាប់ដាំដំណាំប្រេងខ្យល់។ ទោះបីជាយ៉ាងនេះក៏ដោយ តំបន់ដាំដំណាំកៅស៊ូសរុបទូទាំងប្រទេស បានកើនឡើងដល់ ១៨២,៩០០ ហិកតា (ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម និងអាជ្ញាធរគ្រប់គ្រងដីធ្លីខេត្តចំប៉ាសាក់)

ការពង្រីកឧស្សាហកម្មកៅស៊ូនៅក្នុងប្រទេសឡាវ មានទំនាក់ទំនងផ្ទាល់នឹងការរីកលូតលាស់នៃឧស្សាហកម្មរថយន្តរបស់ប្រទេសចិន។ បច្ចុប្បន្ននេះ ប្រទេសចិនបានក្លាយទៅជាប្រទេសដែលប្រើប្រាស់កៅស៊ូច្រើនជាងគេ នៅទូទាំងពិភពលោក។ ក្រុមហ៊ុនជាច្រើនមកពីប្រទេសចិន បានពង្រីកតំបន់ដាំកៅស៊ូរបស់ពួកគេនៅក្នុងប្រទេសឡាវ តាមរយៈកុងត្រាដាំដុះ ដែលភាគច្រើនស្ថិតនៅតំបន់ភាគខាងជើង ដែលនៅទីនោះប្រទេសពីរប្រើព្រំដែនរួមមួយ។ ជាទូទៅ ក្រុមហ៊ុន និងពាណិជ្ជករចិន និងផ្តល់ថវិកា កូនឈើ និងទិញផលិផលវិញពីកសិករ ចំណែកឯដីធ្លី និងកំលាំងពលកម្ម ជាការទទួលខុសត្រូវរបស់កសិករ។ ទោះជាយ៉ាងនេះក៏ដោយ ភាពខុសគ្នាជាច្រើនក្នុងការចាត់ចែង នៅតែ

កើតមាន។ ក្រុមហ៊ុនរបស់ប្រទេសថៃ និងវៀតណាម បានវិនិយោគយ៉ាងច្រើនទៅលើដំណាំកៅស៊ូ ដែលភាគច្រើននៅតំបន់ភាគកណ្តាល និងភាគខាងត្បូងប្រទេស។ ក្រុមហ៊ុនទាំងពីរនេះ បានទទួលដីធ្លីតាមរយៈគំរូដីសម្បទាន។ ថ្មីៗនេះមានក្រុមហ៊ុនវៀតណាមចំនួនប្រាំនៅក្នុងប្រទេសឡាវភាគខាងត្បូង ដែលបួនក្នុងចំណោមនោះ ជាក្រុមហ៊ុនមកពីក្រុមផ្នែកដំណាំកៅស៊ូដ៏សំខាន់របស់ប្រទេសវៀតណាម (វៀត-ឡាវ ដាវទៀង តាំងមីញ និងខ្វាសាគៀវសូ) ចំណែកមួយទៀតជាក្រុមហ៊ុនថ្នាក់ខេត្ត ដែលមានឈ្មោះថា ក្រុមកៅស៊ូដាឡាក់។ ជាសរុប តំបន់ដែលត្រូវទទួលសិទ្ធិអនុញ្ញាតឱ្យដាំដំណាំកៅស៊ូក្នុងប្រទេសឡាវ មានចំនួន ៤២,០៥០ ហិកតា។

**ការបាត់បង់ដីធ្លី និងសំណងតិចតួច**

ដីសម្បទានសម្រាប់ដំណាំកៅស៊ូរបស់ក្រុមហ៊ុនវៀតណាមចំនួនបី បានធ្វើឱ្យប្រជាជនដែលរស់នៅក្នុងតំបន់ស្ទើរតែបាត់បង់ដីកសិកម្មរបស់ពួកគេទាំងអស់។ មានតែដីស្រែ ព្រមទាំងតំបន់លំនៅដ្ឋានក្នុងភូមិតិចតួចប៉ុណ្ណោះ ដែលមួយភាគតូចត្រូវបានមកវិញ។ តំបន់ភាគច្រើនដែលស្ថិតនៅក្នុងតំបន់ដីសម្បទានទាំងនោះ ជាចំការវិលជុំ និងដីដាំដំណាំ។

អ្នកភូមិមួយចំនួន បានសំដែងភាពច្របូកច្របល់ និងការខឹងសម្បាររបស់ពួកគេ តាមរយៈការបាត់បង់ដីធ្លី។ អ្នកភូមិម្នាក់ បានពន្យល់ថា **"មុនដំបូង ប្រជាជនមិនយល់អំពីថាអ្វីទៅជាដីសម្បទាននោះទេ។ អាជ្ញាធរភូមិ និងអាជ្ញាធរថ្នាក់លើ បានចុះមកពន្យល់ពីផលប្រយោជន៍ ដែលអ្នកភូមិនឹងអាចទទួលបាន។ ឧទាហរណ៍ ពួកគេបានពន្យល់ថា អ្នកភូមិនឹងទទួលបានការងារធ្វើជាមួយក្រុមហ៊ុន និងទទួលបានប្រាក់ឈ្នួលជារៀងរាល់ខែ។ ដីទាំងមូលរបស់ភូមិយើង គឺស្ថិតនៅក្នុងតំបន់ដីសម្បទាន។ អត់មានអ្វីដែលត្រូវនិយាយនោះទេ បើទោះបីជាយើងពេញចិត្ត ឬមិនពេញចិត្តក៏ដោយ ពីព្រោះដីសម្បទាននេះ ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាល"**។ អ្នកភូមិម្នាក់ទៀតបាននិយាយថា **"ប្រជាជនមួយចំនួន មានដីត្រឹមតែ១-២ហិកតាប៉ុណ្ណោះ ដែលពួកគេត្រូវតែប្រគល់ទៅឱ្យក្រុមហ៊ុន។ បន្ទាប់មក ពួកគេឥតមានដីនៅសល់ឡើយ ចំនុចនេះមានន័យថា ពួកគេអត់មានដីធ្វើស្រែដើម្បីបានអង្ករហូបនោះទេ។ ត្រូវពឹងទៅលើក្រុមហ៊ុន បើមិនដូច្នោះទេ ពួកគេនឹងស្លាប់"**។

ជាទូទៅ សំណងត្រូវសងដល់អ្នកដែលបាត់បង់ដីធ្លី ប៉ុន្តែមានករណីខុសប្រក្រតីជាច្រើនទាក់ទងទៅនិងសំនងហើយតំលៃសង មានកម្រិតទាបបំផុត។ របាយការណ៍សំណង មិនត្រូវបានធ្វើឱ្យដូចតាមអ្វីដែលបានចែងនៅក្នុងក្រិតស្តីពីសំណងនោះទេ។ ក្រុមហ៊ុនមួយចំនួន ចេញសងចំពោះតែផលដំណាំតែប៉ណ្ណោះ ក្រុមហ៊ុនខ្លះសិក្សាប៉ាន់ប្រមាណទៅលើដីធ្លី និងផលដំណាំរួមគ្នា និងក្រុមហ៊ុនខ្លះទៀត ចេញសងតែថ្លៃដីតែប៉ុណ្ណោះ។ ភាគច្រើនត្រូវពឹងផ្អែកទៅលើសមត្ថភាពចចារ របស់អ្នកភូមិម្នាក់ៗ ដែលខុសគ្នាយ៉ាងខ្លាំងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត។ ជាមធ្យម គ្រួសារដែលបានផ្តល់ការ សម្ភាសន៍ បានទទួលសំណងប្រហាក់ប្រហែល ១.៥ លានគីប (១៥០ ដុល្លាអាមេរិក) តែប៉ុណ្ណោះជាថ្នូរនឹងការខាតបង់ របស់ពួកគេ។

នៅក្នុងភូមិខ្លះ ដីចំការត្រូវបានផ្តល់សំណងជាមធ្យមចំនួន ៥០០,០០០ — ១,០០០,០០០ គីប ក្នុងមួយហិកតា (៥០-១០០ ដុល្លាអាមេរិក) ចំណែកភូមិផ្សេងៗទៀត មិនទទួលបានសំណងអ្វីទាំងអស់។ សណ្តែកដីដែលជារឿយៗត្រូវបានដាំនៅលើដីចំការ មិនត្រូវបានផ្តល់សំណងទេ។ សម្រាប់ដំណាំផ្សេងៗទៀត ដូចជាមៃស័កសំណងផ្អែកទៅលើប្រភេទ និងអាយុកាលរបស់ដើមឈើ ដែលជាទូទៅមានតម្លៃចន្លោះពី ៥០០-៥,០០០ គីប

ក្នុងមួយដើម (០.០៥-០.៥ ដុល្លារអាមេរិក)។ ការខាតបង់ ដែលកើតចេញពីដំណាំដែលអ្នកភូមិមិនអាចដាំបាន មិនត្រូវបានសិក្សាប៉ាន់ប្រមាណឡើយ។ ឧទាហរណ៍ ដំណាំធ្វើអំបោស *(យ៉ាខា)* ដែលអ្នកភូមិប្រមូលផលដើម្បីលក់ ឬដែលជាប្រភពម្ហូបអាហារ ឬតំបន់វាលស្មៅនៅក្នុងតំបន់ *ប៉ាខូក* (ព្រៃជ្រុះស្លឹកប្រចាំឆ្នាំ)។ គ្រួសារដែលមានចំការដំណាំធ្វើអំបោស ធ្លាប់ទទួលបានចំណូលពីការលក់ដើម *យ៉ាខា* តែឯងចំនួន ១.៦ លានគីប ក្នុងមួយគ្រួសារ ក្នុងរយៈពេលមួយឆ្នាំ។

**ការរស់នៅក្រោមស្ថានភាពងាយរងគ្រោះបំផុត**

ជីវភាពរស់នៅរបស់អ្នកភូមិដែលបាត់បង់ដីធ្លីដោយសារក្រុមហ៊ុន បានផ្លាស់ប្តូរ។ ពីភាពជាសហគមន៍មួយដែលធ្លាប់ប្រកបរបរចិញ្ចឹមជីវិតពីការដាំដុះ ធ្វើចំការវិលជុំ ចិញ្ចឹមសត្វគោ និងក្របី និងស្វែងរកអាហារនៅក្នុងតំបន់ព្រៃ *ប៉ាខូក* ឥឡូវនេះ ពឹងផ្អែកជាសំខាន់ទៅលើការងារដែលក្រុមហ៊ុនជួលធ្វើជាកម្មករ ដើម្បីរកប្រាក់ទិញអង្ករហូប។ ពួកគេបានលក់សត្វគោ និងក្របីស្ទើរតែទាំងអស់របស់ពួកគេ ដែលពួកគេធ្លាប់រក្សាទុកដើម្បីធ្វើស្រែចំការ និងយកសាច់ធ្វើជាអាហារបរិភោគ។

យោងតាមការសម្ភាសន៍ចំនួន១៨៦នាក់ នៅក្នុងភូមិចំនួនប្រាំមួយ បានរកឃើញថា ប្រជាជនដែលធ្វើស្រែបានផលហូបគ្រប់គ្រាន់សម្រាប់រយៈពេលពី១១-១២ខែក្នុងមួយឆ្នាំ បានធ្លាក់ចុះពី៤ភាគ៥ នៅឆ្នាំ២០០៣ មកត្រឹមតែ១ភាគ៥ប៉ុណ្ណោះ នៅត្រឹមឆ្នាំ២០០៧។ មានផ្ទះជាច្រើន មិនបានធ្វើស្រែអស់រយៈពេលជាច្រើនខែ ហើយមានគ្រួសារជាច្រើន ខ្វះខាតអង្ករបរិភោគនៅឆ្នាំ២០០៧។

សម្រាប់អ្នកដែលបាត់បង់ដីធ្លី ប្រសិនបើក្រុមហ៊ុនចំការកៅស៊ូមិនជួលប្រជាជនមូលដ្ឋានឱ្យធ្វើការនោះទេ នៅមានជំរើសមួយទៀត គឺពួកគេគេអាចងាកទៅរកសុំជំនួយពីនិយោជកមួយចំនួនផ្សេងទៀតបាន។ ពួកគេបានក្លាយទៅជា មនុស្សដែលពឹងពាក់គេចំពោះប្រភពចំណូល ដែលធ្វើឱ្យពួកគេងាយទទួលរងគ្រោះ បើប្រៀបធៀបជាមួយមធ្យោបាយ ចិញ្ចឹមជីវិតកាលពីដើមដំបូងរបស់ពួកគេ។ ភាគច្រើន អ្នកភូមិត្រូវបានជួលដោយផ្អែកលើមូលដ្ឋានប្រចាំថ្ងៃជាជាង មូលដ្ឋានអចិន្ត្រៃយ៍។ ក្រុមហ៊ុនជាច្រើន បានផ្តល់ប្រាក់ឈ្នួលខុសៗគ្នា ប៉ុន្តែជាទូទៅ កម្រៃជាមធ្យមដែលផ្តល់ឱ្យ មានចន្លោះពី ២០,០០០-២៥,០០០ គីប (២-២.៥ ដុល្លាអាមេរិក) ក្នុងមួយថ្ងៃ។ ចំនួនថ្ងៃធ្វើការងារជាមធ្យមក្នុងមួយឆ្នាំ សម្រាប់កម្មករមិនអចិន្ត្រៃយ៍ក្នុងចំណោមអ្នកដែលផ្តល់បទសម្ភាសន៍ ធ្វើការងារតិចជាង១/៤នៃឆ្នាំការងារ។

តម្រូវការកំលាំងពលកម្ម ត្រូវការក្នុងកម្រិតមួយខ្ពស់នៅឆ្នាំដំបូង ប៉ុន្តែមានការងារតិចតួចប៉ុណ្ណោះដែលត្រូវធ្វើបន្ទាប់ពីនោះមក រហូតដល់រដូវប្រមូលផលដំណាំកៅស៊ូ។ ប្រាក់ខែរបស់កម្មករអចិន្ត្រៃយ៍ មិនទៀងទាត់ ដែលទំនង

ជាធ្លាក់ចុះបន្ទាប់ពីឆ្នាំដំបូង។ កម្មករអចិន្ត្រៃយ៍ ជារឿយៗមិនដឹងថាតើពួកគេអាចរកលុយបានច្រើនប៉ុណ្ណានោះទេ រហូតដល់ពួកគេបានទទួលប្រាក់កម្រៃប្រចាំខែរបស់ពួកគេ។

នៅតាមភូមិមួយចំនួន ក្រុមហ៊ុនបណ្តេញកម្មករអចិន្ត្រៃយ៍របស់ខ្លួនទាំងអស់ចេញ ដោយនិយាយថាពួកគេអត់មានប្រសិទ្ធភាព។ ក្រុមហ៊ុនទាំងនោះ បានជួលកម្មករមកពីកន្លែងផ្សេង តាមរយៈឈ្មួញកណ្តាល នៅពេលដែលពួកគេមិនសប្បាយចិត្តជាមួយកម្មករក្នុងមូលដ្ឋាន។ មន្ត្រីអាជ្ញាធរគ្រប់គ្រងដីធ្លីថ្នាក់ខេត្តម្នាក់បានឱ្យយោបល់ថា "អ្នកភូមិមិនអាចកំណត់រូបភាពថាតើអនាគតរបស់ពួកគេគឺជាអ្វីនោះបានទេ ពីព្រោះដីធ្លីរបស់ពួកគេ ត្រូវបានប្រគល់ឱ្យកាន់កាប់ជាដីសម្បទាន។ តើកូនៗ និងចៅៗរបស់ពួកគេ នឹងធ្វើអ្វីនៅពេលខាងមុខ? មនុស្សចាស់ដែលមានកំលាំងខ្សោយ តើពួកគេនឹងធ្វើអ្វី? ប្រសិនបើតម្លៃជ័រកៅស៊ូធ្លាក់ចុះ តើនឹងមានផលប៉ះពាល់ដែរឬទេ?

**យោបល់រួម**

ប្រទេសឡាវ មានយុទ្ធសាស្ត្រព្រៃឈើ ដែលលើកកម្ពស់ការពង្រីកចំការឈើដាំលក្ខណៈពាណិជ្ជកម្មរហូតដល់ឆ្នាំ២០២០ ប៉ុន្តែមិនទាន់មានយុទ្ធសាស្ត្ររួម ពាក់ព័ន្ធនឹងធនធានដីធ្លីទាំងមូល។ ការលើកកម្ពស់ចំការឈើដាំជាលក្ខណៈពាណិជ្ជកម្ម ទំនងជាផ្តល់សារៈសំខាន់ច្រើនជាងការថែរក្សាទុកនូវតំបន់ធ្វើស្រែចំការ និងធនធានចិញ្ចឹមជីវិតផ្សេងទៀត សម្រាប់ការប្រើប្រាស់របស់មនុស្ស។

នៅក្នុងការពិនិត្យមើលឡើងវិញពីការវិនិយោគដ៏សំខាន់ ចំពោះចំការឈើដាំលក្ខណៈឯកវប្បកម្មកម្រិតធំ បញ្ហាធំៗជាច្រើន ត្រូវតែយកមកពិចារណា។ បន្ទាប់ពីមានបញ្ហាក្រខ្សត់នូវធនធានហិរញ្ញវត្ថុ និងសមត្ថភាពនៅក្នុងជួររបស់រដ្ឋាភិបាល ការសម្រេចចិត្តជាច្រើនត្រូវបានធ្វើឡើងដោយគ្មានការវិភាគស៊ីជំរៅ និងគ្មានការការពារនូវផលប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនភាគច្រើនរបស់ប្រទេសឡាវ។ ជាលទ្ធផល ប្រទេសនេះកំពុងប្រឈមមុខទល់នឹងការខាតបង់ដ៏សំបើមនូវធនធានសំខាន់ៗ ដែលត្រូវធ្លាក់ទៅក្នុងដៃឈ្មួញបរទេស។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ជាក់ និងកំណត់ពីសិទ្ធិកាន់កាប់ដីធ្លីរបស់ប្រជាពលរដ្ឋក៏ដោយ ការភ័ណ្ឌច្រឡំនៅតែកើតមាន សូម្បីតែនៅក្នុងចំណោមអ្នកដែលទទួលបានប័ណ្ណកាន់កាប់ដីធ្លី ក្រោមកម្មវិធីការផ្តល់ដីធ្លី និងព្រៃឈើ។ អ្នកភូមិជាច្រើន បានទទួលរងការគាបសង្កត់ឱ្យប្រគល់ប័ណ្ណកាន់កាប់ដីធ្លីរបស់ពួកគេចេញមក ដើម្បីអនុញ្ញាតឱ្យចំការឈើដាំអាចដំណើរការបាន។ ដូចគ្នានឹងបណ្តាប្រទេសផ្សេងៗនៅជុំវិញតំបន់នេះ តំបន់ចំការ តំបន់ព្រៃ *ប៉ាខូក* ឬតំបន់ព្រៃផ្សេងទៀត ដែលអ្នកភូមិអាចរកអាហារ និងផលព្រៃឈើបាន អាចចិញ្ចឹមសត្វបាន...។ល។ ត្រូវបានចាត់ទុកថាជាដីរបស់រដ្ឋ ដោយយោងតាមច្បាប់។ គុណតម្លៃ និងផលប្រយោជន៍នៃដីធ្លីទាំងនេះ ចំពោះ

ប្រជាជនមូលដ្ឋាន ត្រូវបានសិក្សាលំអិត ប៉ុន្តែកំរបានយកមកពិចារណាក្នុងការធ្វើផែនការ និងធ្វើសេចក្តីសម្រេចចិត្ត។ ការបាត់បង់ដីធ្លី និងព្រៃឈើទាំងអស់នេះចំពោះប្រជាពលរដ្ឋ មានន័យថាជាការកំពុងតែបំផ្លាញ។

យោងតាមរបាយការណ៍ស្រាវជ្រាវមួយដោយ Pinkaew, Luangaramsi, Rebeca Leonard, Pornpana and Kuaycharoen (2008) ស្តីពី "ផលប៉ះពាល់ពីចំការឈើដាំលក្ខណៈឧស្សាហកម្មខ្នាតធំទៅលើប្រព័ន្ធអេកូឡូស៊ី និងសេដ្ឋកិច្ចសង្គម នៅក្នុងប្រទេសឡាវ : ករណីសិក្សាពីចំការកៅស៊ូ" សាកលវិទ្យាល័យ ឈាង មៃ នឹងមានការកែសម្រួលជាភាសាអង់គ្លេស។ ផ្អែកលើកិច្ចសហការការងារស្រាវជ្រាវ រវាងមជ្ឈមណ្ឌលព័ត៌មាន និងការស្រាវជ្រាវទៅលើធនធានធម្មជាតិ និងដីធ្លី អាជ្ញាធរគ្រប់គ្រងដីធ្លីជាតិ ខុទ្ទកាល័យរបស់នាយករដ្ឋមន្ត្រី មូលនិធិដើម្បីស្តារប្រព័ន្ធអេកូឡូស៊ី និងមហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម សាកលវិទ្យាល័យឈាងមៃ ក្រុងឈាងមៃ ប្រទេសថៃ។

**ការអភិវឌ្ឍចំការឈើដាំក្នុងប្រទេសឡាវ —ការប្រជែងគ្នាដើម្បីបានចំណែកមួយនៃធនធានក្នុងប្រទេសឡាវ**

ចាប់តាំងពីឆ្នាំ២០០៦ ប្រទេសឡាវក្នុងតំបន់អាស៊ីអាគ្នេយ៍ដ៏តូច និងព័ទ្ធជុំវិញទៅដោយដី បានមើលឃើញពីការផ្ទុះឡើងនៃចំការឈើដាំខ្នាតតូច មធ្យម និងធំ ដែលផ្តោតជាពិសេសចំពោះដំណាំកៅស៊ូ ប្រេងខ្យល់ និងដំណាំជីវថាមពលផ្សេងៗទៀត។ ការរីកលូតលាស់នៃចំការឈើដាំលក្ខណៈឧស្សាហកម្មនេះ មិនបានកើតចេញដោយឯងៗនោះទេ ប៉ុន្តែត្រូវបានជំរុញដោយ (IFI's) ក្នុងរង្វង់មួយទសវត្សចុងក្រោយនេះ ដោយលើកឡើងថាជាមធ្យោបាយដើម្បីបង្កើនផលិតផលក្នុងស្រុកសរុប (GDP) របស់ប្រទេសឡាវ។ ស្ថាប័នដែលល្បីល្បាញបំផុតក្នុងចំណោមអ្នកជំរុញឱ្យមានការអភិវឌ្ឍចំការឈើដាំនេះ គឺធនាគារអភិវឌ្ឍន៍អាស៊ី។ ទោះបីជាប្រទេសមួយដែលមានអំពើពុករលួយធ្ងន់ធ្ងរជាងគេនៅលើពិភពលោកក៏ដោយ (ក្នុងឆ្នាំ២០០៧ ប្រទេសឡាវត្រូវបានចាត់ចំណាត់ថ្នាក់ទី ១៦៣ ក្នុងចំណោមប្រទេសចំនួន១៧១ នៅក្នុងតារាងគោលគំនិតអំពើពុករលួយ ទាក់ទងនឹងតម្លាភាពអន្តរជាតិ) ធនាគារអភិវឌ្ឍន៍អាស៊ី បាន និងកំពុងជំរុញឱ្យមានការវិនិយោគកសិរុក្ខកម្មក្នុងរយៈពេលមួយយូរអង្វែង។ ប្រវត្តិមិនស្មោះត្រង់នៃការជំរុញចំការឈើដាំ ទំនងត្រូវបានគេស្គាល់ច្បាស់ តាមរយៈគំរោងបរាជ័យរបស់ខ្លួន ដែលមានកំចីចំនួន ១១លានដុល្លាអាមេរិក ដោយអនុវត្តចាប់ពីឆ្នាំ១៩៩៦-២០០៣ ដែលមានគោលបំណងជំរុញឱ្យមានចំការឈើដាំនៅក្នុងប្រទេសឡាវ។ គំរោងនេះតែឯង បានបន្សល់ឱ្យមានកសិករក្រីក្រដ៏ច្រើនសន្ធឹកសន្ធាប់ ជាមួយនឹងបំណុលដែលមិនអាចសងរួច និងស្ទើរតែបានធ្វើឱ្យខ្ស័យធនដល់ធនាគារជំរុញវិស័យកសិកម្ម ដែលគ្រប់គ្រងដោយរដ្ឋាភិបាល និងបានសម្របសម្រួលឱ្យមានដំណើរការចំការឈើដាំខ្នាតធំផ្សេងៗទៀតនៅក្នុងប្រទេសឡាវ។

ទោះបីជាខ្វះខាតការរៀបចំសិទ្ធិកាន់កាប់ដីធ្លីប្រកបដោយសន្តិសុខ និងកង្វះសមត្ថភាពក្នុងជួររដ្ឋាភិបាល ដើម្បីត្រួតពិនិត្យ និងប្រើប្រាស់ប្រព័ន្ធច្បាប់គ្រប់គ្រងការវិនិយោគវិស័យចំការឈើដាំយ៉ាងណាក៏ដោយ ធនាគារអភិវឌ្ឍន៍អាស៊ី មិនមានការបារម្ភចំពោះការជំរុញប្រទេសឡាវឱ្យក្លាយទៅជា ទីកន្លែងសម្រាប់ក្រុមហ៊ុនវិនិយោគវិស័យកសិរុក្ខកម្មឆ្លងប្រទេសឡើយ ដោយកាលពីឆ្នាំ២០០៤ នៅក្នុងរាជធានីវៀងច័ន្ទ បានអញ្ជើញវិនិយោគិនផ្នែកកសិរុក្ខកម្មធំៗ ដើម្បីឱ្យជួយផ្សព្វផ្សាយប្រទេសឡាវថាជាកន្លែងសម្រាប់វិនិយោគចំការឈើដាំដ៏ល្អ។ សកម្មភាពជំរុញទាំងអស់នេះ ដែលបានធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ី ទំនងជាមានដំណើរការដូចគ្នាកាលពីឆ្នាំ២០០៥ ដែលក្រុមហ៊ុនផលិតក្រដាសដ៏ធំរបស់ប្រទេសជប៉ុនឈ្មោះ Oji Paper បានក្លាយទៅជាក្រុមហ៊ុនដ៏សំខាន់ដំបូងគេបង្អស់ដើម្បីវិនិយោគចំការឈើដាំនៅក្នុងប្រទេសឡាវ (ដោយទទួលបានដីសម្បទានចំនួន ៥០,០០០ ហិកតា)។ បន្ទាប់ពីការចូលអភិវឌ្ឍន៍របស់ក្រុមហ៊ុនមួយនេះ ការវិនិយោគផ្សេងៗទៀតក្នុងវិស័យកសិរុក្ខកម្ម ក៏បានរីកលូតលាស់ខ្លាំងខ្លាផងដែរ។ តួរលេខពីក្រសួងផែនការ និងវិនិយោគ បានបង្ហាញពីចំនួនទ្វេរគុណនៃចំនួនវិនិយោគវិស័យកសិរុក្ខកម្មចាប់ពីឆ្នាំ២០០៤-២០០៦ ជាមួយនឹងកំនើនតម្លៃវិនិយោគសរុបពី ៧៥លានដុល្លាអាមេរិក ក្នុងឆ្នាំ២០០៤ រហូតដល់ ៤៥៨លានដុល្លាអាមេរិក ក្នុងឆ្នាំ២០០៦។ ទន្ទឹមពេលគ្នានេះដែរ មានចំការឈើដាំកម្រិតតូច និងល្មមជាច្រើនចាប់ដំណើរការ ពិសេសពីប្រទេសជិតខាង ដែលបច្ចុប្បន្ននេះ វិនិយោគិនធំៗរួមមាន ក្រុម Grassim-Birla Group of India ដែលដើរតាមក្រុមហ៊ុន Oji Paper ដោយធានាសន្តិសុខដល់ដីសម្បទានចំនួន ៥០,០០០ ហិកតា ហើយថ្មីៗនេះទៀត ក្រុមហ៊ុនផលិតក្រដាស Stora Enso បានកំពុងធ្វើការចុះហត្ថលេខាលើកិច្ចព្រមព្រៀងដីសម្បទានចំនួន ៣៥,០០០ ហិកតា ដើម្បីដាំដើមប្រេងខ្យល់នៅភាគខាងត្បូងប្រទេសឡាវ។ នៅចុងបញ្ចប់ ក្រុមហ៊ុន Oji Paper កំពុងព្យាយាមបន្តអនុវត្តដីសម្បទានចំនួន ៣០,០០០ ហិកតាបន្ថែមទៀត នៅភាគខាងត្បូងប្រទេស។

ទោះជាយ៉ាងណាក៏ដោយ ក្នុងប្រទេសមួយ ដែលប្រាក់ខែរបស់មន្ត្រីរាជការ មានត្រឹមតែ៣០ដុល្លាអាមេរិក និងសមត្ថភាពត្រួតពិនិត្យដីសម្បទានរបស់ពួកគេនៅខ្សោយ ការបាត់បង់ធនធានធម្មជាតិ និងការរាំងស្ទះដល់ជីវភាពរស់នៅបែបប្រពៃណី បានអមដំណើរគ្នាជាមួយនឹងការអភិវឌ្ឍចំការឈើដាំ។ របាយការណ៍របស់អង្គការភ្នាក់ងារអភិវឌ្ឍន៍អាល្លឺម៉ង់ (GTZ) បានលាតត្រដាងពីការកង្វះខាតទាំងស្រុង នូវលិខិតគតិយុត្តផ្នែកដីសម្បទាន ក្នុងប្រទេសឡាវ។ ក្នុងចំណោមលទ្ធផលរកឃើញជាច្រើននៃរបាយការណ៍របស់អង្គការភ្នាក់ងារអភិវឌ្ឍន៍អាល្លឺម៉ង់ កាលពីឆ្នាំ២០០៦ បានឱ្យដឹងថា មានតិចតួចប៉ុណ្ណោះដែលមិនទាន់យល់អំពីការពង្រីកដីសម្បទាន ដែលបានចេញនៅទូទាំងប្រទេស ដោយសារដំណើរការប្រគល់ដីសម្បទានតាមបែបវិមជ្ឈកា និងបែបមិនប្រើប្រាស់ច្បាប់។ មិនត្រឹមតែភ្នាក់ងាររដ្ឋាភិបាលផ្សេងៗប៉ុណ្ណោះទេដែលអាចផ្តល់ដីសម្បទាន ប៉ុន្តែអាជ្ញាធររដ្ឋាភិបាលថ្នាក់ស្រុក ខេត្ត និងថ្នាក់ជាតិ

ក៏អាចផ្ដល់ដីឱ្យមានការអភិវឌ្ឍចំការឈើដាំផងដែរ ដោយគ្មានការឆ្លងយោបល់ពីស្ថានប័នផ្សេងណាមួយឡើយ។ ទិដ្ឋភាពបែបនេះ បាននាំទៅរកស្ថានភាពមួយ ដែលដីសម្បទានផ្ដល់កាលពីមុន ជាន់គ្នាជាមួយដីសម្បទាន ដែលផ្ដល់នៅពេលបច្ចុប្បន្ន ដែលមានន័យថា ក្រុមហ៊ុនចំការឈើដាំជាច្រើន ឥឡូវនេះកំពុងប្រជែងគ្នា ដើម្បីធ្វើយ៉ាងណាធានាសន្តិសុខ ដល់ដីសម្បទានរបស់ពួកគេ មុនវាត្រូវបានប្រគល់ទៅឱ្យក្រុមហ៊ុនផ្សេង។

ទោះបីជាមានការរីកលូតលាស់ ដែលមិនគួរឱ្យជឿ នៃការវិនិយោគកសិឧស្សាហកម្មនៅប៉ុន្មានឆ្នាំថ្មីៗនេះក៏ដោយ ដំណើរការផ្ដល់ដីសម្បទាននៅតែមិនទាន់គ្រប់គ្រាន់។ ការរាយការណ៍ចេញពីមន្ត្រីរដ្ឋាភិបាលដែលខឹងសម្បាមួយចំនួន និងពីអ្នកភូមិ បានគូសបញ្ជាក់ថា ជាការពិតក្រុមហ៊ុនបានទទួលការអនុញ្ញាតឱ្យផ្ដល់ដីដល់ពួកគេ ដោយដាក់មន្ត្រីរដ្ឋាភិបាលមូលដ្ឋានក្នុងតួនាទីដែលចេញថ្លៃដោយក្រុមហ៊ុន ដើម្បីរក្សាសន្តិសុខដីធ្លីរបស់ក្រុមហ៊ុន។ ក្នុងប្រព័ន្ធមួយ ដែលមានមន្ត្រីរាជការក្រីក្រច្រើន ត្រៀមសម្រាប់ដាក់ជំនួសមន្ត្រីណាដែលមិនអាចស្វែងរកដីបាន ហើយវាមិនគួឱ្យភ្ញាក់ផ្អើលទេដែលថា មានការរាយការណ៍ជាញឹកញាប់ថាមានឧបាយកល ការបោកបញ្ឆោតពីផលប្រយោជន៍ និង ការបង្ខំឱ្យអ្នកភូមិ ប្រគល់ដីធ្លីទៅឱ្យក្រុមហ៊ុនចំការឈើដាំ។

តាមទ្រឹស្តី ច្បាប់ព្រៃឈើបានចែងថាមានតែ "ដីសឹករិចរិល" ប៉ុណ្ណោះដែលអាចប្រើប្រាស់ដើម្បីអភិវឌ្ឍន៍ចំការឈើដាំ ប៉ុន្តែក្រោយៗមក ព្រៃឈើត្រូពិចដ៏ក្រាស់ ត្រូវបានកាប់ដើម្បីធ្វើផ្លូវសម្រាប់អភិវឌ្ឍន៍ចំការឈើដាំ (ដោយផ្ដល់ជាប្រាក់ចំណូលដ៏ងាយស្រួលពីការលក់ឈើទាំងនោះ)។ នៅចំចំនុចកណ្ដាលនៃខេត្ត បូលីខាំសៃ ដំណើរការនៃការកាប់ឈើដ៏ធំ និងច្រើនកន្លែង ដែលបិតបាំងថាជាការអភិវឌ្ឍដាំដើមដូងប្រេង ត្រូវបានរាយការណ៍ដោយភ្នាក់ងារអភិវឌ្ឍន៍ក្នុងតំបន់ ហើយមានអ្នកស្រាវជ្រាវឯករាជ្យជាច្រើន បានចងក្រងជាឯកសារ ទាក់ទងនឹងការទន្ទ្រានយកដីដែលសម្បូរទៅដោយព្រៃឈើសំខាន់ និងមិនសូវសំខាន់ ដើម្បីធ្វើចំការឈើដាំដើមប្រេងខ្យល់ឱ្យក្រុមហ៊ុន Oji Paper។

សម្រាប់សហគមន៍ជនបទ ដែលនៅតែពឹងផ្អែកខ្លាំងទៅលើធនធានព្រៃឈើដើម្បីចិញ្ចឹមជីវិត មានស្ថានភាពធ្ងន់ធ្ងរយ៉ាងខ្លាំង។ សហគមន៍នៅតាមភូមិ ថ្មីៗនេះមិនមានសិទ្ធិកាន់កាប់ដីធ្លីដោយសុវត្ថិភាពក្រោមច្បាប់នោះទេ ពីព្រោះដីព្រៃទាំងអស់ ត្រូវបានទទួលស្គាល់ថាជាទ្រព្យសម្បត្តិរបស់រដ្ឋ។ ការអភិវឌ្ឍចំការឈើដាំ ត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលរបស់ប្រទេសឡាវអស់រយៈពេលជាច្រើនឆ្នាំ ដោយប្រើជាឧបករណ៍រារាំងដល់ប្រព័ន្ធកសិកម្មពនេចរ ដែលកំណត់ពេលវេលាទុកដីឱ្យទំនេរចោល និងកាត់បន្ថយសន្តិសុខស្បៀង។ ជាងនេះទៀត សហគមន៍ជនបទ ទោះបីជាបាន បណ្ដោយឱ្យដីព្រៃរាប់សិបហិកតាក្លាយទៅជាចំការឈើដាំក៏ដោយ ពួកគេជាញឹកញាប់ ទទួលបានផលប្រយោជន៍តិច តួចបំផុតពីការអនុវត្តចំការឈើដាំទាំងនោះ។ អំឡុងពេលដាំដើមឈើ ដំណាលគ្នានឹងរដូវធ្វើស្រែដែរ

ដែលមានន័យថា ការងារជាច្រើនត្រូវបានទៅលើកម្មករផ្សេង ដែលមិនស្ថិតក្នុងកិច្ចសន្យា។ នៅក្នុងពេលវេលាណាមួយ នៅពេលដែលការងារសមប្រកបសម្រាប់អ្នកភូមិ ភាគច្រើនការងារទាំងនោះមិនទៀងទាត់ និងជាពិសេសផ្តល់លទ្ធភាពបានតែអ្នកភូមិមួយចំនួនតូចតែប៉ុណ្ណោះ។

មកត្រឹមខែឧសភា ឆ្នាំ២០០៧ រដ្ឋាភិបាលឡាវ បានបាត់ម្ចាស់ការគ្រប់គ្រងស្ថានភាពដីសម្បទាន និងមានរបាយការណ៍កាន់តែច្រើនឡើង (សូម្បីតែនៅតាមសារព័ត៌មានរដ្ឋ ដែលជាទូទៅនិយាយតែពីភាពវិជ្ជមាន) ដែលនិយាយអំពីភាពតានតឹងដែលអ្នកភូមិត្រូវប្រឈមមុខ ទាក់ទងនឹងចំការឈើដាំ រហូតដល់នាយករដ្ឋមន្ត្រីប្រទេសឡាវបានប្រកាស់ឱ្យផ្អាកដីសម្បទានទូទាំងប្រទេស។ ទោះជាយ៉ាងណាក៏ដោយ ការផ្អាកនេះបានបរាជ័យក្នុងការទប់ស្កាត់កំណើនដីសម្បទានទូទាំងប្រទេស ដោយសារតែ បើមិនត្រូវបានព្រងើយកន្តើយដោយឈ្មួញធំៗក្នុងតំបន់ទេ ក៏ត្រូវបានបញ្ចៀសតាមរយៈភាពខ្វះចន្លោះ ដែលមាននៅក្នុងការប្រកាសផ្អាកនោះ ដែលអនុញ្ញាតឱ្យតែក្រុមហ៊ុនដែលបានចុះហត្ថលេខាលើកិច្ចសន្យាដីសម្បទានប៉ុណ្ណោះ បន្តអនុវត្តដីសម្បទាន ឬអនុញ្ញាតឱ្យក្រុមហ៊ុនទាំងនោះ មានសម្បទានពហុវិស័យលើផ្ទៃដី១០០ហិកតា។

ថ្មីៗនេះ ខណៈពេលដែលមានចលនាជាវិជ្ជមានខ្លះៗពីរដ្ឋាភិបាលប្រទេសឡាវ និងភ្នាក់ងារផ្តល់ជំនួយ ដែលបានទទួលស្គាល់ និងត្រូវដោះស្រាយទប់ទល់នឹងការបរាជ័យដ៏ធ្ងន់ធ្ងរ នៃការវិនិយោគចំការឈើដាំក្នុងប្រទេសឡាវមានតែពេលវេលាប៉ុណ្ណោះ នឹងប្រាប់ថាតើរដ្ឋាភិបាលប្រទេសឡាវ អាចធ្វើបានល្អបានកម្រិតណា ដើម្បីគេចចេញឱ្យផុតពីការអភិវឌ្ឍចំការឈើដាំ និងដើម្បីការពារធនធានធម្មជាតិ ដែលមានសារៈសំខាន់ជាអនេក ដល់ជីវិតរស់នៅរបស់អ្នកភូមិ និងស្ថេរភាពរបស់ប្រទេស។

### ប្រទេសថៃ : តម្លៃកៅស៊ូខុសប្លែកគ្នា តើកសិករអាចទទួលបានផលចំណេញតាមវិធីណា?

ដំណាំកៅស៊ូ ជាផ្នែកមួយនៃជីវិតរស់នៅរបស់ប្រជាជនភាគខាងត្បូង ពាក់ព័ន្ធទាំងផ្នែកវប្បធម៌ និងសេដ្ឋកិច្ចក្នុងរយៈពេល១០៨ឆ្នាំចុងក្រោយនេះ។ ប្រព័ន្ធផលិតកម្មដំណាំឯកវប្បកម្ម បានជំនួសនូវប្រព័ន្ធព្រៃកៅស៊ូបែបបុរាណដែលកៅស៊ូត្រូវដាំនៅក្នុងចំណោមដំណាំហូបផ្លែ និងព្រៃធម្មជាតិ ដែលគេស្គាល់ថាជា *suan somrom* ឬ "សមាហរណកម្មសួនដំណាំ"។ ចំការកៅស៊ូ ត្រូវបានលើកកម្ពស់តាមរយៈមូលនិធិសុខុមាលភាពរបស់រដ្ឋាភិបាលសម្រាប់ចំការកៅស៊ូ។ ការជំរុញឱ្យមានការពង្រីកបន្ថែមនូវតំបន់កៅស៊ូដោយការិយាល័យមូលនិធិសុខុមាលភាពនេះ កំនើនតម្លៃកៅស៊ូ និងតម្រូវការកៅស៊ូពីទីផ្សារពិភពលោកសម្រាប់ការកែច្នៃជាលក្ខណៈឧស្សាហកម្ម ដើម្បីប្រែក្លាយទៅជាប្រភេទទំនិញផ្សេងៗ បាននាំទៅរកការពង្រីកបន្ថែមនូវតំបន់ដាំដុះដំណាំកៅស៊ូ និងការទន្ទ្រានចូលដីព្រៃនៅភាគខាងត្បូង និងចូលក្នុងតំបន់ឈើនៅភាគឥសាន្ត ដែលក្លាយជាផ្នែកដ៏ធំនៃព្រៃធម្មជាតិនៅភាគខាងកើត។ កៅស៊ូ

គឺជាប្រភេទរុក្ខជាតិមិនធម្មជាតិដែលរដ្ឋាភិបាលបានលើកកម្ពស់ ហើយទាំងព្រះរាជនាយកដ្ឋានព្រៃឈើ និងអង្គការឧស្សាហកម្មព្រៃឈើ សុទ្ធតែមានបំណងរកប្រាក់ចំណូលសេដ្ឋកិច្ចចេញពីចំការកៅស៊ូលក្ខណៈពាណិជ្ជកម្មនេះ។

តើមានកត្តាអ្វីខ្លះដែលជាប់ពាក់ព័ន្ធនឹងការកំណត់តម្លៃកៅស៊ូនៅក្នុងប្រទេសថៃ? ជាការពិត តម្រូវការកៅស៊ូរបស់ទីផ្សារ និងផលិតផលពីផលិតកម្មនៅលើពិភពលោក គឺសុទ្ធសឹងតែជាកត្តាស្នូល។ តម្លៃកៅស៊ូ ក៏មានជាប់ទាក់ទងនឹងតម្លៃប្រេងឡើងចុះផងដែរ ដែលជាកត្តាសំខាន់មួយនៅក្នុងផលិតកម្មកៅស៊ូជាលក្ខណៈសប្បនិម្មិត។ នៅពេលតម្លៃប្រេងឡើងថ្លៃ តម្លៃដើមផលិតកម្ម និងតម្លៃលក់កៅស៊ូសប្បនិម្មិត ក៏កើនឡើងផងដែរ ដែលធ្វើឱ្យប្រទេសជាច្រើនផ្លាស់ប្តូរទៅរកការប្រើប្រាស់កៅស៊ូបែបធម្មជាតិច្រើនជាងមុនវិញ។ ទោះបីយ៉ាងនេះក៏ដោយ ប្រសិនបើតម្លៃលក់កៅស៊ូធម្មជាតិកើនឡើងខ្ពស់ពេកចំពោះអ្នកផលិតជាលក្ខណៈឧស្សាហកម្ម ពួកគេនឹងត្រឡប់ទៅប្រើប្រាស់កៅស៊ូសប្បនិម្មិតវិញ ដែលអាចនាំឱ្យមានការធ្លាក់ចុះបន្តិចបន្តួចនៃតម្លៃលក់កៅស៊ូធម្មជាតិ។

ប៉ុន្តែតម្លៃលក់ ត្រូវកំណត់ដោយមនុស្សកំបាំងមុខជាច្រើននាក់។ ទីផ្សារកៅស៊ូនៅប្រទេសថៃ ត្រូវគ្រប់គ្រងដោយវិនិយោគិនប្រទេសសឹង្ហបុរី និងម៉ាឡេស៊ី ព្រមទាំងប្រទេសថៃខ្លួនឯងផងដែរ។ ម្យ៉ាងវិញទៀត ឧស្សាហកម្មទំនិញកៅស៊ូ ត្រូវត្រួតត្រាដោយប្រទេសឧស្សាហកម្មមួយចំនួន ដូចជាប្រទេសអាល្លឺមង់ អ៊ីតាលី ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ដែលច្រវាក់ពាណិជ្ជកម្មរបស់ពួកគេ ក្រោយមកបានវិលត្រឡប់ទៅទំនាក់ទំនងជាមួយពាណិជ្ជករលក្ខណៈឧស្សាហកម្មរបស់ប្រទេសថៃវិញ។

ថ្មីៗនេះ តម្លៃលក់កៅស៊ូទំនងជារងផលប៉ះពាល់ពីបទអន្តរាគមន៍ ដែលធ្វើឡើងដោយអ្នកគ្រប់គ្រងហ៊ុនកៅស៊ូរបស់ពិភពលោក។ ប្រសិនបើកៅស៊ូជាច្រើន ត្រូវបង្កើននៅតាមឃ្លាំងស្តុក ប្រទេសជាច្រើននឹងលក់ហ៊ុនរបស់ពួកគេចេញទៅឱ្យអ្នកផលិតកៅស៊ូ ព្រមទាំងទិញយកទាំងអស់នូវកៅស៊ូដែលនៅសេសសល់បន្តិចបន្តួច ដែលបានផលិតរួចនៅក្នុងឆ្នាំនេះ។ ប្រសិនបើមានបាតុភូតនៃតម្រូវការលើសលុបក្នុងកំឡុងពេលដ៏យូរ ប្រទេសអ្នកផលិតកៅស៊ូ នឹងទទួលរងសំពាធ ដែលជុំរុញឱ្យកាត់បន្ថយនូវបរិមាណផលិតជាដាច់ខាត។

ស្ថានភាពទិញ និងលក់ហ៊ុននៅលើទីផ្សារហ៊ុន គឺជាកត្តាមួយផ្សេងទៀតពាក់ព័ន្ធនឹងតម្លៃលក់កៅស៊ូ។ ទីផ្សារដែលមានឥទ្ធពលខ្លាំងបំផុត គឺទីផ្សាររបស់ប្រទេសជប៉ុន និងស័ង្ហបុរី។ ៩០%នៃជំនួញទីផ្សារជប៉ុន (ក្រុងតូក្យូ និងកូប៊ី) ត្រូវបានចាត់ទុកថាជាជំនួញដែលមានការប្រថុយប្រថានខ្ពស់ ហើយនៅសេសសល់ពីនេះ ជាប្រភេទកិច្ចសន្យាពាណិជ្ជកម្មជាមួយអ្នកនាំចូល និងឈ្មួញកណ្តាល។

ស្រដៀងគ្នានេះដែរ ៨០%នៃជំនួញនៅលើទីផ្សារស័ង្ហបុរី ជាប្រភេទកិច្ចសន្យាពាណិជ្ជកម្មនៅលើទីផ្សារហ៊ុន ចំណែកនៅសល់ពីនេះ ផ្អែកលើការផ្ទេរទំនិញជាលក្ខណៈរូបវ័ន្ត។ ទីផ្សារស័ង្ហបុរី ជាទីផ្សារដែលត្រូវបានបង្កើតឡើងយូរ

មកហើយ ជាចំនុចកណ្តាលនៃការដឹកជញ្ជូនទំនិញ និងជាមជ្ឈមណ្ឌលធនាគារ និងហិរញ្ញវត្ថុក្នុងចំណោមទីផ្សារផ្សេងៗ។ ទីផ្សារនេះ មានទំនាក់ទំនងយ៉ាងជិតស្និត ជាមួយប្រភពផលិតកៅស៊ូសំខាន់ៗបំផុតចំនួនបីនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ រួមមានប្រទេសថៃ ម៉ាឡេស៊ី និងឥណ្ឌូនេស៊ីជាដើម។ ប្រទេសបីនេះ អាចផលិតបានប្រហែល ៧០% នៃផលិតផលទូទាំងសាកលលោក។

ប្រទេសថៃជាអ្នកផលិតកៅស៊ូធំបំផុតទីបីនៅក្នុងពិភពលោក។ យ៉ាងណាក៏ដោយ តម្លៃលក់ត្រូវកំណត់ដោយទីផ្សាររបស់ប្រទេសជប៉ុន និងស័ង្ហបុរី។ រដ្ឋាភិបាលថៃ មិនដែលបានបង្កើតឱ្យមានតួនាទីរបស់ខ្លួន ពាក់ព័ន្ធនឹងការធ្វើឱ្យមានឥទ្ធិពលដល់តម្លៃលក់កៅស៊ូ នៅលើទីផ្សារកៅស៊ូរបស់សាកលលោកទេ។ រដ្ឋាភិបាលប្រទេសនេះបានចាត់ចែង និងគ្រប់គ្រងតម្លៃលក់កៅស៊ូ ដោយលំអោនតាមសំពាធពីភ្នាក់ងារអន្តរជាតិ និងប្រទេសបរទេសមួយចំនួន។ ជាទូទៅ រដ្ឋាភិបាលប្រើប្រាស់យុទ្ធសាស្រ្តរបស់អ្នកធ្វើអន្តរាគមន៍ក្នុងស្រុក ដើម្បីធ្វើឱ្យតម្លៃលក់កៅស៊ូមានស្ថេរភាព ដែលជាមធ្យោបាយមួយដើម្បីទទួលបានសំលេងឆ្នោតពីកសិករដាំកៅស៊ូ។ ជាឧទាហរណ៍ នៅក្នុងរដ្ឋបាលដែលទទួលបានជោគជ័យរបស់លោក ឈួន លីកផៃ និងឧត្តមសេនី ឆាវ៉ាលិត យុងឆៃយុត មានបទអន្តរាគមន៍ទៅលើតម្លៃលក់កៅស៊ូចំនួនប្រាំមួយដង ដោយទិញកៅស៊ូសុរបចំនួន ១.៣ លានតោន ដែលអស់ទឹកប្រាក់សរុបចំនួន ២៥,៣៩៤ លានបាត។ លទ្ធផលមួយកើតចេញពីសកម្មភាពនេះ គឺបានធ្វើឱ្យថវិការបស់រដ្ឋាភិបាលមានឱនភាពរហូតដល់ ៦,២៦៧ លានបាត ដែលភាគច្រើនបណ្តាលមកពីអំពើពុករលួយនៅតាមក្រសួង។ ពួកគេបានប្រើប្រាស់វិធីសាស្រ្តបញ្ចុះបញ្ចូល ផ្សព្វផ្សាយតាមផ្ទាំងរូបភាពធំៗ កេងបន្លំ ការទម្លាក់ថ្លៃ ព្រមទាំងការលក់បន្តោកទំនិញ ជាឧទាហរណ៍ កុងត្រាជាច្រើនត្រូវរៀបចំឡើងដើម្បីលក់ភាគហ៊ុនកៅស៊ូជាងហាសិបលើក ដោយមិនធ្វើការទទួលយកអ្វីមួយមកវិញ។

ជាងនេះទៀតសោត រដ្ឋាភិបាលបានអនុម័តច្បាប់គ្រប់គ្រងតម្លៃកៅស៊ូ កំណត់ទំហំតំបន់ផលិតកៅស៊ូ និងកន្លែងដាំដុះដំណាំផ្សេងៗទៀត។ កសិករមិនត្រូវបានអនុញ្ញាតឱ្យដាំដំណាំកៅស៊ូដោយខ្លួនផ្ទាល់របស់ពួកគេទេ។ ការគ្រប់គ្រងទាំងអស់នេះ ត្រូវបានដាក់ចំកន្លែង ដើម្បីធ្វើឱ្យកៅស៊ូរបស់ប្រទេសថៃអាចប្រកួតប្រជែងបាននៅលើទីផ្សារពិភពលោក។ ទោះបីជាយ៉ាងនេះក៏ដោយ បញ្ហាជារចនាសម្ព័ន្ធដែលនិយាយខាងលើនេះ បាននាំទៅរកការផ្តាច់មុខនៅលើទីផ្សារដោយវិនិយោគិនដែលគ្រប់គ្រងផលិតផល និងទីផ្សារកៅស៊ូ ខណៈដែលកសិករក្លាយជាអ្នកផ្គត់ផ្គង់កៅស៊ូដល់ទីផ្សារទាំងក្នុង និងខាងក្រៅ។

វាច្បាស់ណាស់ដែលថា កសិករដាំកៅស៊ូគឺជាអ្នកផ្គត់ផ្គង់កៅស៊ូនៅផ្នែកខាងលើតែមួយគត់ ដែលមិនមានឥទ្ធិពលកំណត់តម្លៃរបស់កៅស៊ូ។ ក្នុងឆ្នាំ២០០៧ តម្លៃផលិតនៃដុំកៅស៊ូឆៅ និងកៅស៊ូរាវរបស់កសិករថៃ ជាមធ្យម

ប្រមាណ ៣៥ បាតក្នុងមួយគីឡូក្រាម ដោយមិនរាប់បញ្ចូលតម្លៃដី និងកំលាំងពលកម្ម។ ដូចនេះ ខណៈដែលតម្លៃលក់ដុំកៅស៊ូឆៅ និងកៅស៊ូរាវ នៅចន្លោះពី ៥០-១០០ បាត ក្នុងមួយគីឡូក្រាម មានន័យថាកៅស៊ូរបស់កសិករទទួលបានតម្លៃខ្ពស់គួរសម្យ។

ជាការពិត នៅពេលប្រៀបធៀបតម្លៃលក់ដុំកៅស៊ូក្នុងស្រុកជាមួយទីផ្សារ តម្លៃលក់នៅទីផ្សារខេត្តខ្ពស់ជាង។ ឆ្នាំមុន តម្លៃលក់ដុំកៅស៊ូក្នុងស្រុក មានតម្លៃ ៤៧.១៤ បាត ក្នុងមួយគីឡូក្រាម ចំណែកតម្លៃនៅ ហាដយៃ មានតម្លៃ ៧៣.០៥ បាត ក្នុងមួយគីឡូក្រាម ហើយតម្លៃដេញថ្លៃមានតម្លៃ ៧៤.៥៧ បាត (ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧)។ ឆ្នាំនេះ ជ័រកៅស៊ូចំហុយរួចលេខ៣ ត្រូវបានលក់ក្នុងតម្លៃតែ ៣៥.៧៣ បាត ក្នុងមួយគីឡូក្រាម តែប៉ុណ្ណោះ នៅហាដយៃ (ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨)។

បច្ចុប្បន្ននេះ តម្លៃលក់បានធ្លាក់ចុះម្តងទៀត ដូចនេះសំនួរសួរថាតើរដ្ឋាភិបាល នឹងប្រើប្រាស់វិធីសាស្ត្រអ្នកអន្តរាគមន៍ក្នុងស្រុកដដែល ដើម្បីដោះស្រាយបញ្ហានៅខាងក្រោម និងដើម្បីប្រើប្រាស់លុយពីអ្នកបង់ពន្ធ ដោយអត់ធ្វើអ្វីសោះក្រៅតែពី "អុំទូកនៅក្នុងអាងទឹក"?

ទន្ទឹមពេលគ្នានេះដែរ កសិករដាំកៅស៊ូជាច្រើន បានព្យាយាមស្វែងរកមធ្យោបាយដោយខ្លួនពួកគេ ដើម្បីគេចចេញពីបញ្ហានេះ។ នៅក្នុងករណីមួយនៅសហគមន៍ មៃ រៀង កសិករបានបង្កើតជាបណ្តាញឧស្សាហកម្មសហគមន៍ជាមួយភូមិជិតខាងចំនួន១១ ដើម្បីកែច្នៃកៅស៊ូ។ ជាមួយគ្នានេះដែរ កសិករក៏បានធ្វើការដាំដុះដំណាំប្រភេទផ្សេងៗ ដើម្បីទប់ស្កាត់ពួកគេពីការប្រឈមមុខនឹងបញ្ហា ដែលពឹងផ្អែកតែទៅលើប្រាក់ចំណូលពីដំណាំកៅស៊ូ។ ពួកគេដាំទាំងកៅស៊ូ និងដំណាំហូបផ្លែ ពួកគេមានដីស្រែ ហើយពួកគេក៏មានធ្វើជំនួញតូចតាចផ្សេងៗបន្ថែមទៀតដែរ។ ចំពោះតំបន់ដាំកៅស៊ូ ការដាំដំណាំផ្សេងៗលាយជាមួយកៅស៊ូ គឺជាមធ្យោបាយមួយដើម្បីធ្វើឱ្យប្រសើរឡើងដល់ប្រព័ន្ធអេកូឡូស៊ីរបស់ដី។ កសិករនៅក្នុងក្រុម ប្រើប្រាស់ជីធម្មជាតិជំនួសឱ្យជីគីមី ដែលជួយកាត់បន្ថយការចំណាយនៅក្នុងគ្រួសារ។ ពួកគេមានអាហារផ្សេងៗដើម្បីបរិភោគ។ ដំណោះស្រាយលាយឡំនេះ ត្រូវបានស្នើឱ្យមានការពិភាក្សាដោយគ្រួសារជាច្រើន ដែលត្រូវអនុវត្តការពឹងផ្អែកខ្លួនឯង ព្រមទាំងការងារក្នុងរង្វង់ប្រព័ន្ធមូលធននិយម។

ដោយ Sayamol Kaiyoorawong គំរោងកសាងសមត្ថភាពបរិស្ថាន។ អ៊ីមែលៈ nok_sayamol@yahoo.com

## ផែនការដ៏ធំរបស់ប្រទេសថៃដើម្បីចំណេញការចំការឈើដាំកសិថាមពល ប្រឈមនឹងភាពមិនច្បាស់លាស់

ប្រទេសថៃកំពុងរៀបចំគ្រោងការដ៏ធំមួយ ជាពិសេសសម្រាប់ដប់ឆ្នាំក្រោយ ដើម្បីបង្កើនផលិតផលកសិថាមពល ពិសេសតាមរយៈការពង្រីកចំការដូងប្រេង។ ទោះបីជាយ៉ាងណាក៏ដោយ គ្រោងការនេះ មិនទាន់ដឹងថា

ត្រូវទៅទីណានៅឡើយទេ ដោយសារតែការប្រែប្រួលតម្លៃផលិតផលកសិថាមពល ដូចជា ដូងប្រេង ស្ករ ព្រមទាំងការព្រួយបារម្ភពីបរិស្ថាន ដែលកំពុងកើនឡើងផ្សេងៗទៀត។

ប្រទេសថៃមានប្រភេទកសិថាមពលពីរផ្សេងគ្នា គឺប្រភេទឧស្ម័នថាមពល (ល្បាយសាំង និងអេតាណុល) និងជីវម៉ាស៊ូត។ ឧស្ម័នថាមពល ផ្សំឡើងដោយការលាយគ្នារវាងសាំង និងអេតាណុលចំនួន ១០% ដែលអាចហៅថា E10 (Gonsalves ឆ្នាំ២០០៦)។

ជិត ៩០%នៃមេតាណុលក្នុងប្រទេសថៃ បានមកពីសាធាតុរាវរង្គ (សារធាតុដែលត្រូវបានធ្វើឱ្យឡើងមេដោយផលិតផលពីរោងចក្រស្ករ) និងរបស់នៅសល់ផ្សេងទៀត បានមកពីដំឡូងមី។ នៅក្នុងឆ្នាំ២០០៧ ប្រទេសថៃផលិតមេតាណុលបានចំនួន ១៩២.៨ លានលីត្រ (APEC ឆ្នាំ២០០៨)។

ទោះបីជាយ៉ាងនេះក៏ដោយ តម្លៃដើមផលិតដំណាំអំពៅ មានកម្រិតខ្ពស់ ហើយកម្រិតដែលត្រូវកែប្រែទៅជាអេតាណុល នៅទាបនៅឡើយ ចាប់តាំងពីអំពៅក្លាយជាវត្ថុធាតុដើមសំខាន់បំផុតដើម្បីផលិតស្ករ។ ដូចនេះប្រទេសថៃដែលជាប្រទេសអ្នកផលិតដំឡូងមីធំបំផុត ដែលមានចំនួនប្រមាណ ២០ លានតោនក្នុងមួយឆ្នាំ កំពុងសំឡឹងមើលខ្លាំងឡើងចំពោះដំឡូងមីថាជាវត្ថុធាតុដើមសម្រាប់ផលិតអេតាណុល (Artachinda, Gonsalves ឆ្នាំ២០០៦)។

ជីវម៉ាស៊ូត ត្រូវបានផលិតពីដំណើការចំរាញ់ (ដែលហៅថា transesterification) នៃប្រេងបន្លែដោយជាតិអាកុល ជាទូទៅជាតិ មេតាណុល ហើយក្រោយមកត្រូវលាយច្របល់ជាមួយម៉ាស៊ូត។ ប្រេងបន្លែ ដែលត្រូវបាននិយមប្រើប្រាស់នៅក្នុង ប្រទេសថៃ គឺដូងប្រេង (សណ្តែកសៀង គ្រាប់ធញ្ញជាតិ canola ដើមផ្កាឈូករត្ន័សណ្តែកដី អាចត្រូវបាន ប្រើប្រាស់ផងដែរ)។ B2 មាន២%ជាជីវម៉ាស៊ូត និង៩៨%ទៀតជាប្រេងម៉ាស៊ូត។ ១០%លាយច្របល់ជាមួយម៉ាស៊ូត អាចហៅថា B10 (Gonsalves ឆ្នាំ២០០៦)។ នៅក្នុងឆ្នាំ២០០៧ ផលិតកម្មជីវម៉ាស៊ូតរបស់ប្រទេសថៃ មានរហូតដល់៥៨លានលីត្រ។ នៅពេលបច្ចុប្បន្ននេះ ប្រទេសថៃមានរោងចក្រជីវម៉ាស៊ូតចំនួនប្រាំបួន ដែលមាន សមត្ថភាពផលិតសរុបចំនួន ៦៥៥ លានលីត្រក្នុងមួយឆ្នាំ (APEC ឆ្នាំ២០០៨)។

ដូងប្រេង គឺជាវត្ថុធាតុដើមដ៏សំខាន់នៅក្នុងប្រទេសថៃ។ ដូងប្រេងមួយហិកតា អាចផលិតប្រេងបានពី ៤-៥ តោន ដែលច្រើនជាងទិន្នផលរបស់ដំណាំយកប្រេង ដែលដាំជាលក្ខណៈឧស្សាហកម្មផ្សេងៗទៀតពី ៥-១០ ដង (Gonsalves ឆ្នាំ២០០៦)។

សេដ្ឋកិច្ចដូងប្រេងរបស់ប្រទេសថៃ ស្ថិតនៅចំណាត់ថ្នាក់ទីបីនៅលើពិភពលោក បន្ទាប់ពីប្រទេសឥណ្ឌូនេស៊ី និងម៉ាឡេស៊ី។ តំបន់ដាំដុះដូងប្រេងបច្ចុប្បន្ន មានចំនួន ៣២០,០០០ ហិកតា នៅក្នុងប្រទេសថៃ (IPS, 2008b) ដែលក្នុងនោះ ជាង៤០% ស្ថិតនៅក្នុងខេត្តភាគខាងត្បូង ជាពិសេសខេត្ត ក្រាប៊ី បន្ទាប់មកខេត្តស៊ូរាតថានី និងជុំផន។

តំបន់នៅភូមិភាគឥសាន្ត (អ៊ីសាអាន) មានប្រហែលជា ២,៣៦២ ហិកតា ជាពិសេសនៅក្នុងខេត្តកាឡាស៊ីន និងណាខនរ៉ាតឆាស៊ីម៉ា (Nok Sayamol, pers. Comm..)។

ផលិតផលប្រេងដូងសរុបប្រចាំឆ្នាំ មានចំនួន ១.៣ លានតោន ដែល៨00,000 តោន នឹងត្រូវចូលទៅផ្នែកចំណីអាហារ។ ក្នុងចំណោម ៥00,000 តោន ដែលនៅសេសសល់សម្រាប់ពាណិជ្ជកម្មមិនមែនអាហារ មាន ៤២0,000 តោន នឹងយកទៅធ្វើជា B2។ ចំពោះ B5 យ៉ាងហោចណាស់មាន ៦00,000 តោន ដែលគេត្រូវការ។

រដ្ឋាភិបាលបានបង្កើតក្រុមការងារមួយនៅក្នុងក្រសួងកសិកម្ម និងសហប្រតិបត្តិការ និងក្រសួងថាមពល ដែលមានឈ្មោះថា "គណៈកម្មការលើកកម្ពស់ និងអភិវឌ្ឍន៍ជីវថាមពល" (CBDP, Preechajarn et al. 2008)។ នៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខ ដោយគិតចាប់ពីឆ្នាំ២00៨ គណៈកម្មការនេះ មានទិសដៅពង្រីកបន្ថែមនូវតំបន់ដាំដុះដំណាំដូងប្រេង លើផ្ទៃដីចំនួន ២.៥ លាន រ៉ៃ ស្មើនឹង ៤00,000 ហិកតា (APEC ឆ្នាំ២00៨)។

ដើម្បីផលិតជីវម៉ាស៊ូត រដ្ឋាភិបាលថៃបានប្រកាសពី "ផែនការយុទ្ធសាស្ត្ររបស់ខ្លួនស្តីពីការអភិវឌ្ឍ និងលើកកម្ពស់ជីវម៉ាស៊ូត" កាលពីខែមករា ឆ្នាំ២00៥។ ផែនការនេះ មានគោលបំណងដាក់ជំនួសការប្រើប្រាស់ម៉ាស៊ូតចំនួន ១0% ដោយបង្កើនការដាំដុះដំណាំដូងប្រេង និងជំរុញការផលិតជីវម៉ាស៊ូតលក្ខណៈពាណិជ្ជកម្ម និងផ្អែកលើសហគមន៍ ឱ្យបានត្រឹមឆ្នាំ២0១២។ ជាងនេះទៅទៀត រដ្ឋាភិបាលបានណែនាំនូវអាណត្តិរបស់ B2 នៅក្នុងខែកុម្ភៈ ឆ្នាំ២00៨ ដើម្បីផលិតជីវម៉ាស៊ូតឱ្យបានប្រហែល ៤២0,000 តោន ក្នុងមួយឆ្នាំ (APEC ឆ្នាំ២00៨)។

យុទ្ធសាស្ត្រជីវម៉ាស៊ូតរបស់រដ្ឋាភិបាល គឺត្រូវបង្កើតការដាំដំណាំល្ហុងខ្វង និងដូងប្រេង ដោយមានការវិនិយោគសរុបប្រមាណជា ៧0 ពាន់លានបាត ស្មើនឹង ១.៧៥ ពាន់លានដុល្លាអាមេរិក (Gonsalves ឆ្នាំ២00៦ IPS 2008a)។ ជាពិសេសនៅក្នុងខេត្តភាគខាងត្បូង តំបន់មួយដែលត្រូវបានប្រកាសថាជាតំបន់សម្រាប់ក្រុមវិនិយោគិន រដ្ឋាភិបាលបានផ្តល់ថវិកាចំនួន ៥0 លានដុល្លាអាមេរិក ដើម្បីធ្វើការដាំដុះដំណាំដូងប្រេង (Griggers 2004)។

**គ្រោងការរយៈពេលយូររបស់ប្រទេសថៃ ដើម្បីរៀបចំចំការឈើដាំដំណាំកសិថាមពល**

១. ពង្រីកចំការឈើដាំដំណាំដូងប្រេងក្នុងស្រុក ដែលគ្របដណ្តប់លើផ្ទៃដីសរុបចំនួន ៤ លានរ៉ៃ ដែលស្មើនឹង 0.៦៧ លានហិកតា ដើម្បីផ្តល់ជីវម៉ាស៊ូតឱ្យបាន ៤.៨ លានលីត្រក្នុងមួយថ្ងៃ។

២. បង្កើតចំការឈើដាំដំណាំដូងប្រេង ដែលគ្របដណ្តប់លើផ្ទៃដីចំនួន ១ លាន រ៉ៃ នៅតាមបណ្តាលប្រទេសជិតខាង ដើម្បីទទួលបានទិន្នផលជីវម៉ាស៊ូតបន្ថែមចំនួន ១.២ លានលីត្រក្នុងមួយថ្ងៃ

៣. បង្កើតចំការឈើដាំរួមគ្នារវាងដំណាំដូងប្រេង និងល្ហុងខ្វង ដើម្បីផលិតជីវម៉ាស៊ូតបន្ថែម ឱ្យបាន ២.៥ លានលីត្រក្នុងមួយថ្ងៃ។ គេរំពឹងថា ចំការល្ហុងខ្វងដែលមានផ្ទៃដី ១ លានរ៉ៃ និងចំការដូងប្រេង

ប្រហែល ១.២ លានរ៉ៃ នឹងអាចផ្តល់ជីវម៉ាស៊ូតបានចំនួន ២.៥ លានលីត្រក្នុងមួយថ្ងៃ (Gonsalves ឆ្នាំ២០០៦)។

ទោះបីជាយ៉ាងណាក៏ដោយ ការពង្រីកតំបន់ដាំដុះដំណាំដូងប្រេង មិនទាន់កើតមានតាមការគ្រោងទុកនៅឡើយទេ។ យោងតាមរបាយការណ៍របស់នាយកដ្ឋានកសិកម្មសហរដ្ឋអាមេរិក (USDA) បានឱ្យដឹងថា "ការបង្កើនការដាំដុះដំណាំដូងប្រេង ដើម្បីបំពេញតាមតម្រូវការ កំពុងជួបនូវបញ្ហាប្រឈម។ នៅឆ្នាំ២០០៦ តំបន់ដាំដុះដូងប្រេងដែលបានកើនឡើងនោះ មានទំហំត្រឹមតែ ៤៨,០០០ ហិកតាតែប៉ុណ្ណោះ គឺប្រមាណជា ៤០%នៅពីក្រោមទិសដៅប្រចាំឆ្នាំ" (Preechajarn et al. p. 5)។ ការបរាជ័យនេះ ត្រូវបានសន្មត់ថាបណ្តាលមកពីកៅស៊ូ ដែលបានផ្តល់ប្រាក់ចំណូលច្រើនជាងមុន ប៉ុន្តែកង្វះខាតវត្ថុលើកទឹកចិត្តសម្រាប់ការដាំដំណាំដូងប្រេង។ ដូចនេះ រដ្ឋាភិបាលបានសម្រេចជុំរុញចំការឈើដាំដំណាំដូងប្រេងនៅក្នុងតំបន់មិនមានដាំកៅស៊ូ ដែលស្ថិតនៅភាគខាងជើង និងភាគឥសាន្តរបស់ប្រទេសថៃ (Gonsalves ឆ្នាំ២០០៦)។

ថាតើគោលនយោបាយពង្រីកកសិថាមពលរបស់រដ្ឋាភិបាល កើតឡើងតាមផែនការដែរឬអត់នោះ គឺអាស្រ័យទៅលើការប្រកួតប្រជែងលក្ខណៈសេដ្ឋកិច្ចនៃដំណាំកសិថាមពល ជាពិសេសតម្លៃលក់អេតាណុល ពីព្រោះអេតាណុលដែលថោកជាងនេះ និងដែលអាចលាយជាមួយប្រេងសាំងបាន គឺមានសារៈសំខាន់ណាស់សម្រាប់ផែនការរបស់រដ្ឋាភិបាលថៃ ដើម្បីដាក់អេតាណុលជំនួសសមាសធាតុអុកតាញ ៩៥ ដែលមាននៅក្នុងប្រេងសាំង។

ការសិក្សាវិភាគពីសេដ្ឋកិច្ចមួយបានបញ្ជាក់ថា "ផ្នែកដ៏ធំបំផុតនៃថ្លៃដើមផលិតកម្មអេតាណុលសរុប ពឹងផ្អែកយ៉ាងខ្លាំងទៅលើតម្លៃលក់ផលិតផល ដែលជាទូទៅមានការប្រែប្រួលខ្ពស់ និងទំនងជាទទួលរងផលប៉ះពាល់ពីតម្រូវការ និងការផ្គត់ផ្គង់គ្រឿងឧបភោគបរិភោគនៅលើទីផ្សារពិភពលោក និងបំរែបំរួលការផ្គត់ផ្គង់តាមតំបន់ និងរដូវកាល" (p. 78 Yoosin and Sorapipatana 2007)។

លទ្ធភាពនៃផលិតផលមួយចំនួន ដូចជាស្ករ និងដូងប្រេង ខុសប្លែកគ្នាពីរដូវមួយទៅរដូវមួយទៀត ទីតាំងភូមិសាស្ត្រ ព្រមជាមួយនឹងតម្រូវការរំពឹងទុកនាពេលអនាគត។ ជាឧទាហរណ៍ កំនើនផ្នែកតម្រូវការប្រេងដូង ថ្មីៗនេះបានធ្វើឱ្យតម្លៃលក់ប្រេងដូងសុទ្ធកើនឡើង។ តម្លៃលក់ប្រេងដូងក្នុងស្រុក កើនឡើងយ៉ាងខ្លាំងនៅចុងឆ្នាំ ២០០៧ ដោយឈានចូលរហូតដល់ការធ្វើកំណត់ត្រាទុកពីកម្រិតឡើងខ្ពស់ ដែលមានពី ៦-៦.៣ បាត ក្នុងមួយគីឡូក្រាម (២៩០-២០៦ ដុល្លាអាមេរិកក្នុងមួយតោន) នៅក្នុងខែមករា ឆ្នាំ២០០៨ (Preechajarn et al. 2008)។

បញ្ហានេះ បានធ្វើឱ្យប៉ះពាល់ស្ទើរតែទាំងស្រុងដល់ដំណាំកសិថាមពលដែលមានស្រាប់របស់ប្រទេសថៃ ដែលប្រឈមមុខនឹងការផ្គត់ផ្គង់ហួសកំណត់ ព្រមទាំងកំនើនតម្លៃវត្ថុធាតុដើម នៅត្រឹមពាក់កណ្តាលឆ្នាំ២០០៨ ដែល

ស្ទើរតែរោងចក្រផលិតអេតាណុលទាំងអស់ កំពុងដំណើរការតែចំនួន ៧០%ប៉ុណ្ណោះនៃសមត្ថភាពផលិតរបស់ពួកគេ ខណៈដែលរោចក្រផ្សេង១ទៀត បានព្យួរការផលិតរបស់ខ្លួន ឬផ្លាស់ប្តូរទៅជាការផលិតផលិតផលផ្សេង ក្រៅពីអេតាណុល ( Preechajarn et al. 2008)។

ការព្រួយបារម្ភផ្នែកបរិស្ថានអំពីការពុលរបស់ដី និងទឹក ជុំវិញតំបន់ចំការឈើដាំដំណាំកសិថាមពលរបស់ប្រទេសថៃ នៅត្រង់ថាថ្នាំសំលាប់ស្មៅចង្រៃ ដូចជា Paraquat និង Glyphosate ត្រូវបានប្រើប្រាស់នៅលើដីនៅក្នុងតំបន់ចំការដូងប្រេង ថ្នាំសំលាប់សត្វល្អិតចង្រៃពពួក Furadan ត្រូវបានយកមកប្រើប្រាស់នៅក្នុងថ្នាលបណ្តុះកូនដូងប្រេង (Pleanjai et al. 2004)។ Furadan គឺជាឈ្មោះស្លាកថ្នាំសំលាប់សត្វល្អិតចង្រៃ Carbofuran ដែលបានប្រឈមនឹងរឿងចំរូងចំរាស់ជាច្រើន ចាប់តាំងពីទសវត្សទី៨០ បន្ទាប់ពីការពិនិត្យមើលឡើងវិញជាពិសេសរបស់ភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិក (EPA) ដែលបានប៉ាន់ប្រមាណថា បក្សីជាងមួយលានក្បាលបានស្លាប់រៀងរាល់ឆ្នាំដោយសារតែការបង្កើតឱ្យមានសារធាតុជាគ្រាប់តូច១។ បន្ទាប់មក ការបង្កើតគ្រាប់តូច១នេះត្រូវបានលុបចោលនៅក្នុងសហរដ្ឋអាមេរិក នៅក្នុងឆ្នាំ១៩៩៤ ប៉ុន្តែទម្រង់ជាសារធាតុរាវ នៅតែរក្សាដដែលនៅលើទីផ្សារ ពិភពលោក។

ដោយ Amraapali, N.a ដែលជាអ្នកសរសេរមានមូលដ្ឋាននៅក្នុងតំបន់ទន្លេមេគង្គ។ អ៊ីមែលៈ Amraapali@gmail.com

APEC. 2008. Thailand biofuels activities. *in* APEC Biofuels.
Artachinda, A. Bio fuel development and consumption in Thailand. Mekong Environment and Resource Institute (MERI), Bangkok.
CIAT. 2008. Cassava and Biofuels: Is this the Magic Vehicle that will Lift Millions of Cassava Farmers Out of Poverty? . *in*. International Center for Tropical Agriculture (CIAT).
Gonsalves, J. B. 2006. An Assessment of the Biofuels Industry in Thailand. United Nations Conference on Trade and Development (UNCTAD), Geneva.
Griggers, C. 2004. Biofuels: A natural solution to rising oil costs. *in* Thailand Investment Review-Board of Investment (BOI).
IPS. 2008a. Jatropha key to self-sufficiency? *in*. Inter Press Service (IPS), Manila.
IPS. 2008b. Environment: Clean or Not Thailand Sees Dollars in Palm Oil by Marwaan Macan-Markar. Inter Press Service (IPS), Manila. http://ipsnews.net/news.asp?idnews=38415
Pleanjai, S., S. H. Gheewala, and S. Garivait. 2004. Environmental Evaluation of Biodiesel Production from Palm Oil in a Life Cycle Perspective. *in* The Joint International Conference on “Sustainable Energy and Environment (SEE)".
Preechajarn, S., P. Prasertsri, and M. Kunasirirat. 2008. Thailand Bio-Fuels Annual 2008 USDA Foreign Agricultural Service
Yoosin, S., and C. Sorapipatana. 2007. A Study of Ethanol Production Cost for Gasoline Substitution in Thailand and Its Competitiveness. Thammasat Int. J. Sc. Tech. **12**:69-80.

**ប្រទេសវៀតណាម : កង្វះខាតក្រដាស កំណើនថ្លៃលក់ រោងចក្រក្រដាសកើតថ្មី និងកំនើនចំការឈើផាំ**

រៀងរាល់ឆ្នាំកាលពីទសវត្សកន្លងទៅថ្មីៗនេះ ប្រទេសវៀតណាម បានប្រឈមមុខទល់នឹងកង្វះខាតក្រដាសជាច្រើន។ ឆ្នាំនេះ មិនអាចលើកលែងបានទេ។ នៅក្នុងខែមិថុនា ឆ្នាំ២០០៨ កាសែតប្រទេសវៀតណាម បានរាយការណ៍ថា រោងពុម្ព និងកន្លែងបោះពុម្ពជាច្រើន កំពុងប្រឈមនឹងផលលំបាកជាច្រើន ពាក់ព័ន្ធនឹងការទិញការផ្គត់ផ្គង់។ កង្វះខាតផ្សេងៗ បានកំពុងកើតឡើង ទោះបីជារោងចក្រផលិតក្រដាសធំៗចំនួនពីររបស់ប្រទេសនេះ គឺរោងចក្រ Bai Bang និង Tan Mai កំពុងប្រតិបត្តិការក្នុងសមត្ថភាពពេញលេញយ៉ាងណាក៏ដោយ ហើយការនាំចូលក្រដាស បានកើនឡើងយ៉ាងខ្លាំងអំឡុងដើមខែដំបូងនៃឆ្នាំ។

ការពន្យល់មួយចំពោះកង្វះខាតនេះ គឺបណ្តាលមកពីអ្នកនាំចូលជាច្រើន កំពុងស្តុកទុកក្រដាស ដោយរង់ចាំឱ្យតម្លៃក្រដាសនាំចូលកើនឡើងមុនពេលលក់ចេញ។ នៅក្នុងខែមីនា ក្រដាសមកពីប្រទេសឥណ្ឌូនេស៊ីចំនួនមួយតោនអាចនាំចូលទៅក្នុងប្រទេសវៀតណាមក្នុងតម្លៃ ៦៥០ ដុល្លាអាមេរិក។ មកដល់ខែឧសភា តម្លៃលក់បានឡើងដល់ ៨០០ ដុល្លាអាមេរិក។ ទន្ទឹមពេលជាមួយគ្នានេះដែរ ការនាំចូលក្រដាស់ពីប្រទេសចិន បានធ្លាក់ចុះ ដោយបង្កើនតម្រូវការដ៏មានសក្តានុពលសម្រាប់ទំនិញនាំចូលពីប្រទេសឥណ្ឌូនេស៊ី។

នៅក្នុងខែមិថុនា ឆ្នាំ២០០៨ រោងពុម្ពជាច្រើន បានបង្កើនតម្លៃលក់សៀវភៅ។ សៀវភៅដែលលក់ដាច់ច្រើនបំផុត គឺសៀវភៅ "វាលស្រែដ៏ធំល្វឹងល្វើយ" ដែលនិពន្ធដោយ Nguyen Ngoc Tu បានកើនតម្លៃ២០%។

ក្នុងខែកញ្ញា ឆ្នាំ២០០៨ ក្រសួងហិរញ្ញវត្ថុ បានកាត់បន្ថយពន្ធនាំចូលទៅលើក្រដាស ចន្លោះពី ៧-១២% ដោយអាស្រ័យតាមប្រភេទក្រដាស់។ តួនាទីរបស់សមាគមក្រដាសរបស់ប្រទេសវៀតណាមចំពោះការកាត់បន្ថយនោះមិនសូវច្បាស់លាស់។ កាសែតជាច្រើន បានរាយការណ៍ថា ការកាត់បន្ថយពន្ធនោះ បណ្តាលមកពីសំណើសុំរបស់សមាគមនេះ។ ប៉ុន្តែរដ្ឋលេខាធិការរបស់សមាគមនេះ គឺលោក Vu Ngoc Bao បានប្រាប់ភ្នាក់ងារសារព័ត៌មានវៀតណាមថា "ការកាត់បន្ថយនេះ នឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់អ្នកផលិតក្រដាសក្នុងស្រុក ដែលមានការលំបាកក្នុងការកាត់បន្ថយតម្លៃផលិតរបស់ពួកគេ ដោយសារតែតម្លៃសម្ភារៈកើនឡើង។ ក្រុមហ៊ុន ដ៏មហិមារបស់បរទេស ដូចជាក្រុមហ៊ុនរបស់ប្រទេសជប៉ុន ចិន សហរដ្ឋអាមេរិក និងកូរ៉េខាងត្បូង បានធ្វើឱ្យមានការប្រឈមនឹងសមត្ថភាពប្រកួតប្រជែងរបស់អ្នកផលិតក្នុងស្រុក"។

ទន្ទឹមពេលគ្នានេះដែរ សមាគមនេះ កំពុងបញ្ចុះបញ្ចូលសុំប្រាក់ឧបត្ថម្ភរបស់រដ្ឋាភិបាល ដើម្បីលើកទឹកចិត្តការវិនិយោគក្នុងស្រុក ក្នុងឧស្សាហកម្មក្រដាស់។ ថ្មីៗនេះ ឧស្សាហកម្មនេះ អាចផ្គត់ផ្គង់បានប្រហែល ២/៣ នៃតម្រូវការ

ក្រដាស់ ហើយប្រទេសនេះ ត្រូវគេរំពឹងថានឹងនាំចូលក្រដាស់ប្រហែល ១ លានតោន នៅឆ្នាំនេះ ដែលកើនចំនួន ២០០,០០០ តោន លើសឆ្នាំ២០០៧។

រោងចក្រផលិតក្រដាស់មួយចំនួន កំពុងរៀបចំផែនការ និងកំពុងសាងសង់នៅក្នុងប្រទេសវៀតណាម។ នៅក្នុងខែកញ្ញា ឆ្នាំ២០០៨ ក្រុមហ៊ុន Pöyry ទទួលបានកិច្ចសន្យាដើម្បីតំឡើងប្រព័ន្ធផលិតក្រដាស់ឱ្យបាន ២៥០,០០០ តោនក្នុងមួយឆ្នាំ នៅក្នុងរោងចក្រផលិតក្រដាស នៅភាគខាងជើងប្រទេសវៀតណាម។ ប្រព័ន្ធផលិតក្រដាសនេះ នឹងចាប់ដំណើរការនៅក្នុងឆ្នាំ២០១០។

ដូចគ្នានេះដែរ នៅក្នុងខែកញ្ញា ឆ្នាំ២០០៨ ក្រុមហ៊ុនផលិតក្រដាស Tan Mai បានទទួលការអនុញ្ញាតឱ្យសាងសង់រោងចក្រផលិតក្រដាសចំនួនបួន គឺរោងចក្រផលិតក្រដាសនៅក្នុងខេត្ត ដុង ណៃ រោងចក្រផលិតក្រដាសនៅក្នុងខេត្ត គ័ង ងៃ រោងចក្រក្រដាសនៅក្នុងខេត្ត ឡាំ ដុង និងរោងចក្រផលិតក្រដាសមួយទៀតនៅលើខ្ពង់រាបកណ្តាលរបស់ប្រទេសវៀតណាម។ នៅក្នុងខែឧសភា ឆ្នាំ២០០៨ សហគ្រាសផ្គត់ផ្គង់សម្ភារៈក្រដាស ឡាំ ដុង ដែលជាផ្នែកមួយរបស់ក្រុមហ៊ុនផលិតក្រដាស តាន់ មៃ បានទទួលការអនុញ្ញាតឱ្យស្ថាបនាតំបន់កំសាន្តផ្នែកទេសចរណ៏ធម្មជាតិ ដែលអស់ទឹកប្រាក់ចំនួន ៥៤ លានដុល្លាអាមេរិក នៅក្នុងស្រុក ឌី លីញ។ តំបន់កំសាន្ត បឹងកាឡានឹងរួមបញ្ចូល "សំណង់អាគារក្រោមទឹក តំបន់ទស្សនាខ្សែភាពយន្ត ឧទ្យាន កន្លែងលេងកូនគោល សណ្ឋាគារភោជនីយដ្ឋានលំដាប់ខ្ពស់ និងភូមិពាណិជ្ជកម្មរបស់ក្រុមកុលសម្ព័ន្ធជនជាតិភាគតិច" យោងតាមរដ្ឋបាលទេសចរណ៏ជាតិរបស់ប្រទេសវៀតណាម។

នៅក្នុងខែមីនា ឆ្នាំ២០០៨ ខេត្តកន្ទុំ បានផ្តល់សិទ្ធិអនុញ្ញាតដល់គំរោងមួយដែលមានទឹកប្រាក់ ៦៧ លានដុល្លាអាមេរិក ដើម្បីដំណើរការចំការឈើដាំលើផ្ទៃដី ៦៥,០០០ ហិកតា។ ក្រុមហ៊ុនដែលឈរពីក្រោយគ្រោងការនេះ ដែលមានឈ្មោះថា InnovGreen មានគំរោងចំការឈើដាំនៅក្នុងខេត្តចំនួនប្រាំ នៅក្នុងប្រទេសវៀតណាម និងសំដៅដាំដុះ "នូវប្រភេទអាកាស្យា និងប្រេងខ្យល់ដែលមានគុណភាពខ្ពស់" លើផ្ទៃដីសរុបចំនួន ៣០០,០០០ ហិកតា ដែលគេចាត់ទុកថាជា "ប្រភេទដីទំនេរ ឬមិនអាចដាំដុះបានល្អ"។

ក្រុមហ៊ុននេះ កំពុងប្រើប្រាស់ក្រុមប្រឹក្សាថែរក្សាព្រៃឈើ (FSC) ដើម្បីផ្សព្វផ្សាយពីដំណើរការប្រតិបត្តិរបស់ខ្លួន។ នាយកប្រតិបត្តិរបស់ក្រុមហ៊ុន InnovGreen លោក វូ ឌិន បានរៀបរាប់អំពីចំការឈើដាំរបស់ក្រុមហ៊ុននៅក្នុងខេត្ត ញេ អាន់ (Nghe An) ថា "ស្តង់ដារចំការឈើដាំអន្តរជាតិក្រោមក្រុមប្រឹក្សាថែរក្សាព្រៃឈើ ដែលជាប្រព័ន្ធគ្រប់គ្រងដោយអ្នកពាក់ព័ន្ធ ដើម្បីលើកកម្ពស់ឱ្យមានការគ្រប់គ្រងព្រៃឈើពិភពលោក ប្រកបដោយការទទួល

ខុសត្រូវ នឹងត្រូវយកមកអនុវត្ត"។ មិនមានចំការឈើដាំណាមួយរបស់ក្រុមហ៊ុន InnovGreen ទទួលបានការបញ្ជាក់អះអាងថាស្ថិតក្រោមប្រព័ន្ធ FSC នេះ។

ការដាំដុះដំណាំប្រេងខ្យល់ មានរឿងចំរូងចំរាស់អស់រយៈពេលជាយូរមកហើយ នៅក្នុងប្រទេសវៀតណាម។ សាស្ត្រាចារ្យ Vo Quy នៃសាកលវិទ្យាល័យជាតិរបស់ប្រទេសវៀតណាម គឺជាមនុស្សម្នាក់ដែលត្រូវបានគេចាត់ទុកថាជាបិតាចលនាថែរក្សាបរិស្ថានរបស់ប្រទេសវៀតណាម។ គាត់បាននិយាយកាលពីឆ្នាំ១៩៩១ នៅក្នុងសិក្ខាសាលាមួយស្តីពីផលប៉ះពាល់ពីចំការឈើដាំដើមប្រេងខ្យល់ ក្នុងទីក្រុង ហា ណូយ ថា "ឥឡូវនេះ វាជាបញ្ហាបន្ទាន់ដែលតម្រូវឱ្យធ្វើការសិក្សាបន្ថែមទៀត ចំពោះការជំនួសបន្តិចម្តងៗនូវដើមប្រេងខ្យល់ ដោយប្រភេទដើមឈើមួយចំនួនផ្សំចូលគ្នាដែលសមប្រកបជាងមុននៅក្នុងតំបន់ ដែលការប្រតិបត្តិចំការឈើដាំនៅក្នុងតំបន់នោះ កន្លងមកមិនទាន់បានល្អ"។

១៧ឆ្នាំក្រោយមក សេចក្តីថ្លែងការរបស់លោក Vo Quy រិតតែមានសភាពបន្ទាន់ជាងមុនទៅទៀត។ ប៉ុន្តែនេះមិនគ្រាន់តែជាបញ្ហាអំពីដើមប្រេងខ្យល់ទេ។ ខណៈដែលប្រទេសវៀតណាម នាំចូលផលិតផលក្រដាស ការនាំក្តារបន្ទះចេញពីរោងចក្រផលិតក្តារបន្ទះមួយចំនួនតាមបណ្តោយឆ្នេរ បានកើនឡើងយ៉ាងគម្ហុក នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ ឧស្សាហកម្មក្រដាស គឺជាអ្នកដឹកនាំការពង្រីកចំការឈើដាំឯកវប្បកម្មដ៏សំខាន់នៅក្នុងប្រទេសវៀតណាម។ អ្នកដែលទទួលបានជោគជ័យ គឺក្រុមហ៊ុនផលិតក្រដាស ប៉ុន្តែអ្នកដែលចាញ់ គឺជាប្រជាជននៅតាមមូលដ្ឋាន ដែលបានបាត់បង់ដីធ្លី និងមើលឃើញស្ទឹង និងអណ្តូងទឹករបស់ពួកគេ ត្រូវរីងស្ងួត។

ដោយ Chris Lang, http://chrislang.org